# បំណិនជីវិតតាមមូលដ្ឋាន

# ការប្រែប្រួលអាកាសធាតុ

## គំរូដំណើរការបង្រៀន ថ្នាក់ទី៧-៩






**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

**ឆ្នាំ ២០២៣**

# គំរូដំណើរការបង្រៀនបំណិនជីវិតតាមមូលដ្ឋាន
# ស្តីពីការប្រែប្រួលអាកាសធាតុ
# សម្រាប់ថ្នាក់ទី៧-៩

## សកម្មភាពអាទិភាពរបស់អង្គការ UNICEF

វគ្គសិក្សានេះតម្រូវឱ្យមានការចំណាយទាំងពេលវេលា និងថាមពលពីអង្គការ UNICEF ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការចំណាយពេលវេលានេះមានសក្តានុពល និងជះឥទ្ធិពលដល់ការសិក្សាទូទាំងប្រទេស លើប្រធានបទ បរិស្ថាន និងតម្លៃរបស់វា។

1- ល្បែងសិក្សា "ចំណុចរបត់" https://treecer.com/en/store/product/Tipping%20Point អង្គការ UNICEF នឹងត្រូវទិញល្បែងសិក្សានេះ ហើយបកប្រែជាភាសាខ្មែរ បន្ទាប់មកថតចម្លងមួយឈុតសម្រាប់សាលារៀននីមួយៗដែលកំពុងអនុវត្តបំណិនជីវិតតាមមូលដ្ឋានស្តីពីការប្រែប្រួលអាកាសធាតុ។ ជាការប្រសើរ គួរទាក់ទងអ្នកសរសេរល្បែងសិក្សា និងសុំការអនុញ្ញាតថតចម្លង (អ្នកប្រឹក្សាព្យាយាមតាមរយៈតំណភ្ជាប់ខាងលើ) ប៉ុន្តែការបកប្រែជាភាសាខ្មែរ និងការប្រើប្រាស់មិនមែនក្នុងគោលបំណងសម្រាប់លក់ទេ បើមិនដូច្នោះ នឹងមានការផាកពិន័យក្រោមច្បាប់រក្សាសិទ្ធិ។

2- សិស្សនឹងសរសេររឿងដែលចាំបាច់ត្រូវបោះពុម្ពជាសៀវភៅ ឬបណ្ណផ្នត់ ឬដាក់តាមអ៊ីនធឺណិតនៅលើគេហទំព័រពិសេសដែលបង្កើតឡើងសម្រាប់ចែករំលែករឿងទាំងនេះ។ អង្គការ UNICEF ជាអ្នកទទួលរាប់រងក្នុងការចំណាយថវិកាសម្រាប់ការចងក្រងជាសៀវភៅ ឬបណ្ណផ្នត់ ដើម្បីចែករំលែកទៅសាលារៀនផ្សេងៗទៀត ឬស្វែងរកនៅលើគេហទំព័ររបស់អង្គការ UNICEF ដែលអាចបោះពុម្ពបាន ឬតាមរយៈគេហទំព័រដែលបង្កើតឡើងដោយឯកវាជ្យសម្រាប់ "គំនូរជីវចលស្តីអំពីអាកាសធាតុជាភាសាខ្មែរ" ឬគេហទំព័រស្រដៀងគ្នា។

3- អង្គការ UNICEF នឹងផលិតវីដេអូដែលមានរយៈពេល ១៥នាទី សម្រាប់វាគ្មិនជំនាញផ្នែកនិរន្តរភាព។ វីដេអូទាំងនេះអាចរក្សាទុកនៅលើគេហទំព័រ ឬម៉ាស៊ីនមេរបស់អង្គការ UNICEF ឬ MoEYS និងចែករំលែកទៅសាលារៀនដែលបានស្នើសុំ។ ខាងក្រោមនេះជាបញ្ជីឈ្មោះអ្នកដែលអាចទាក់ទងជាភាសាខ្មែរ ៖

- Saron Chhem: Owner of Domlei sustainable clothing boutique, Phnom Penh, Whatsapp: +855 15 670 639, www.domlei.com
- Dai Khmer Sustainable Beauty, Phnom Penh, https://www.facebook.com/daikhmer1/
- Village works sustainable handicrafts, Phnom Penh, Whatsapp: +855 12 995 944 https://www.facebook.com/villageworkssongkhem/
- Green Lady Cambodia Sustainable Menstrual Products, Phnom Penh, Phone: 012 300 557, https://www.facebook.com/greenladycambodia/ https://www.greenladycambodia.com/?fbclid=IwAR3atS3SVcr09RP3Ma5kndW77-pHg4s1umRkt1AZQvg637B32IBmHM8ugMs
- Hatha Neary, Sustainable Teas, Toul Kork Phone 098 983 039, https://www.facebook.com/HatthaNeary/,https://hatthaneary.com/en/?fbclid=IwAR2LgUhhXjxN_YW2Jtk_3xsXdWrJ6ZEIADopdZm2RG_2MOHZKZwEt2V94-A

ដើម្បីឱ្យចនាសម្ព័ន្ធនៃការសម្ភាស មានភាពស៊ីសង្វាក់គ្នា វាត្រូវបានផ្តល់អនុសាសន៍ឱ្យពួកគេធ្វើទម្រង់សម្ភាសន៍មួយ ហើយវាគ្មិនត្រូវបានសួរសំណួរតាមលំដាប់ដូចខាងក្រោម។ ឱ្យអ្នកឆ្លើយបទសម្ភាសមើលសំណួរជាមុនសិន ដើម្បីឱ្យពួកគេដឹងពីអ្វីដែលនឹងត្រូវសួរ ហើយមានពេលវេលាគិតអំពីចម្លើយ។ ត្រូវចែកសំណួរឱ្យពួកគេពីរ ឬបីថ្ងៃមុន៖

- សូមប្រាប់យើងពីឈ្មោះរបស់អ្នក អាយុ ទីតាំង ឈ្មោះអាជីវកម្មរបស់អ្នក និងទំនិញដែលលក់?
- ចំពោះអ្នក តើនិរន្តរភាពមានន័យដូចម្តេច?
- តើអាជីវកម្មរបស់អ្នកសម្រេចបាននិរន្តរភាពដោយរបៀបណា? សូមប្រាប់យើងអំពីផលិតផលរបស់អ្នក ការវេចខ្ចប់ ប្រភព ស្តង់ដាការងារ និងប្រាក់ខែរបស់អ្នក ការដឹកជញ្ជូនផលិតផល ការកែច្នៃឡើងវិញ ការប្រើប្រាស់ថាមពល និងអ្វីគ្រប់យ៉ាងដែលអ្នកអាចធ្វើបានអំពីវដ្តនៃផលិតផលរបស់អ្នក?
- តើអ្វីជាការជំរុញទឹកចិត្តអ្នកឱ្យបង្កើតអាជីវកម្មប្រកបដោយនិរន្តរភាព?
- តើអ្នកសិក្សាអំពីបញ្ហានិរន្តរភាពពីកន្លែងណា និងដោយរបៀបណា? តើអ្នកបានមើល ឬអានអ្វីខ្លះ?
- តើអ្នកអាចប្រាប់យើងអំពីការលំបាកណាមួយ ដែលអ្នកជួបប្រទះក្នុងការរៀបចំ និងលក់ផលិតផលរបស់អ្នកបានទេ? (ឧទាហរណ៍ បើផលិតផលរបស់អ្នកមានតម្លៃថ្លៃក្នុងការផលិត ដូច្នេះអ្នកត្រូវលក់វាក្នុងតម្លៃខ្ពស់ តើអតិថិជនចង់ចំណាយទិញវាឬទេ?)
- តើអ្នកគិតថាអ្វីដែលអាចជួយអ្នកជម្នះលើការលំបាកទាំងនោះ?
- ហេតុអ្វីបានជាអ្នកគិតថា វាមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ក្នុងការទទួលយកការរស់នៅ ប្រកបដោយនិរន្តរភាព? (សូមនិយាយអំពីបញ្ហាបរិស្ថាន ឬសុខភាពដែលអ្នក បានដឹងដោយសារកង្វះនិរន្តរភាព ឬអ្វីដែលអ្នកដឹងអំពីផែនការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា និងបញ្ហាដែលអាចនាំទៅរកការខូចខាតបរិស្ថាន ឬការប្រែប្រួលអាកាសធាតុកាន់តែខ្លាំង ប្រសិនបើអនុវត្តមិនបានល្អ)
- តើអ្នកធ្វើតាមការអនុវត្តប្រកបដោយនិរន្តរភាពផ្សេងទៀតនៅក្នុងជីវិតរបស់អ្នក និងនៅខាងក្រៅអាជីវកម្មរបស់អ្នកឬទេ? ប្រសិនបើធ្វើតាម តើអ្នកអាចប្រាប់យើងបានទេថា ពួកវាជាអ្វី ហើយហេតុអ្វីបានជាអ្នកធ្វើវា?(ឧទាហរណ៍ ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យដើម្បីសន្សំប្រាក់ និងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ការបិទថាមពលអគ្គិសនីលើឧបករណ៍ទាំងអស់នៅពេលមិនប្រើប្រាស់ ការច្នៃសម្អាតទឹកឡើងវិញ។ល។)
- តើអ្នកអាចប្រាប់យើងអំពីអាជីវកម្មដែលមាននិរន្តរភាពផ្សេងទៀត ឬអ្នកជំនួញដែលអ្នកស្គាល់បានទេ?
- តើអ្នកមានគំនិតសម្រាប់អាជីវកម្មណាមួយ ដែលប្រកបដោយនិរន្តរភាពផ្សេងទៀតដែលអ្នកចង់ចាប់ផ្តើមដែរឬទេ ឬអ្នកមិនចង់ចាប់ផ្តើមអាជីវកម្ម ដែលប្រទេសកម្ពុជាត្រូវការ?
- តើអ្នកនឹងផ្តល់យោបល់អ្វីខ្លះដល់សិស្ស និងអ្នកទាំងអស់គ្នា ដោយចាប់ផ្តើមអនុវត្តពីខ្លួនឯងទៅ(កាត់បន្ថយការប្រើរថយន្ត ឬម៉ូតូ និងជិះកង់ជំនួសវិញ? ទិញតែសម្លៀកបំពាក់ធ្វើពីកំណាត់ធម្មជាតិ? បិទភ្លើងពេលចេញពីបន្ទប់ ឬមិនប្រើ? ជៀសវាងប្លាស្ទិក ប្រើថង់និងប្រដាប់ប្រដាប្រើប្រាស់ប្រកបដោយនិរន្តរភាព? ផឹកទឹកពីធុងទឹក មិនមែនដបប្លាស្ទិកទេ? ...)
- តើមានពាក្យចុងក្រោយផ្សេងទៀតទេ?

**ប្រធានបទជាក់លាក់** ៖ ការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ និងការរស់នៅប្រកបដោយនិរន្តរភាព

**ប្រធានបទពាក់ព័ន្ធសម្រាប់ការសិក្សាបន្ថែម** ៖ សេវាកម្មបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះនិងការបាត់បង់ជីវៈចម្រុះ ការប្រើប្រាស់ដី(កសិកម្ម និងការកាប់បំផ្លាញព្រៃឈើ) អាស៊ីតមហាសមុទ្រ ការបំពុលពីប្លាស្ទិក ការបំពុលខ្យល់និងទឹក ការបំពុល

និងសុខភាពមនុស្ស ការគ្រប់គ្រងទឹក បច្ចេកវិទ្យាកាត់បន្ថយអាកាសធាតុ គោលនយោបាយ និងសកម្មភាពអាកាសធាតុសកល និងថ្នាក់ជាតិ។

**ធនធាន និងសម្ភារៈដែលត្រូវការ** ៖ សមាជិកសហគមន៍ដែលមានបទពិសោធស្តីពីផលប៉ះពាល់គ្រោះមហន្តរាយ ឬអាកាសធាតុអាថ្វាធរថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិនៃក្រសួងបរិស្ថាន ឬអ្នកវិទ្យាសាស្ត្របរិស្ថាន ឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ឯកសារយោងការប្រែប្រួលអាកាសធាតុ(CCRD) កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ស្មាតហ្វូន ក្រដាស ហ្វឺត ឬខ្មៅដៃពណ៌ ក្រដាសផ្ទាំងធំ ស្កុត ក្រដាសពណ៌តូចៗ ក្តារខៀន...។

**សម្គាល់លើការប្រើប្រាស់ធនធានសម្ភារៈ** ៖ ប្រសិនបើមានលទ្ធភាព សូមប្រើកុំព្យូទ័រ និងឧបករណ៍បញ្ចាំងស្លាយ ឬក្តារខៀន វាប្រសើរជាងព្រីនលើក្រដាស ធ្វើបែបនេះដើម្បីសន្សំសំចៃក្រដាស។ ការសន្សំសំចៃក្រដាសជាការសន្សំសំចៃដើមឈើនឹងជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ!។ មេរៀននេះ "ការប្រើប្រាស់ធនធានធម្មជាតិតិចតួច និងការរស់នៅប្រកបដោយនិរន្តរភាព" គឺជាមេរៀនមួយដែលអ្នកត្រូវតែបង្រៀនសិស្សរបស់អ្នកជានិច្ច តាមរយៈខ្លឹមសារវគ្គសិក្សានិងឧទាហរណ៍ល្អ។ ដូចគ្នានេះដែរ សូមប្រាកដថា ត្រូវបិទឧបករណ៍អគ្គិសនីទាំងអស់នៅពេលមិនប្រើប្រាស់ ហើយត្រូវច្បាស់ថា សិស្សយល់ពីសារៈសំខាន់ក្នុងការបិទផងដែរ។

**រយៈពេល** ៖ មួយឆមាស។ គ្រូបង្រៀនត្រូវប្រើម៉ោងក្រៅកម្មវិធីសិក្សា ដើម្បីបញ្ចប់សកម្មភាពជាមួយសិស្ស។

**បំណិនទន់គោលដៅ** ៖ ការយល់ដឹងអំពីវិទ្យាសាស្ត្រទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍សាលារៀន ការអនុវត្តបំណិនជីវិត (ចំណេះដឹងទាក់ទងនឹងអាកាសធាតុ និងដំណោះស្រាយការបន្សាំក្នុងតំបន់ អ្វីដែលត្រូវធ្វើក្នុងការកាត់បន្ថយគ្រោះមហន្តរាយ) និងបំណិនទន់(ការគិតប្រកបដោយភាពច្នៃប្រឌិត ការវិភាគ សហប្រតិបត្តិការ ភាពធន់ គុណតម្លៃផ្ទាល់ខ្លួន...)។

**ឯកសារនេះមាន** ៖ គំរូដំណើរការបង្រៀនមួយឆមាសសម្រាប់គ្រូ កំណត់សម្គាល់អំពីកន្លែងដែលត្រូវស្វែងរកព័ត៌មានបន្ថែមគំនិតសម្រាប់សកម្មភាពសិស្ស និងគ្រូបង្រៀននៅក្នុងថ្នាក់រៀន និងក្នុងសហគមន៍។

**សម្ភារៈបន្ថែម** ៖ មាននៅក្នុង CCRD រួមបញ្ចូលទាំងផែនការវគ្គសិក្សា។ តួលេខដាក់លាក់ដែលប្រើសម្រាប់យោងត្រូវបានកត់ត្រានៅក្នុងតារាងគំរូដំណើរការបង្រៀន៦ដំណាក់កាលខាងក្រោម។ ឧបសម្ព័ន្ធនៃឯកសារនេះ និង CCRD ក៏ណែនាំឱ្យស្វែងរកធនធានផ្សេងទៀតដើម្បីប្រើប្រាស់ ឬស្វែងរកតាមអ៊ីនធឺណិតផងដែរ។ គ្រូអាចប្រើប្រាស់សម្ភារៈដោយផ្ទាល់ពី CCRD ឬទទួលយកវាតាមដែលគ្រូមើលឃើញថាល្អបំផុតសម្រាប់សិស្ស និងសហគមន៍របស់ពួកគេ។ គ្រូក៏ត្រូវយោងលើសៀវភៅសិក្សាស្តីពីការប្រែប្រួលអាកាសធាតុរបស់ក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ទី៤ ទី៥ និងទី៦ ដើម្បីមើលអំពីអ្វីដែលសិស្សបានរៀនកន្លងមក។ គ្រូក៏ត្រូវពិនិត្យឡើងវិញនូវសៀវភៅសិក្សាវិទ្យាសាស្ត្រ ថ្នាក់ទី១-៦ ដើម្បីដឹងថា តើប្រធានបទវិទ្យាសាស្ត្រអ្វីខ្លះដែលសិស្សបានសិក្សាកន្លងមក៖ គ្រូអាចកែសម្រួលគំរូដំណើរការបង្រៀននេះតាមតម្រូវការ និងឱ្យសិស្សរំលឹកពីអ្វីដែលបានសិក្សាកន្លងមក។

**ប្រធានបទសិក្សា** ៖ ការប្រែប្រួលអាកាសធាតុមានភាពស្មុគស្មាញ។ គ្រូត្រូវតែអាន CCRD ដោយប្រុងប្រយ័ត្ន និងធ្វើការស្វែងរកព័ត៌មានតាមអ៊ីនធឺណិតដោយខ្លួនឯងដើម្បីបន្ថែមតាមតម្រូវការ។ គ្រូគួរតែមើលផងដែរអំពីគេហទំព័រទាំងនេះ https://www.youtube.com/watch?v=SsHUdPI0JJI and https://www.youtube.com/watch?v=5cFWtolh A3A and https://www.youtube.com/watch?v=OkZRRT6Zg4I ដើម្បីគាំទ្រដល់ការសិក្សាសម្រាប់មនុស្សពេញវ័យ។

**ព័ត៌មានជំនួយសម្រាប់ដំណើរការបង្រៀន ៖** បម្រែបម្រួលអាកាសធាតុ ទាក់ទងទៅនឹងស្ទើរតែគ្រប់ប្រធានបទ ក្នុងមុខវិជ្ជាផ្សេងទៀតដែលបង្រៀននៅក្នុងសាលារៀន ព្រមទាំងកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានផងដែរ។ ការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់សុខភាព ហិរញ្ញវត្ថុ អន្តរកម្មសង្គម បរិស្ថាន ជីវភាពរស់នៅ និងគុណភាពជីវិតទូទៅនាពេលបច្ចុប្បន្ន និងអនាគត។ នៅពេលបង្រៀនសិស្សអំពីបម្រែបម្រួលអាកាសធាតុ យើងចង់ជួយពួកគេឱ្យយល់អំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុតាមរយៈការពន្យល់អំពីវិទ្យាសាស្ត្រ ហើយយើងចង់ឱ្យពួកគេមើលពីអ្វីដែលមានឥទ្ធិពលដល់ពួកគេនៅពេលនេះ។ យើងអាចធ្វើដូចនេះបានដោយការផ្តល់នូវឧទាហរណ៍ក្នុងជីវិតពិត អំពីអ្វីដែលប៉ះពាល់ផ្ទាល់ទៅលើជីវិតរបស់ពួកគេ ជីវិតគ្រួសាររបស់ពួកគេ និងជីវិតរបស់មនុស្ស ជម្រកធម្មជាតិនិងសត្វនៅជុំវិញខ្លួន។

សិស្សគួរតែដឹងរួចហើយថា អ្វីទៅជាការប្រែប្រួលអាកាសធាតុ ប៉ុន្តែប្រហែលជានៅតែមានចំណុចមិនច្បាស់មួយចំនួន។ សិស្សជាច្រើន(និងមនុស្សពេញវ័យ)យល់ច្រឡំអំពីការប្រែប្រួលអាកាសធាតុជាមួយនឹងបញ្ហាបរិស្ថានផ្សេងទៀត ដូចជាកាកសំណល់ទូទៅ និងការបំពុល ព្រមទាំងការថយចុះស្រទាប់អូហ្សូន។ ដូច្នេះហើយ ក្នុងមេរៀនទាំងនេះ តួនាទីរបស់គ្រូគឺរំលឹកពួកគេអំពីមូលដ្ឋានគ្រឹះនៃការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានផ្សេងទៀត ដោយបង្រៀនពួកគេអំពីសម្ភារៈថ្មីៗសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការរស់នៅប្រកបដោយនិរន្តរភាព ហើយដឹកនាំពួកគេលើការអនុវត្តផ្ទាល់ក្នុងការរស់នៅប្រកបដោយភាពឆ្លាតវៃ។

ចំណុចសំខាន់បំផុតនៃមេរៀននេះត្រូវផ្តោតលើផលវិបាកនៃការប្រែប្រួលអាកាសធាតុក្នុងស្រុក និងរបៀបនៃការរស់នៅប្រកបដោយនិរន្តរភាពដើម្បីជួយកាត់បន្ថយផលប៉ះពាល់អាកាសធាតុសកល។ នៅថ្នាក់ទី៨ និងទី៩ សិស្សគួរត្រៀមខ្លួនជាស្រេចក្នុងការរៀបចំផែនការសកម្មភាពសមញ្ញ ប៉ុន្តែជឿនលឿន និងសុំការគាំទ្រពីសហគមន៍។

គោលដៅចុងក្រោយនៃការបង្រៀនមេរៀនអំពីការប្រែប្រួលអាកាសធាតុ គឺដើម្បីបង្កើតឱ្យមានសកម្មភាព៖ កុមារនិងយុវជនបានទទួលបទពិសោធពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាងមនុស្សជំនាន់មុន។ កុមារ និងយុវជនត្រូវតែជាកម្លាំងចលករនៃការចូលរួមនាពេលអនាគត។ ដំណើរការបង្រៀនគួរជួយសិស្សឱ្យរកឃើញពីស្ថានភាពនៃបញ្ហា កំណត់បានពីមូលហេតុ និងផលវិបាកជាក់លាក់នៃបញ្ហា បង្កើត និងអនុវត្តដំណោះស្រាយ ហើយបន្ទាប់មកផ្សព្វផ្សាយ ឬបង្រៀនដល់សហគមន៍។

មេរៀននេះគួរតែផ្អែកលើបំណិនទន់ផ្សេងទៀត (LLS) ទាំងអស់ដែលសិស្សបានរៀន រួមមាន ប៉ុន្តែមិនកំណត់ចំពោះការដោះស្រាយបញ្ហា ការរិះគិតពិចារណា ភាពធន់ សហប្រតិបត្តិការ ទំនាក់ទំនង ការចូលរួម ការចរចា ការច្នៃប្រឌិត និងការសម្រេចចិត្ត។ វាគួរតែមានបង្រៀននៅថ្នាក់វិទ្យាសាស្ត្រមុននឹងបង្រៀនមេរៀននេះ ដូច្នេះសម្រាប់ហេតុផលនេះ វាសំខាន់ណាស់ដែលគ្រូពិនិត្យមើលកម្មវិធីសិក្សាវិទ្យាសាស្ត្រពីឆ្នាំមុនៗ។

មេរៀនទាំងនេះអាចប្រើប្រាស់សម្ភារៈបង្រៀនច្រើនប្រភេទ រួមទាំងដ្យាក្រាមដែលផ្នែកខ្លះអាចផ្លាស់ទី រូបភាពនៃផលប៉ះពាល់អាកាសធាតុនៅមូលដ្ឋាន នៅប្រទេសកម្ពុជា ឬនៅជុំវិញពិភពលោក វីដេអូអំពីសកម្មភាពអាកាសធាតុសម្រាប់យុវវ័យ វីដេអូបង្រៀន(ការបង្រៀនតាមរយៈវីដេអូ) និងព័ត៌មានភ្ជាប់ដោយរូបភាពដែលបង្ហាញពីការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា បណ្តាប្រទេសតាមដងទន្លេមេគង្គ និងពិភពលោក។

ក្នុងនាមជាគ្រូបង្រៀនអ្នកត្រូវគាំទ្រសិស្ស ដោយណែនាំសិស្សឱ្យដឹងពីអ្វីដែលត្រូវធ្វើ ថាតើអ្វីដែលគេអាចធ្វើបាន ឬក៏អ្វីដែលអាចបណ្តាលឱ្យខូចខាតដល់បរិស្ថាន និងបង្កើនការប្រែប្រួលអាកាសធាតុ។ អ្នកក៏ត្រូវជួយពួកគេក្នុងការបំផុសគំនិតអំពីដំណោះស្រាយចំពោះបញ្ហាតាមរយៈសកម្មភាពផ្ទាល់ ឬប្រយោល ឬទាំងផ្ទាល់និងប្រយោល។ អ្នកអាចធ្វើសកម្មភាពតាមរយៈ ៖

1- ការអញ្ជើញវាគ្មិនដែលអាចនិយាយអំពីផលប៉ះពាល់ផ្ទាល់នៃការប្រែប្រួលអាកាសធាតុលើពួកគេ
2- ការបង្ហាញ ឬបញ្ចាំងវីដេអូដល់សិស្សប្រសិនបើមិនមានវាគ្មិន
3- ការអញ្ជើញអ្នកវិទ្យាសាស្រ្តឱ្យផ្តល់ព័ត៌មាន
4- ការផ្តល់ពេលវេលាសម្រាប់ការស្រាវជ្រាវស្តីពីបញ្ហានៃការប្រែប្រួលអាកាសធាតុក្នុងតំបន់
5- ការចូលរួមរបស់សិស្សដើម្បីសន្ទនាអំពីបញ្ហាទាំងនោះ
6- ការចូលរួមរបស់សិស្សដើម្បីបង្រៀនដល់មិត្តភក្តិ
7- ជួយពួកគេអនុវត្តដំណោះស្រាយ បណ្តុះបណ្តាលពួកគេពីរបៀបទំនាក់ទំនង(ផ្សព្វផ្សាយ) និងឱ្យសិស្សបង្រៀនអំពីអ្វីដែលពួកគេដឹង។

## គោលបំណងទូទៅនៃវគ្គសិក្សា

គោលបំណងនៃវគ្គសិក្សាពេញមួយឆមាសនេះគឺ៖

1- បង្រៀនសិស្សអំពីមូលដ្ឋានគ្រឹះនៃបរិយាកាស និងការប្រែប្រួលអាកាសធាតុ រួមទាំងភាពខុសគ្នារវាងស្រទាប់អូហ្សូន និងការប្រែប្រួលអាកាសធាតុ និងទម្រង់ផ្សេងៗនៃបញ្ហាបរិស្ថាន
2- ត្រូវប្រាកដថាពួកគេយល់ពីមូលហេតុ បម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់អ្វីខ្លះជុំវិញពួកគេ
3- យល់ពីរបៀបដើម្បីត្រៀមខ្លួន ការពារ និងបន្សាំខ្លួនទៅនឹងគ្រោះមហន្តរាយ
4- លើកទឹកចិត្តក្នុងការធ្វើយុទ្ធនាការនៅក្នុងភូមិរបស់ខ្លួនដើម្បីសម្របខ្លួនតាមការប្រែប្រួលអាកាសធាតុ។

នៅចុងបញ្ចប់នៃវគ្គសិក្សា សិស្សអាច៖

- ពន្យល់បានពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងភាពខុសគ្នារវាងការកាត់បន្ថយ និងការបន្សាំ
- យល់ដឹងពីការរស់នៅប្រកបដោយនិរន្តរភាព
- និយាយអំពីសកម្មភាពរបស់យុវជនជុំវិញពិភពលោកស្តីពីការប្រែប្រួលអាកាសធាតុ
- កំណត់ដំណោះស្រាយក្នុងជីវភាពរស់នៅជាក់ស្តែងចំពោះការរស់នៅប្រកបដោយភាពវៃឆ្លាតជាមួយនឹងអាកាសធាតុនៅក្នុងសហគមន៍របស់ពួកគេ ហើយអនុវត្តសកម្មភាពនោះ។
- បង្កើតយុទ្ធនាការផ្សព្វផ្សាយអំពីការរស់នៅប្រកបដោយនិរន្តរភាព។

បំណិនទន់(LLS) ត្រូវបានពង្រឹង ឬបញ្ចូលនៅក្នុងមេរៀន៖ នៅក្នុងដំណើរការបង្រៀននេះ សិស្សនឹងសិក្សា និងពង្រឹងចំណេះដឹងមានស្រាប់របស់ពួកគេអំពី "បំណិនទន់" គោលទាំង១២ ដែលបានរៀបចំក្នុងកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន។ តើបំណិនទន់ទាំងនេះមានលក្ខណៈដូចម្តេច ឬចាំបាច់ត្រូវបញ្ចូលទៅក្នុងម៉ោងសិក្សានីមួយៗ? បំណិនទន់ទាំងនេះត្រូវបានកត់ត្រានៅក្នុងជួរឈរខាងស្តាំនៃតារាងដំណើរការបង្រៀន។ បំណិនទន់ទាំងនោះរួមមាន៖

1- **ការដោះស្រាយបញ្ហា** ៖ តាមរយៈដំណើរការនៃការទទួលស្គាល់បញ្ហាក្នុងពិភពពិត ការកំណត់អត្តសញ្ញាណនៃបញ្ហាជាអាទិភាព និងការអភិវឌ្ឍដំណោះស្រាយដែលអាចអនុវត្តបាន សិស្សនឹងរៀនដោះស្រាយបញ្ហាតាមសមត្ថភាពបច្ចុប្បន្នរបស់ពួកគេ។
2- **ការរិះគិតពិចារណា** ៖ នៅពេលដែលសិស្សធ្វើការវិភាគមូលហេតុដើម និងមូលហេតុបន្ទាប់បន្សំនៃបញ្ហា ដើម្បីស្វែងរកដំណោះស្រាយ ពួកគេត្រូវប្រៀបធៀបដំណោះស្រាយផ្សេងៗក្នុងចំណោមដំណោះស្រាយទាំងអស់ដែលពួកគេបានបំផុសគំនិត ធ្វើការវិភាគប្រៀបធៀបផលប៉ះពាល់ និងភាពពាក់ព័ន្ធនៃដំណោះស្រាយ។

3- **ការច្នៃប្រឌិត ឬការបង្កើតថ្មី** ៖ សិស្សនឹងមានភាពច្នៃប្រឌិតនៅពេលដែលពួកគេអនុវត្តដំណោះស្រាយផ្ទាល់ខ្លួន និងមូលហេតុនៃបញ្ហាដែលបានកំណត់។ ការច្នៃប្រឌិតអាចជាសំឡេង ឬការច្នៃប្រឌិតប្រកបដោយបញ្ញា និងសិល្បៈ។

4- **សហប្រតិបត្តិការ** ៖ ក្រុមត្រូវបានរំពឹងថានឹងសង្ខេបបញ្ហា មូលហេតុ ដំណោះស្រាយ និងគម្រោងសកម្មភាពមួយ។ ក្នុងការធ្វើបែបនេះ ពួកគេរៀនសហការជាមួយអ្នកដទៃ រៀនគោរពអ្នកដទៃ និងរបៀបសម្រុះសម្រួលតាមការចាំបាច់។

5- **ការសម្រេចចិត្ត** ៖ នៅពេលដែលសិស្សត្រូវបានស្នើសុំឱ្យជ្រើសរើសដំណោះស្រាយជាអាទិភាពមួយក្នុងចំណោមដំណោះស្រាយមួយចំនួនដែលមាន បំណិនជាអាទិភាព និងបំណិនធ្វើការសម្រេចចិត្តរបស់ពួកគេផ្អែកលើហេតុផលដែលពួកគេបានបង្កើតនឹងត្រូវបានពង្រឹង។

6- **ការចរចា** ៖ នៅពេលដែលក្រុមជ្រើសរើសសកម្មភាព និងដំណោះស្រាយជាអាទិភាព សមាជិកក្រុមត្រូវបានរំពឹងថាយល់ព្រមលើការសម្រេចចិត្តរបស់ពួកគេជាក្រុម។ សិស្សនឹងព្យាយាមបញ្ចុះបញ្ចូលអ្នកដទៃឱ្យជ្រើសរើសបញ្ហា និងដំណោះស្រាយជាក់លាក់ ដោយបង្ហាញពីហេតុផលផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីឈានដល់ការយល់ស្របគ្នា។

7- **ការប្រាស្រ័យទាក់ទង** ៖ តាមរយៈដំណើរការនៃការកំណត់បញ្ហា ការអភិវឌ្ឍដំណោះស្រាយ និងការលើកសំណើ សិស្សម្នាក់ៗប្រាស្រ័យទាក់ទងតាមរយៈគំនិត និងការគិតរបស់ពួកគេ។ សិស្សក៏ត្រូវស្តាប់អ្នកដទៃដោយយកចិត្តទុកដាក់ផងដែរ ដើម្បីយល់និងពេញចិត្តចំពោះទស្សនៈផ្សេងៗ។

8- **ភាពធន់** ៖ ការសម្របខ្លួនទៅនឹងអាកាសធាតុ ជារឿយៗត្រូវបានប្រើប្រាស់ជំនួសដោយពាក្យ "ភាពធន់"។ តាមរយៈការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការយល់ដឹងពីប្រភេទនៃសកម្មភាពបន្សាំដែលត្រូវការដើម្បីរក្សាបាននូវសុកមង្គល និងសុខភាពល្អ ពួកគេកំពុងបង្រៀនខ្លួនឯងអំពីទិដ្ឋភាពមួយនៃភាពធន់។

9- **ការចូលរួម** ៖ ការចូលរួមមានន័យថា ក្នុងការអប់រំរបស់ពួកគេ សិស្សនិយាយ ស្តាប់ និងចូលរួមជាមួយមិត្តភក្តិនៅក្នុងសាលារៀន ការឱ្យតម្លៃលើយោបល់និងគំនិតផ្សេងៗ និងឱ្យសិស្សគ្រប់គ្រងការសិក្សារបស់ពួកគេ។ ការចូលរួមធ្វើឱ្យប្រសើរឡើងនូវភាពជាម្ចាស់នៃអភិបាលកិច្ចនៅក្នុងសាលារៀន និងសហគមន៍។

10- **ការយល់ចិត្ត** ៖ បម្រែបម្រួលអាកាសធាតុមានផលប៉ះពាល់លើមនុស្សផ្សេងៗគ្នា អាស្រ័យលើទីកន្លែងដែលពួកគេរស់នៅ និងសំខាន់ជាងនេះទៅទៀតគឺស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ។ សិស្សត្រូវសិក្សាឱ្យដឹងថា វាជារឿងសំខាន់ដើម្បីពិចារណាពីភាពងាយរងគ្រោះបំផុត៖ ជនចាស់ជរា ជនក្រីក្រខ្លាំង ជនពិការ ដែលងាយរងផលប៉ះពាល់។

11- **ការគោរពភាពចម្រុះ** ៖ ស្រដៀងគ្នាទៅនឹងការយល់ចិត្ត សិស្សត្រូវយល់ថាទស្សនៈចម្រុះមានសារៈសំខាន់ក្នុងការយល់ដឹងផលប៉ះពាល់ពីអាកាសធាតុ របៀបកាត់បន្ថយការប្រែប្រួលអាកាសធាតុ របៀបសម្របខ្លួន និងរបៀបរស់នៅប្រកបដោយនិរន្តរភាព។ អ្វីដែលមនុស្សម្នាក់ធ្វើបាន មិនប្រាកដថាអ្នកដទៃអាចធ្វើបានគ្រប់គ្នានោះទេ។

12- **ស្វ័យគ្រប់គ្រង** ៖ សិស្សនឹងមានតួនាទីរៀងៗខ្លួននៅក្នុងគម្រោងដ៏ស្មុគស្មាញ ពួកគេត្រូវគ្រប់គ្រងពេលវេលា និងឥរិយាបថរបស់ពួកគេ ដើម្បីឱ្យពួកគេជួយក្រុម។ ដូចគ្នានេះដែរ ពួកគេត្រូវរៀនពីរបៀបសម្របសម្រួលឥរិយាបថរបស់ពួកគេដើម្បីឱ្យកាន់តែមាននិរន្តរភាព និងមានសុខភាពល្អសម្រាប់ជីវិតលើភពផែនដី។

| ខែ | សប្ដាហ៍ | ម៉ោងសិក្សា | សកម្មភាពគ្រូ | បំណិនទន់គោលដៅ |
|---|---|---|---|---|
| **ជំ.១. ការស្វែងយល់ប្រធានបទ** | | | **គោលបំណង៖** សិស្សពិនិត្យឡើងវិញអ្វីដែលពួកគេដឹងអំពីការប្រែប្រួលអាកាសធាតុ និងសិក្សាព័ត៌មានថ្មីស្តីពីការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ហើយសិស្សយល់ និងអាចអនុវត្តការរស់នៅប្រកបដោយភាពឆ្លាតវៃ និងនិរន្តរភាពអាកាសធាតុ។ ករណីនេះត្រូវធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នានូវការបង្រៀនមនុស្សពេញវ័យ ការបង្រៀនពីមិត្តភ័ក្តិ និងការស្វែងយល់ដោយខ្លួនឯង។ | |
| ១ | ១ | ២ (២) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** រៀបចំស្លាយ ឬរូបភាពធំៗ ១-ស្រទាប់បរិយាកាស ២-ដ្យាក្រាមរូបភាព រូបភាពស្តីពីបម្រែបម្រួលអាកាសធាតុ និងបញ្ហា បរិស្ថានផ្សេងៗទៀត(គ្រូត្រូវអាន CCRD មេរៀនទី១-៤)។<br>**សម្ភារៈ ៖** កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ក្តារខៀន ដីស ហ្វឺត ក្រដាសផ្ទាំងធំ។<br><br>**សកម្មភាពទី១ ៖ បទពិសោធ និងបញ្ហាផ្ទាល់ខ្លួន**<br>រៀបរាប់ពីបញ្ហាដូចដែលបានលើកឡើងខាងលើមាន បម្រែបម្រួលអាកាសធាតុ ការរស់នៅដែលខ្វះការយកចិត្តទុកដាក់អំពីកាកសំណល់ ថាមពល ទឹក ហើយឱ្យសិស្សរៀបរាប់ពីបទពិសោធ និងការអង្កេតស្វែងយល់របស់ពួកគេអំពីបញ្ហាទាំងនេះ។ ឱ្យសិស្សផ្តល់ជាព្យុះគំនិតអំពីវិធីដែលពួកគេអាចធ្វើបាន ហើយប្រមូលកត់ត្រាទុករាល់គំនិតទាំងនេះ។ ដោយសារសិស្សមិនដែលបានរៀនអំពីអ្វីនៅឡើយ ការឆ្លើយរបស់ពួកគេប្រហែលមិនទាន់ត្រូវនៅឡើយ ប៉ុន្តែវាមិនអីទេ គ្រូគ្រាន់តែកត់ត្រាបញ្ហាទាំងនេះនៅលើក្រដាសផ្ទាំងធំ ហើយទុកចម្លើយទាំងនេះសម្រាប់ប្រៀបធៀបនៅធមាសដែលត្រូវសិក្សាបន្ទាប់។<br><br>**សកម្មភាពទី២ ៖ រំលឹកឡើងវិញ**<br>សិស្សគួរតែបានរៀនអំពីមូលដ្ឋាននៃការប្រែប្រួលអាកាសធាតុក្នុងថ្នាក់ទី៤-៦ កម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន។ ទោះយ៉ាងណាក៏ដោយ ពួកគេប្រហែលជាត្រូវការការកែសម្រួលឡើងវិញ។ ការសិក្សានេះគឺត្រូវរំលឹកឡើងវិញនូវអ្វីដែលពួកគេបានរៀនដោយប្រើធនធានពី CCRD ថ្នាក់ទី៤-៦។ ប្រសិនបើសិស្សមិនទាន់បានរៀនពីមូលដ្ឋានគ្រឹះទេ គ្រូបង្រៀនត្រូវបង្រៀនពួកគេឡើងវិញអំពី GHGs មូលហេតុនៃការប្រែប្រួលអាកាសធាតុ និង | **ការប្រាស្រ័យទាក់ទង ៖** សិស្សនឹងត្រូវប្រាស្រ័យទាក់ទងគ្នាឲ្យបានច្បាស់លាស់ និងត្រឹមត្រូវ ទើបអាចបង្រៀនបាន។<br><br>**ការចូលរួម ៖** សិស្សនឹងចូលរួមយ៉ាងពេញលេញនៅក្នុងមេរៀនដោយការបង្រៀន។<br><br>**ការរិះគិតពិចារណា ៖** ក្នុងការសរសេរការវាយតម្លៃរបស់ពួកគេលើវីដេអូ សិស្សនឹងត្រូវបានស្នើឱ្យគិតយ៉ាងម៉ត់ចត់អំពីអ្វីដែលល្អ និងអ្វីដែលអាក្រក់អំពីវីដេអូ។ សិស្សមិនគ្រាន់តែវាយការណ៍ពីរឿងនេះទេ ប៉ុន្តែក៏កែលម្អវាដែរ។<br><br>**ស្វ័យគ្រប់គ្រង ៖** ក្នុងនាមជាគ្រូបង្រៀន សិស្សនឹងត្រូវគ្រប់គ្រងពេលវេលា និងអាកប្បកិរិយារបស់ពួកគេ ដូច្នេះសិស្សត្រូវបានគេគោរព និងមាន |

| | | | | |
|---|---|---|---|---|
| | | | ផលប៉ះពាល់នៃអាកាសធាតុធៀបនឹងបញ្ហាបរិស្ថានផ្សេងទៀត។ ទោះយ៉ាងណាក៏ដោយ វគ្គសិក្សានេះត្រូវបានសន្មតថាពួកគេបានរៀនរួចហើយ។<br>សិស្សត្រូវថតចម្លងសៀវភៅយោង CCRD ថ្នាក់ទី៤-៦ ដើម្បីជាការចែករំលែកសម្រាប់ការសិក្សា។ ទុកពេលឱ្យសិស្ស ៣០នាទីដើម្បីអាន ឬសង្ខេបមេរៀនទី១-៤។<br>គ្រូចាត់សិស្សចំនួនពី ២-៣នាក់(អាស្រ័យលើចំនួនសិស្ស) ឱ្យទទួលក្នុងប្រធានបទមួយ។ បន្ទាប់មកសុំឱ្យសិស្សមកមុខបន្ទប់ដើម្បីបង្រៀនរហូតដល់ ៥នាទីក្នុងមួយប្រធានបទ៖<br>• តើឧស្ម័នផ្ទះកញ្ចក់ GHGs ជាអ្វី?<br>• តើ GHGs ធំៗ ៣-៤ ប្រភេទមានអ្វីខ្លះ?<br>• ហេតុអ្វីបានជាបញ្ហា GHGs គឺជារឿងចាំបាច់?<br>• តើមានអ្វីកើតឡើងនៅពេលដែល GHGs មានកាន់តែច្រើន?<br>• ហេតុអ្វីរស្មីសំយោគមានសារៈសំខាន់សម្រាប់ការគ្រប់គ្រង GHGs?<br>• តើសកម្មភាពមនុស្សបែបណាដែលបញ្ចេញ GHGs?<br>• តើអ្វីជាភាពខុសគ្នារវាងការប្រែប្រួលអាកាសធាតុ និងបញ្ហាស្រទាប់អូហ្សូន?<br>• តើបញ្ហាបរិស្ថានផ្សេងទៀតដែលមិនចាំបាច់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុមានអ្វីខ្លះ?<br>• តើនរណាម្នាក់អាចផ្តល់ទំនាក់ទំនងរវាងបញ្ហាទាំងនេះផ្សេងទៀត និងការប្រែប្រួលអាកាសធាតុបានទេ?<br>• តើមានផលប៉ះពាល់អ្វីខ្លះពីការប្រែប្រួលអាកាសធាតុជុំវិញពិភពលោក?<br>• តើផលប៉ះពាល់អ្វីខ្លះនៃបម្រែបម្រួលអាកាសធាតុនៅក្នុងសហគមន៍របស់យើង?<br>• តើផលប៉ះពាល់ទាំងនោះមានផលវិបាកអ្វីខ្លះ?<br>• តើមានរឿងអ្វីខ្លះដែលយើងអាចធ្វើ ដើម្បីត្រៀមខ្លួនសម្រាប់ផលប៉ះពាល់ទាំងនោះ?<br>(តម្រុយ៖ ចម្លើយសម្រាប់សំណួរទាំងអស់នេះមាននៅក្នុង CCRD ថ្នាក់ទី៤-៦ មេរៀនទី១-៤។)<br>**សកម្មភាពទី២ ៖ វីដេអូស្តីពីការប្រែប្រួលអាកាសធាតុ**<br>ជាជំនួយការចងចាំបន្ថែម សិស្សត្រូវចំណាយពេលដែលនៅសល់ក្នុងថ្នាក់មើលរឿងនេះ៖<br>https://www.youtube.com/watch?v=PacBrZUXNSE | ប្រយោជន៍ក្នុងនាមជាគ្រូបង្រៀន។ |

| | | | | |
|---|---|---|---|---|
| | | | ជាគំនិត គ្រូអាចបង្ហាញវានៅលើកុំព្យូទ័រ ហើយបញ្ចាំងតាមឧបករណ៍បញ្ចាំងស្លាយ។ ប្រសិនបើមិនអាចទេ ឲ្យសិស្សមើលលើស្មាតហ្វូន និងចែករំលែកឱ្យមិត្តភក្តិបានមើលផង ប្រសិនបើមិត្តភក្តិណាមិនមាន។<br><br>**កិច្ចការផ្ទះ** ៖ សិស្សស្វែងរកតាម YouTube សម្រាប់វីដេអូបម្រែបម្រួលអាកាសធាតុមូលដ្ឋានផ្សេងទៀតជាភាសាខ្មែរ។ ពួកគេត្រូវមើល  វីដេអូមួយយ៉ាងហោចណាស់ ៥នាទី ហើយសរសេរនៅក្នុងសៀវភៅកំណត់ត្រាដោយសង្ខេប។ គ្រូត្រូវប្រាកដថា សិស្សបានបញ្ចប់កិច្ចការរបស់ពួកគេនៅម៉ោងបន្ទាប់ ហើយចាត់ថ្នាក់ពួកគេឱ្យសមស្រប។ | |
| ១ | ២ | ២(៤) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ អានមេរៀនទី៧ ចំណុចរបត់ CCRD ថ្នាក់ទី៧-៩ ត្រៀមកុំ  ព្យូទ័រ និងឧបករណ៍បញ្ចាំងស្លាយ កំណត់រូបភាពចំនួន៥ដែលមាននៅក្នុងជំពូកមេរៀននេះ និងត្រៀមគូររូបលើក្ដារខៀន។<br>**សម្ភារៈ** ៖ កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ឬរូបភាពដែលព្រីនចេញជាសន្លឹក(បើគ្មានឧបករណ៍បញ្ចាំងស្លាយ)។<br><br>**សកម្មភាពទី១ ៖ ការផ្ដល់មតិយោបល់ និងចំណុចរបត់**<br>គ្រូត្រូវបង្រៀនចាប់ពីមេរៀនទី៧ក្នុងឯកសារ CCRD ។ ក្នុងរយៈពេល ១០នាទីម្ដង គ្រូត្រូវផ្អាកការបង្រៀន រួចសួរសំណួរ ៖<br>• តើអ្នកអាចផ្ដល់ឧទាហរណ៍ជាក់ស្ដែងនៃចំណុចរបត់បានឬទេ? (គម្រូ៖ ពេលដាក់គ្រឿងទេសមួយមុខទៀតថែមទៅក្នុងកាបូបកាបូបក៏រហែក។ ពេលដែលអ្នកដាកចេញពីបង្អួចតែបន្តិចអ្នកអាចដួលភ្លាម។ ពេលភ្លៀងធ្លាក់តែបន្តិចទៀតលើដំបូលដែលទ្រុឌទ្រោមធ្វើឱ្យវារលំ។ល។)<br>• តើយើងអាចធ្វើអ្វីបានខ្លះ ដើម្បីកាត់បន្ថយកំដៅក្នុងទីក្រុង?<br>• តើយើងអាចធ្វើអ្វីដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ?<br>• តើយើងអាចធ្វើអ្វីបានដើម្បីបញ្ឈប់ការរលាយដុំទឹកកកនៅតំបន់ប៉ូល?<br>• តើយើងអាចធ្វើអ្វីបានដើម្បីបន្ថយការរលាយទឹកកក?<br>• ចាប់តាំងពីអ្នកបានរៀនអំពីអាកាសធាតុពីមុនមក តើអ្នកអាចគិតពីចំណុចរបត់ផ្សេងទៀតបានទេ? (គម្រូ ៖ សំណួរនេះប្រហែលជាពិបាកឆ្លើយ ប៉ុន្តែសូមសាកល្បងឆ្លើយ។ ចំណុចរបត់ផ្សេងទៀតគឺ ផ្កាថ្មប្រែពណ៌ នៅពេលដែលមហា | **កិច្ចសហប្រតិបត្តិការ** ៖ សិស្សក្នុងក្រុមត្រូវធ្វើការជាមួយគ្នាដើម្បីធ្វើឱ្យប្រាកដថាល្បែងដំណើរការ។<br><br>**ការប្រាស្រ័យទាក់ទង** ៖ សិស្សនឹងធ្វើការលើបំណិនទំនាក់ទំនងរបស់ពួកគេ នៅដែលពេលពួកគេបង្ហាញការវាយតម្លៃអំពីវីដេអូដល់សិស្សទាំងអស់ក្នុងថ្នាក់។<br><br>**ការរិះគិតពិចារណា** ៖ ល្បែងចំណុចរបត់ជាធម្មតាត្រូវបាន ជំរុញឱ្យមានបំណិនរការដោះស្រាយបញ្ហា និងការរិះគិតពិចារណា។ |

| | | | | |
|---|---|---|---|---|
| | | | សមុទ្រក្ដៅពេក ឬមានជាតិអាស៊ីត ។ ខ្យល់ និងចរន្តទឹកអាច ផ្លាស់ប្ដូរប្រសិនបើផ្ទៃផែនដីឡើងកំដៅ។)<br><br>**សកម្មភាព២ ៖ ល្បែងអំពីចំណុចរបត់**<br>គ្រូចែកសិស្សជាក្រុមដែលមានសិស្ស ៤នាក់ក្នុង១ក្រុម និង ទាញយកល្បែងជាភាសាខ្មែរនេះចេញតាមរយៈតំណភ្ជាប់នេះ (https://www.amazon.ca/Tipping-Point-Climate-Change-Card/dp/B096H9GPP8/ref=sr_1_1?crid=FHF9KVR37AC&dchild=1&keywords=tipping+point+climate+change+game&qid=1623769229&s=toys&sprefix=tipping%2Ctoys%2C193&sr=1-1).<br>ប្រាប់សិស្សឱ្យអានការណែនាំពីរបៀបលេង នៅពេលពួកគេ យល់ការណែនាំហើយ សូមចាប់ផ្ដើមលេង។ សិស្សប្រហែលជា មិនអាចបញ្ចប់ល្បែងក្នុងម៉ោងរៀនបានទេ ប៉ុន្តែយ៉ាងហោចណាស់ សិស្សនឹងទទួលបានការយល់ដឹងអំពីអ្វីដែលជាគំនិត ដែលនឹង ពង្រឹងចំណុចរបត់ដល់ពួកគេ។<br><br>**កិច្ចការផ្ទះ** ៖ គ្រូប្រាប់សិស្សត្រួសៗថា នៅម៉ោងបន្ទាប់អ្នកនឹង និយាយអំពីការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ តាមរយៈ សកម្មភាពដែលយក GHGs ចេញពីខ្យល់ ឬយ៉ាងហោចណាស់ កាត់បន្ថយបរិមាណដែលវាបានកកើតឡើង។ ភារកិច្ចរបស់អ្នកគឺ ស្វែងរករឿង ឬវីដេអូតាមអ៊ីនធឺណិត ទូរទស្សន៍ វិទ្យុ ឬតាមសារ ព័ត៌មាន អំពីប្រធានបទនេះ មើលរឿង ឬអានខ្លឹមសារឱ្យយល់ ហើយត្រូវរៀបចំដើម្បីនិយាយរយៈពេល ២នាទី អំពីអ្វីដែលអ្នក បានមើល ឬអាននៅក្នុងម៉ោងរៀនបន្ទាប់។ | |
| ១ | ៣ | ២(៦) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ គ្រូត្រូវអានមេរៀនទី៨-ការផ្ដល់ពិន្ទុ ក្នុងCCRD ថ្នាក់ទី៧-៩ និងរៀបចំរូបភាពទាំងអស់ក្នុងកុំព្យូទ័រ ឬ ព្រីនចេញ(ប្រសិនបើគ្មានកុំព្យូទ័រ និងឧបករណ៍បញ្ចាំង) ។<br>**សម្ភារៈ** ៖ កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ឬ រូបភាពពីក្នុងឯកសារ យោង ឬប្រភពផ្សេងទៀត(បើមិនមានក្នុងកុំព្យូទ័រ) ក្ដារខៀន ហ្វឺត ដីស ។<br><br>**សកម្មភាពទី១ ៖ ការធ្វើបទបង្ហាញរបស់សិស្សអំពីការកាត់បន្ថយ**<br>ទុកពេល២នាទី ឱ្យសិស្សពាក់កណ្ដាលក្រោកឈរ ហើយ និយាយអំពីអ្វីដែលពួកគេបានអាន ឬមើលអំពីការបន្ធូរបន្ថយ | **ការដោះស្រាយបញ្ហា** ៖ តាមរយៈការស្វែងរក បញ្ហាក្នុងពិភពពិត និង កំណត់ដំណោះស្រាយ ពួកគេកំពុងគិតតាមរយៈ ការដោះស្រាយបញ្ហា។<br><br>**ការត្រិះរិះពិចារណា** ៖ តាមរយៈការកំណត់ បញ្ហាបរិស្ថាន ហើយ បន្ទាប់មកព្យាយាមស្វែង |

| | | | | |
|---|---|---|---|---|
| | | | និងអារម្មណ៍ចំពោះអត្ថបទ។ អាស្រ័យលើទំហំថ្នាក់ ពួកគេអាចមានពេលច្រើន ឬតិច ប៉ុន្តែកំណត់សកម្មភាពត្រឹមតែ ៤៥នាទី។<br>បន្ទាប់ពីបទបង្ហាញនីមួយៗចប់ គ្រូសួរសិស្សណាម្នាក់៖<br>• តើអ្នកចូលចិត្តអ្វីអំពីរបាយការណ៍របស់គាត់?<br>• តើអ្នកមិនយល់ស្របជាមួយអ្វីទេ? ហេតុអ្វី ឬហេតុអ្វីមិន?<br>• គ្រូអាចសួរបន្ថែមអំពីមូលហេតុដែលវាកាត់បន្ថយ ប្រសិនបើសិស្សអ្នកធ្វើបទបង្ហាញមិនទាន់បានពន្យល់។<br>វិធីនេះ សិស្សម្នាក់ៗទទួលបានមតិកែលម្អ និងសំណូមពរសម្រាប់ការកែលម្អ។<br>**សកម្មភាពទី២ ៖ ការបង្រៀនកាត់បន្ថយការប្រែប្រួលអាកាសធាតុ**<br>គ្រូចាត់ទុកឯកសារ CCRD មេរៀនទី៨ ជាប្រភពធនធានសម្ភារៈ ដោយសព្វថ្ងៃនេះ គេផ្តោតលើការបង្រៀនសម្ភារៈកាត់បន្ថយជាលក្ខណៈប្រព័ន្ធដែលបានកើតឡើង។ គ្រូនឹងពិនិត្យជម្រើសកាត់បន្ថយជាលក្ខណៈប្រព័ន្ធដែលបានកើតឡើង ដោយបង្ហាញតួលេខដែលត្រូវគ្នា។ ជាការល្អ គ្រូបង្រៀនគួរតែស្វែងរកព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះតាមអ៊ីនធឺណិត ព្រោះ CCRD មិនសុទ្ធតែចូលជ្រៅទៅក្នុងប្រធានបទនោះទេ។<br>បន្ទាប់ពីពណ៌នាអំពីជម្រើសនីមួយៗដោយយោងតាមសម្ភារៈនៅក្នុង CCRD គ្រូគួរតែជ្រើសរើសសិស្សថ្មីម្នាក់ដើម្បីសួរសំណួរនីមួយៗខាងក្រោម (សិស្សម្នាក់មួយសំណួរ ដូច្នេះសិស្សគ្រប់គ្នានឹងដល់វេនត្រូវនិយាយ ហើយសិស្សទាំងអស់ក៏ត្រូវបានលើកទឹកចិត្តឱ្យគិតពិចារណាដែរ)៖<br>• តើអ្នកធ្លាប់ឃើញជម្រើសនេះនៅក្នុងសាលា ឬសហគមន៍របស់យើងទេ? បើបាន នៅឯណា?<br>• តើកន្លែងណាខ្លះក្នុងប្រទេសកម្ពុជា ឬក្នុងពិភពលោកត្រូវការប្រើប្រាស់ជម្រើសនេះច្រើនជាងគេ? (លើកទឹកចិត្តពួកគេឱ្យគិតពិចារណា - ប្រសិនបើអ្នកនិយាយអំពីកាកសំណល់អាហារ ប្រហែលជាពួកគេត្រូវគិតអំពីប្រទេសអ្នកមាន និងខ្ជះខ្ជាយដូចជានៅអាមេរិក និងអឺរ៉ុប ប្រហែលជាពួកគេក៏អាចគិតអំពីកាកសំណល់ប្លាស្ទិកទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬអ្វីដែលត្រូវធ្វើជាមួយអាហាររលួយនៅទីសក្ការៈ ចុះបើការអភិវឌ្ឍខ្លាំងនៅកម្ពុជាវិញ? ទីក្រុងរីកចម្រើនលឿនជាងតម្រូវការ ហើយមានដីធម្មជាតិតិច?)<br>• ហេតុអ្វីបានជាមនុស្សមិនធ្វើរឿងទាំងនេះ? (តម្រុយ៖ មនុស្សបើកឡានជំនួសការជិះកង់ក្នុងចម្ងាយផ្លូវខ្លី ដោយសារ | រកដំណោះស្រាយ ពួកគេកំពុងកែលម្អបំណិននេះ។<br>**ការប្រាស្រ័យទាក់ទង ៖** តាមរយៈការបង្ហាញគំនិតរបស់ពួកគេ ពួកគេនឹងត្រូវរៀនទំនាក់ទំនងឱ្យបានច្បាស់លាស់។<br>**ស្វ័យគ្រប់គ្រង ៖** សិស្សនឹងទទួលខុសត្រូវក្នុងការគិតតាមរយៈការធ្វើបទបង្ហាញរបស់ពួកគេ ហើយស្ថិតក្នុងពេលវេលាកំណត់ ជាការបង្ហាញពីស្វ័យគ្រប់គ្រង។ |

ពួកគេចូលចិត្តម៉ាស៊ីនត្រជាក់ ឬដោយសារថយន្តជាសញ្ញាកម្រិតធនធាន ឬដោយសារតែពួកគេខ្ជិល។ មនុស្សមិនបិទភ្លើងដោយសារភ្លេច ឬមិនដឹងថាវាអាក្រក់ប៉ុណ្ណាសម្រាប់ភពផែនដី ឬជាអ្នកមានហើយអាចមានលទ្ធភាពបង់វិក្កយបត្រដូច្នេះហើយគេក៏ខ្ជិលខ្វល់។

**សកម្មភាពទី៣ ៖ ជំនាញធ្វើបទបង្ហាញ**

សិស្សបានផ្តល់បទបង្ហាញរួចហើយ ប៉ុន្តែគ្រូគួរតែណែនាំពីរបៀបធ្វើបទបង្ហាញឱ្យបានល្អដល់សិស្ស ដែលរួមមាន៖

- អត្ថបទមិនលើសពី ៦បន្ទាត់ក្នុងមួយស្លាយ
- ប្រើរូបភាពច្បាស់លាស់ដែលមុខ និងភ្នែករបស់មនុស្សអាចមើលឃើញ(ប្រសិនបើបង្ហាញមនុស្ស) ហើយមិនថតពីខាងក្រោយទេ។
- រូបភាពទាំងអស់ត្រូវតែច្បាស់
- ប្រើទម្រង់ផ្សេងៗគ្នាសម្រាប់ស្លាយរបស់អ្នក – ស្លាយខ្លះអាចគ្រាន់តែជារូបភាព ខ្លះអាចជាពាក្យ ខ្លះអាចជាសម្តីដកស្រង់ – រក្សាវាទុកជាចំណាប់អារម្មណ៍សម្រាប់ទស្សនិកជន
- ដឹងពីអ្វីដែលអ្នកចង់និយាយ ហើយកុំគ្រាន់តែអានស្លាយរបស់អ្នក។
- ចំណាយពេលមួយនាទី ឬតិចជាងនេះក្នុងមួយស្លាយ។ រក្សាអ្វីៗឱ្យមានចលនាដើម្បីកុំឱ្យមនុស្សធុញនឹងការសម្លឹងមើលស្លាយមួយយូរពេក
- និយាយឱ្យខ្លាំង និងច្បាស់ ប្រើអារម្មណ៍ និងទាក់ទាញទស្សនិកជនរបស់អ្នកដោយភាពរីករាយ។

សម្រាប់គ្រូត្រូវសួរដូចនេះ ៖

- តាមបទពិសោធន៍របស់អ្នក តើអ្នកអាចផ្តល់យោបល់លើជំនាញធ្វើបទបង្ហាញល្អផ្សេងទៀតបានទេ?
- នរណាម្នាក់អាចរៀបរាប់ពីរបៀបដែលពួកគេរៀបចំខ្លួនសម្រាប់ការធ្វើបទបង្ហាញ ឬការនិយាយណាមួយបានទេ? តើអ្នកត្រូវឆ្លងកាត់ជំហានអ្វីខ្លះ ដើម្បីត្រៀមខ្លួនទាំងផ្លូវកាយ និងផ្លូវចិត្ត?

ពន្យល់សិស្សថា ប្អូននឹងទទួលបន្ទុកបង្រៀនមិត្តភក្តិក្នុងថ្នាក់អំពីជម្រើសកាត់បន្ថយតាមលក្ខណ្ឌធម្មជាតិ និងជម្រើសកាត់បន្ថយបែបសិប្បនិម្មិត។ CCRD មេរៀនទី៨ មានព័ត៌មានលម្អិតអំពីប្រធានបទមួយចំនួន ប៉ុន្តែមិនមែនទាំងអស់នោះទេ ដូច្នេះពួកគេនឹងត្រូវស្វែងរកតាមអ៊ីនធឺណិតសម្រាប់ព័ត៌មានបន្ថែម។

<table>
<tr><td></td><td></td><td></td><td>អាស្រ័យលើទំហំនៃថ្នាក់ សូមបែងចែកក្រុមទៅជា ៣-៤ ហើយឱ្យពួកគេម្នាក់ៗធ្វើលើប្រធានបទណាមួយ (ឧទាហរណ៍ កសិកម្ម ការដាំដើមឈើ ការចាប់យកកាបូន ការចាប់យកមេតាន ការបរិភោគសាច់ ការធ្វើជីកំប៉ុស ជីវឧស្ម័ន ។ល។) ណែនាំសិស្សឱ្យរកមើលព័ត៌មានតាមអ៊ីនធឺណិតជាភាសាខ្មែរ ឬភាសាអង់គ្លេសផងដែរ(បើសិស្សអាចធ្វើបាន) ដើម្បីបំពេញបន្ថែម CCRD ។<br><br>កិច្ចការផ្ទះ ៖ សិស្សត្រូវបង្រៀននៅម៉ោងបន្ទាប់អំពីការកាត់បន្ថយតាម លក្ខណ្ឌធម្មជាតិ និងបច្ចេកវិទ្យាកាត់បន្ថយ។ សិស្សម្នាក់ៗនឹងត្រូវរៀបចំបទបង្ហាញ (ឬបើមិនអាចទៅរួចមែន ពួកគេនឹងត្រូវធ្វើគំនូរនៅលើក្រដាស់ផ្ទាំងធំ ដែលរៀបចំទុកជាមុន)។ បទបង្ហាញនី មួយៗគួរប្រើពេលប្រហែល១០នាទី ហើយសិស្សម្នាក់ៗគួរតែប្តូរ វេននិយាយ។ ជាការល្អ ម៉ោងសិក្សាស្ទើរទាំងអស់នឹងត្រូវចំណាយឱ្យសិស្សបង្រៀន។</td><td></td></tr>
<tr><td>១</td><td>៤</td><td>២(៨)</td><td>សកម្មភាពអាទិភាពរបស់គ្រូ ៖ សិក្សា CCRD មេរៀនទី ៨ ស្តីពីប្រព័ន្ធធម្មជាតិ និងការកាត់បន្ថយតាមបច្ចេកវិជ្ជា។ រកមើលសំណួរដែលមាននៅលើអ៊ីនធឺ ណិត។ ត្រៀមខ្លួនដើម្បីគាំទ្រសិស្សដោយជួយធ្វើការកែតម្រូវ និងសំណួរផ្សេងៗ។<br>សម្ភារៈ ៖ កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ឬក្តារខៀន ដីស ឬហ្វឺតក្រដាសផ្ទាំងធំ(បើគ្មានកុំព្យូទ័រ និងឧបករណ៍បញ្ចាំងស្លាយ) ប៉ុន្តែសំខាន់ត្រូវព្យាយាមរកកុំព្យូទ័រ និងឧបករណ៍បញ្ចាំងស្លាយ។<br><br>សកម្មភាពទី១ ៖ ការធ្វើបទបង្ហាញរបស់សិស្សអំពីការកាត់បន្ថយ<br>បន្ទាប់ពីការធ្វើបទបង្ហាញរបស់សិស្សនីមួយៗ សូមសួរទៅអ្នកធ្វើបទបង្ហាញ ក៏ដូចជាសិស្សដទៃទៀត។ ការណែនាំសំណួរដែលសមស្របគឺ៖<ul><li>តើយើងបានឃើញការកាត់បន្ថយបែបនេះនៅក្នុងសហគមន៍របស់យើងទេ? នៅកម្ពុជា? នៅកន្លែងផ្សេងទៀត?</li><li>តើទម្រង់នៃការកាត់បន្ថយនេះមានអ្វីខ្លះ? តើអ្នកមិនយល់អ្វី? (គម្រុយ៖ ព្យាយាមឆ្លើយ ឬសួរសិស្សផ្សេងទៀតឱ្យឆ្លើយ)</li><li>តើអ្នកគិតយ៉ាងណាចំពោះការរិះគន់លើទម្រង់នៃការបន្ធូរបន្ថយទាំងនេះ? តើអ្នកយល់ថាហេតុអ្វីបានជាវាអាចមានគ្រោះថ្នាក់ដោយពឹងផ្អែកលើដំណោះស្រាយតែមួយ?</li><li>តើអ្នកយល់ថាហេតុអ្វីបានជាយើងត្រូវធ្វើការលើជម្រើសជាច្រើនក្នុងពេលតែមួយ? ពន្យល់ពីមូលហេតុ?</li></ul></td><td>ការសម្រេចចិត្ត ៖ ចាប់តាំងពីពេលឱ្យសិស្សជ្រើសរើសបញ្ហាមួយក្នុងចំណោមបញ្ហាដែលពួកគេអាចរកឃើញ បំណិនធ្វើការសម្រេចចិត្តដោយផ្អែកលើហេតុផលដែលពួកគេបានបង្កើតនឹងត្រូវបានពង្រឹង។<br><br>ការដោះស្រាយបញ្ហា ៖ តាមរយៈការស្វែងរកបញ្ហាក្នុងពិភពពិត និងការកំណត់ដំណោះស្រាយ ពួកគេនឹងគិតពីរបៀបនៃការដោះស្រាយបញ្ហា។<br><br>ការរិះគិតពិចារណា ៖ តាមរយៈការកំណត់បញ្ហាបរិស្ថាន និងការព្យាយាមស្វែងរកដំណោះស្រាយ</td></tr>
</table>

| | | | | |
|---|---|---|---|---|
| | | | • តើសិស្សអាចធ្វើជម្រើសអ្វីខ្លះនៅទីនេះ? តើរដ្ឋាភិបាល ឬអាជីវកម្មត្រូវធ្វើជម្រើសអ្វីខ្លះ?<br>• តើប្រធានបទអ្វីដែលអ្នកចូលចិត្តជាងគេ? ហេតុអ្វី?<br>• តើបទបង្ហាញអ្វីដែលអ្នកចូលចិត្តជាងគេ? ហេតុអ្វី?<br>• តើអ្នកអាចដាក់ឈ្មោះអ្វីដែលល្អ និងអ្វីដែលមិនល្អអំពីបទបង្ហាញរបស់សិស្សនីមួយៗ ដើម្បីឱ្យយើងអាចរៀនពីរបៀបបង្កើនបំណិននិយាយ និងការធ្វើបទបង្ហាញបានទេ?<br><br>**សកម្មភាពទី២ ៖ បទបង្ហាញអ្នកជំនាញ**<br>គណៈគ្រប់គ្រងសាលា ស្វែងរកវាគ្មិនក្នុងតំបន់ដែលអាចនិយាយអំពីសកម្មភាពកាត់បន្ថយមួយ។ ប្រហែលជាមានមនុស្សនៅក្នុងសហគមន៍របស់អ្នកបានប្រើប្រាស់ជំណាំគម្រប ឬរហូតដល់បច្ចេកទេសកសិកម្ម ឬធ្វើគំនរជីកំប៉ុស។ ប្រហែលជាមានមនុស្សបានដំឡើង ឬប្រើប្រាស់បន្ទះស្រូបពន្លឺព្រះអាទិត្យ ឬប្រហែលជាមានមនុស្សបានចូលរួមក្នុងការដាំដើមឈើ។ ប្រសិនបើគ្មាននរណាម្នាក់នៅក្នុងមូលដ្ឋានទេ សុំការគាំទ្រពីក្រុមប្រឹក្សាឃុំ ដើម្បីទាក់ទងទៅមនុស្សដែលនៅក្នុង DMoE ឬ MoE ឬសាកលវិទ្យាល័យដែលអាចមកនិយាយអំពីការកាត់បន្ថយដល់សិស្ស។<br>សិស្សត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរនៅចុងបញ្ចប់នៃបទបង្ហាញ។ ប្រសិនបើសិស្សមិនសួរទេ គ្រូគួរតែរៀបចំសំណួរដែលសមស្របនឹងប្រធានបទដែលកំពុងពិភាក្សា។<br><br>**សកម្មភាពទី៣ ៖ ការឆ្លុះបញ្ចាំង**<br>ផ្តល់ពេល ៥នាទីដល់សិស្ស ដើម្បីសរសេរក្នុងកំណត់ត្រាឆ្លុះបញ្ចាំងរបស់ពួកគេអំពីអ្វីដែលពួកគេចូលចិត្ត និងមិនចូលចិត្តអំពីថ្នាក់ ក៏ដូចជាអារម្មណ៍ចំពោះលំហាត់ធ្វើបទបង្ហាញ។ ពិបាកទេ? ត្រឹមត្រូវទេ? ងាយស្រួលមែនទេ? តើពួកគេចង់ធ្វើអ្វីឱ្យបានល្អជាងនេះ? តើអ្វីខ្លះជាមោទនភាពបំផុតចំពោះក្រុមរបស់ពួកគេ? តើសិស្សមានអារម្មណ៍យ៉ាងណាចំពោះការសហការជាមួយក្រុមរបស់ខ្លួន? ពេលខ្លះមានការលំបាក តើអ្នកដោះស្រាយបញ្ហាដោយរបៀបណា?<br><br>**កិច្ចការផ្ទះ** ៖ សិស្សត្រូវរាប់បំណែកប្លាស្ទិកដែលពួកគេឃើញនៅតាមផ្លូវពីសាលាមកផ្ទះ។ កត់ត្រាវានៅក្នុងសៀវភៅកំណត់ត្រារបស់ពួកគេ រួមទាំងប្រភេទប្លាស្ទិកផងដែរ។ សិស្សនឹងរាយការណ៍នៅម៉ោងសិក្សាបន្ទាប់។ | សិស្សនឹងបង្កើនការកែលម្អបំណិននេះ។<br><br>**ការប្រាស្រ័យទាក់ទង** ៖ តាមរយៈការបង្ហាញគំនិតរបស់សិស្ស សិស្សនឹងត្រូវរៀនទំនាក់ទំនងឱ្យបានច្បាស់លាស់។ សិស្សក៏ត្រូវស្តាប់ និងរៀនពីអ្នកដទៃផងដែរ នៅពេលដែលមានការគេរិះគន់ពួកគេ។<br><br>**ភាពច្នៃប្រឌិត** ៖ សិស្សនឹងមានភាពច្នៃប្រឌិតនៅពេលដែលពួកគេត្រូវការធ្វើបទបង្ហាញសម្រាប់ការបង្រៀន ដោយប្រើគំនិតពីប្រភពជាច្រើន។ |

| | | | | |
|---|---|---|---|---|
| ២ | ៥ | ២(១០) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** សិក្សាមេរៀនទី៩ ក្នុង CCRD ។ រៀបចំរូបភាពដែលព្រីនចេញពីកុំព្យូទ័រ ឬជាការល្អ រៀបចំរូបភាពក្នុងកុំព្យូទ័រសម្រាប់បង្ហាញលើស្លាយ។ មេរៀននេះ និងមេរៀនបន្ទាប់និយាយអំពីនិរន្តរភាព ហើយមេរៀនសំខាន់មួយក្នុងនិរន្តរភាពគឺ ការប្រើប្រាស់ធនធានតិចតួច ពោលគឺគ្មានក្រដាស។<br>**សម្ភារៈ ៖** កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ផ្ទាំងគំនូរ និងឧបករណ៍សម្រាប់គូរ រូបភាពនៃផលប៉ះពាល់ដែលព្រីនចេញពីកុំព្យូទ័រ(បើគ្មានជម្រើសផ្សេងទៀត)។<br><br>**សកម្មភាពទី១ ៖ ការរស់នៅប្រកបដោយនិរន្តរភាព និងគោលការណ៍របស់វា**<br>លោកគ្រូពន្យល់ពីគោលការណ៍នៃការរស់នៅប្រកបដោយនិរន្តរភាពក្នុង CCRD ។ បង្ហាញតួរលេខនៃសសរស្តម្ភទាំងបី និងរបៀបដែលត្រួតលើគ្នា ហើយនិរន្តរភាពគឺនៅចន្លោះរវាងសសរស្តម្ភទាំងបី។ មុននឹងបន្តទៅផ្នែកបន្ទាប់ សូមឈប់ ហើយសួរសិស្សថា តើពួកគេមានគំនិតអំពីរបៀបរស់នៅប្រកបដោយនិរន្តរភាព (តម្រុយ៖ ចម្លើយគឺជាប្រភេទនៃសកម្មភាពដែលបានរៀបរាប់នៅក្នុងផ្នែកដែលមានចំណងជើងថា "តើត្រូវធ្វើអ្វីដើម្បីរស់នៅប្រកបដោយនិរន្តរភាព?" បើសិស្សផ្តល់ចម្លើយត្រឹមត្រូវ ឱ្យពួកគេ ឬសិស្សផ្សេងទៀត តើសិស្សអាចពន្យល់ពីហេតុអ្វីបានជាវាមាននិរន្តរភាព។<br>និយាយដោយសង្ខេបអំពីការសំចៃថាមពល និងទឹក កាកសំណល់អាហារ ការកែច្នៃឡើងវិញ និងផ្តោតលើមេរៀនដែលនៅសល់ស្តីពីការកាត់បន្ថយការប្រើប្រាស់ និងប្លាស្ទិក។ រំលឹកសិស្សនូវអ្វីដែលពួកគេគួររៀននៅថ្នាក់ទី៤-៦ថា ប្លាស្ទិកមិនទាក់ទងដោយផ្ទាល់ទៅនឹងការប្រែប្រួលអាកាសធាតុទេ ប៉ុន្តែការផលិតប្លាស្ទិកបង្កើតនូវ GHGs យ៉ាងច្រើន ហើយការដុត ឬការបំផ្លាញផ្លាស្ទិកក៏បញ្ចេញ GHGs ផងដែរ។ ដូច្នេះវាមានតំណភ្ជាប់ដោយប្រយោល។ ប៉ុន្តែសំខាន់ជាងនេះទៅទៀត ប្លាស្ទិកបំពុលបរិយាកាសតាមមធ្យោបាយជាច្រើន(សូមមើល CCRD ថ្នាក់ទី៤-៦ មេរៀនទី៤ ស្តីពីការបំពុលពីប្លាស្ទិក)។<br>សួរសំណួរដូចជា៖<br>• តើពួកគេអាចគិតពីពេលមួយដែលពួកគេខ្ជះខ្ជាយអាហារ ឬពេលដែលពួកគេឃើញសំណល់អាហារ? (តម្រុយ៖ អ្នករាល់គ្នាគួរតែឃើញអាហារលួយនៅទីសក្ការៈ ឬអាហារលួយក្នុងសម្រាម។ តើអាហារនេះទៅណា?) | **ការចូលរួម៖** សិស្សនឹងត្រូវធ្វើការជាមួយគ្នាស្មើៗគ្នាដើម្បីចាប់ផ្តើមបំពេញសន្លឹកសារពើភ័ណ្ឌរបស់ពួកគេ។<br><br>**ការគោរពចំពោះភាពចម្រុះ** នៅពេលដែលសិស្សបានឮរឿងរ៉ាវពីអ្នកជំនាញផ្នែកនិរន្តរភាព ពួកគេនឹងយល់ពីទស្សនៈផ្សេងៗគ្នាពីតំបន់ផ្សេងៗគ្នានៅក្នុងប្រទេស។<br><br>**ការយល់ចិត្ត៖** អ្នកជំនាញផ្នែកនិរន្តរភាពគួរតែអាចនិយាយទៅកាន់បញ្ហានៃភាពអយុត្តិធម៌ ប្រាក់ឈ្នួលមិនស្មើគ្នា និងការធ្វើឱ្យខូចបរិស្ថាន ជួយសិស្សឱ្យយល់ដល់មនុស្សផ្សេងទៀត និងបញ្ហាដែលមិនធ្លាប់ស្គាល់។<br><br>**ការគិតបែបរិះគន់ ៖** ការបំពេញសារពើភ័ណ្ឌនឹងបង្ខំសិស្សឱ្យគិតយ៉ាងលម្អិតអំពីថាមពល និងការប្រើប្រាស់កាកសំណល់នៅក្នុងផ្ទះរបស់ពួកគេ។ |

- តើពួកគេអាចគិតពីពេលមួយដែលពួកគេបានឃើញសំណល់ទឹកទេ? តើមានអ្វីកើតឡើង?
- តើពួកគេអាចគិតពីឧទាហរណ៍នៃសំណល់ថាមពលដែលពួកគេបានឃើញទេ? តើមានអ្វីកើតឡើង?
- តើពួកគេអាចនឹកឃើញពីអ្វីៗដែលបានរៀនស្តីពីអាហារ និងសំណល់ជីវម៉ាសផ្សេងទៀត តាំងពីដើមនៃមេរៀនបានទេ?
- តើមានអ្វីកើតឡើងនៅពេលដែលភោជនីយដ្ឋានធ្វើបាយច្រើនពេក? តើអ្នកបានឃើញរឿងនេះទេ? តើភោជនីយដ្ឋានអាចធ្វើអ្វីជំនួសឲ្យការបោះបាយចោលនៅតាមផ្លូវ?

បន្ទាប់ពីការរំលឹកអំពីទំនាក់ទំនងរវាងប្លាស្ទិច និង GHGs សួរសិស្សពីរទៅបីនាក់ថា៖

- តើអ្នកបានឃើញបំណែកប្លាស្ទិចប៉ុន្មាននៅតាមផ្លូវពីសាលាមកផ្ទះ។ តើវាទាំងនោះជាអ្វីខ្លះ?
- ហេតុអ្វីបានជាអ្នកគិតថាប្លាស្ទិកទាំងនោះនៅទីនោះ? តើយើងអាចធ្វើអ្វីបានដើម្បីផ្លាស់ប្តូរវា?
- តើអ្នកអាចប្រាប់យើងអំពីអ្វីដែលអ្នកបានឃើញ ដែលមានការវេចខ្ចប់ច្រើនពេកបានទេ? តើអ្វីជាដំណោះស្រាយ?

**សកម្មភាពទី២ ៖ អ្នកជំនាញផ្នែកនិរន្តរភាពក្នុងមូលដ្ឋាន**

អង្គការ UNICEF នឹងថតបទបង្ហាញរយៈពេល ១៥នាទី អំពីការងាររបស់ប្រជាជនកម្ពុជាមួយចំនួនលើវីដេអូនិរន្តរភាព។ ជ្រើសរើសការងារមួយដើម្បីបង្ហាញសិស្ស។

**សកម្មភាពទី៣ ៖ គំរូនៃការប្រើប្រាស់ប្លាស្ទិកនៅផ្ទះ**

សិស្សធ្វើបញ្ជីត្រួតពិនិត្យគំរូអំពីសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ។ សិស្សអាចធ្វើការងារនេះជាពីរក្រុម ប៉ុន្តែសិស្សម្នាក់ៗត្រូវតែធ្វើបញ្ជីផ្ទាល់ខ្លួនដោយឡែករៀងៗខ្លួន។

| ប្រភេទផ្សេងៗនៃផលិតផលដែលបានប្រើប្រាស់ | | | | | | |
|---|---|---|---|---|---|---|
| កាលបរិច្ឆេទនៃការទិញ | អាហារ និងភេសជ្ជៈ | របស់លេង | សៀវភៅ | ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ | សម្លៀកបំពាក់ | ផលិតផលថែរក្សាសម្រស់ |
| | ឧ- ប្លាស្ទិកដបភេសជ្ជៈ | ឧ - តុក្កតាជ័រ | | ឧ- ឧបករណ៍ប្រើប្រាស់ក្នុងបន្ទប់ទឹក | ឧ- អាវធ្វើពីជ័រប្លាស្ទិក | ឧ - ដបសាប៊ូ |

*(តារាងនេះមានបង្ហាញខាតជំនៅឧបសម្ព័ន្ធ១០)*

ឱ្យសិស្សធ្វើការជាដៃគូ ហើយបំពេញក្នុងសន្លឹកកិច្ចការនូវអ្វីៗទាំងអស់ដែលពួកគេគិតថា ផ្ទះរបស់ពួកគេមានក្នុងប្រភេទទាំងនេះ។ សិស្សប្រហែលជាមិនដឹងកាលបរិច្ឆេទនៃការទិញទេ ប៉ុន្តែគួរតែបំពេញវាដោយការប៉ាន់ស្មាន។ តាមរយៈការងាររួមគ្នា ពួកគេអាចជួយគ្នាគិតពីសម្ភារៈទាំងនេះ។ ពួកគួរតែដឹង និងចេះបង្កើតសន្លឹកកិច្ចការតម្រូវការប្រើប្រាស់។ ហើយសិស្សអាចធ្វើការជាដៃគូរលើការងារនេះម្តងទៀត។

| ផលិតផល? | តើយើងអាចរស់នៅដោយគ្មានវាបានឬទេ? | សម្ភារៈវេចខ្ចប់? | តើរបស់វេចខ្ចប់នឹងត្រូវបោះចោលដោយរបៀបណា? | តើផលិតផលនឹងត្រូវប្រើប្រាស់ ឬបោះចោល? | បើបោះចោល តើគួរចោលដោយរបៀបណា? | តើមានជម្រើសល្អជាងនេះទេ? តើវាជាអ្វី? | តើជម្រើសនោះសមស្របសម្រាប់គ្រួសាររបស់ខ្ញុំឬទេ? ហេតុអ្វីសមស្រប ឬហេតុអ្វីមិនសមស្រប? |
|---|---|---|---|---|---|---|---|
| ដបទឹក | បាទ | ប្លាស្ទិក | ចោលក្នុងធុងសំរាម | ប្រើប្រាស់ឡើងវិញ | | បាទ ម៉ាស៊ីនទឹក | ទេ យើងមិនអាចមានលទ្ធភាពទិញវាបានទេ។ |
| ឯកសណ្ឋានសាលា | ទេ | ប្លាស្ទិក | បោះចោលក្នុងធុងសំរាម | បោះចោល | ធុងសំរាមនៅពេលចាស់ពេកឬចង្អៀត | បាទ ឬចាស | ប្រែក្លាយអាវចាស់នោះទៅជាសិប្បកម្ម ឬវត្ថុដែលអាចប្រើបាន។ |
| ... | ... | ... | ... | ... | ... | ... | ... |

*(តារាងនេះមានបង្ហាញខ្នាតធំនៅឧបសម្ព័ន្ធ១០)*

ចុងបញ្ចប់ ឱ្យសិស្សបំពេញការពិនិត្យសំណល់ថាមពល។ ពួកគេប្រហែលជាមិនអាចបំពេញហើយអស់ និងទាន់ពេលទេ ប៉ុន្តែយ៉ាងហោចណាស់ គ្រូគួរទុកពេលដល់សិស្សឱ្យបានសមស្រប ដើម្បីបំពេញវាឱ្យបានចប់។ កិច្ចការផ្ទះរបស់ពួកគេគឺបញ្ចប់បញ្ជីត្រួតពិនិត្យទាំងបីនេះ បញ្ជីនេះត្រូវរាប់បញ្ចូលក្នុងឧបសម្ព័ន្ធ៩។ ប្រសិនបើវាស្មុគស្មាញក្នុងការគណនាពេក ត្រូវលុបជួរឈរចុងក្រោយ ហើយគ្រាន់តែឱ្យសិស្សបំពេញក្នុងជួរ A ដល់ F។

**កិច្ចការផ្ទះ** ៖ ឱ្យសិស្សបំពេញតារាងទាំងនេះ ដោយពួកគេបំពេញយ៉ាងហោចណាស់ ១០ជួរដេកសម្រាប់សម្ភារៈនីមួយៗ ឬច្រើនជាងនេះបើពួកគេចង់។ សិស្សនឹងត្រូវរាយការណ៍នៅម៉ោងសិក្សាបន្ទាប់អំពីសម្ភារៈដែលបានរកឃើញ ហើយសិស្សនឹងត្រូវបានចោទសួរ ដោយផ្តោតលើផលិតផលចំនួនបីដែលសិស្សគិតថាពិតជាអាចធ្វើការផ្លាស់ប្តូរ(ពោលគឺ សម្ភារៈដែលពួកគេពិតជាអាចរស់នៅដោយគ្មានវា ឬសម្ភារៈដែលពួកគេពិតជាត្រូវការ និងនឹងប្រើកាន់តែមានប្រសិទ្ធភាព)។

| | | | | |
|---|---|---|---|---|
| ២ | ៦ | ២(១២) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** សិក្សាមេរៀនទី៩ ក្នុងឯកសារ CCRD។ ព្រីនរូបភាពចេញពី កុំព្យូទ័រ ឬរៀបចំជា soft សម្រាប់បង្ហាញនៅលើឧបករណ៍បញ្ចាំងស្លាយ។ មេរៀននេះសិក្សាពីនិរន្តរភាព ហើយខ្លឹមសារសំខាន់ពីនិរន្តរភាពគឺ ការប្រើប្រាស់ធនធានតិចតួច ឬមិនចាំបាច់ប្រើក្រ   ដាស។ គ្រូត្រូវកំណត់កន្លែងទំនេរក្នុងតំបន់ដែលសិស្សអាចមើលស្គាល់។ កន្លែងទំនេរមួយគួរជាកន្លែងដែលគ្មានមនុស្សរស់នៅ ឬក៏ជាទីវាល។ វាអាចគ្រាន់តែជាតំបន់ដែលមានស្មៅ និងគ្មានព្រៃឈើ ហើយប្រហែលមានតែស្មៅទាបៗនៅទីនោះ ឬគ្មានតែម្តង។ គ្រូត្រូវយករូបភាពនៃកន្លែងទំនេរទាំងនោះទុកសម្រាប់បង្ហាញតាមឧបករណ៍បញ្ចាំងស្លាយ។ រូបភាពនៃសេសសល់ស្តង់ស្តីពីនិរន្តរភាពក៏ត្រូវត្រៀមសម្រាប់ការបង្ហាញផងដែរ។<br>**សម្ភារៈ ៖** កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ស្មាតហ្វូន គឺមានសារៈសំខាន់សម្រាប់មេរៀននេះ។ ប្រសិនបើសម្ភារៈណាមួយមិនមាននៅក្នុងថ្នាក់រៀន អាចខ្ចីពីគណៈគ្រប់គ្រងសាលារៀន។<br><br>**សកម្មភាពទី១ ៖ របាយការណ៍ស្តីអំពីសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ**<br>ឱ្យសិស្សនិយាយអំពីសម្ភារៈប្រើប្រាស់ក្នុងគ្រួសាររបស់ពួកគេម្នាក់ៗ(រៀបរាប់ដោយសង្ខេបនូវសម្ភារៈមួយចំនួនក្នុងបញ្ជីរបស់គេ) ហើយបន្ទាប់មកនិយាយអំពីផលិតផលចំនួនបីដែលពួកគេអាចធ្វើឱ្យមានភាពផ្លាស់ប្តូរខុសគ្នាខ្លាំង។ បើមានសិស្សច្រើនពេក គ្រូត្រូវកំណត់រយៈពេលត្រឹម ៤៥នាទី។ សំណួរដែលត្រូវសួរ៖<br>• ហេតុអ្វីបានជាអ្នកជ្រើសរើសផលិតផលទាំងបីនេះ?<br>• តើអ្នកគិតថាគ្រួសារ ឬឪពុកម្តាយរបស់អ្នកមានអារម្មណ៍យ៉ាងណាចំពោះការលុបបំបាត់ផលិតផលនេះ?<br>• តើអ្វីដែលអ្នកកំណត់ថាជាវត្ថុដែលអ្នកមិនអាចផ្លាស់ប្តូរបាន?<br>• ហេតុអ្វីបានជាមិនអាចផ្លាស់ប្តូរ? តើធនធានអ្វីខ្លះដែលអ្នកត្រូវការដើម្បីធ្វើការផ្លាស់ប្តូរ?<br>(<u>គម្រូ៖</u> សិស្សមិនអាចប្តូរទៅប្រើធុងទឹក ឬឧបករណ៍ចម្រោះទឹកទេ ដោយសារគ្រួសាររបស់ពួកគេក្រពេកគ្មានលទ្ធភាពទិញ។ សិស្សប្រហែលជាមិនអាចចៀសវាងការទិញផលិតផលល្អស្អាតដែលវេចខ្ចប់ដោយប្លាស្ទិកទេ ដោយសារពួកគេមិនដឹងថាត្រូវទៅរកនៅកន្លែងណាដែលផលិតផលវេចខ្ចប់ដោយរបស់ដែលអាចរលួយបាន ឬវាថ្លៃពេក) | **ការរិះគិតពិចារណា ៖** សិស្សអាចអភិវឌ្ឍបំណិនដោយធ្វើការកំណត់ពីបញ្ហាសំណល់ដែលមាននៅតាមផ្ទះ។<br><br>**ការប្រាស្រ័យទាក់ទង ៖** សិស្សអាចធ្វើបទបង្ហាញរបាយការណ៍ផ្ទាល់មាត់។ ធ្វើការអនុវត្តជាក់ស្តែងឱ្យបានត្រឹមត្រូវច្បាស់លាស់ និងចូលរួមសកម្មភាពទំនាក់ទំនង។<br><br>**ការច្នៃប្រឌិត ៖** ប្រើប្រាស់គំនិតអំពីដីទំនេរ សិស្សនឹងមានគំនិតច្នៃប្រឌិតក្នុងការប្រើប្រាស់ដីរបស់ពួកគេ។<br><br>**ការដោះស្រាយបញ្ហា ៖** ប្រើប្រាស់គំនិតអំពីដីទំនេរ សិស្សនឹងមានគំនិតដោះស្រាយបញ្ហាលើដីដែលប្រើប្រាស់តិចតួច។<br><br>**ការចូលរួម ៖** សិស្សនឹងយល់ថា ពួកគេទាំងអស់គ្នាត្រូវតែចូលរួមក្នុងផែនការស្តីពីនិរន្តរភាព ហើយទស្សនៈដែលប្រមូលបានធ្វើឱ្យផែនការរបស់ពួកកាន់តែរឹងមាំ។<br><br>**ការចរចា ៖** សិស្សនឹងមានគំនិតខុសៗគ្នាអំពីអ្វីដែលពួកគេធ្វើលើដីទំ |

<table>
<tr>
<td></td>
<td></td>
<td></td>
<td>
សកម្មភាពទី២ ៖ និរន្តរភាព និងអាកាសធាតុនៅលើទីវាលទំនេរ<br>
គ្រូពន្យល់ដោយសង្ខេបអំពីការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ននេះ ៖ ឧបមាថា សិស្សត្រូវបានផ្តល់កន្លែងសាធារណៈទំនេរមួយ។ តើសិស្សនឹងធ្វើអ្វីដើម្បីប្រើប្រាស់វាប្រកបដោយនិរន្តរភាព ដោយផ្អែកលើសសរស្តម្ភទាំងបីនៃនិរន្តរភាព។ គ្រូរំលឹកសិស្សអំពីសសរស្តម្ភ បន្ទាប់មក សិស្សបង្ហាញគំនិតរបស់ពួកគេ។ តាមរយៈស្លាយនៃរូបភាពនៅក្នុងឧបសម្ព័ន្ធទី៤ អំពីការប្រើប្រាស់កន្លែងទំនេរ ។ អ្នកមិនចាំបាច់ពន្យល់ឱ្យអស់នោះទេ គ្រាន់តែប្រាប់សិស្សដោយសង្ខេបអំពីរូបភាពដែលសិស្សកំពុងមើល។ នាំសិស្សទៅកន្លែងទីវាល ហើយបែងចែកសិស្សជាក្រុមមិនលើសពី ១០នាក់។ ចាត់សិស្សមើលការខុសត្រូវតាមក្រុម និងសមាជិកក្រុមទទួលភារកិច្ចរៀងៗខ្លួន ខណៈដែលគ្រូគ្រប់គ្រងរួម។ ក្រុមនីមួយៗត្រូវមានក្រដាស និងប៊ិកសម្រាប់កត់ត្រា។<br>
សំណួរអាចមានដូចខាងក្រោម៖
<ul>
<li>ពិពណ៌នាអំពីអ្វីដែលអ្នកឃើញនៅទីនេះ តើមានអ្វីនៅលើដី (ដើមឈើ? ស្មៅ? សំរាម? សត្វ? ដីទទេ? សំណល់អាហារ? របស់ផ្សេងទៀត?)</li>
<li>ឧបមាថា ឥឡូវនេះយើងចង់អភិវឌ្ឍដីនេះទៅជាអ្វីមួយដែលជួយសហគមន៍របស់យើងកាន់តែមាននិរន្តរភាព ឬត្រៀមខ្លួនជាមុនដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ តើយើងអាចធ្វើអ្វីបានជាមួយនឹងដីនេះ?(គ្មានចម្លើយណាខុសទេ ប៉ុន្តែសង្ឃឹមថា សិស្សនឹងគិតដល់រឿងដូចជា៖ ដាំរុក្ខជាតិ ធ្វើសួនច្បារ សិក្សាប្រភេទរុក្ខជាតិដែលត្រូវដាំ ប្រើប្រាស់សំណល់ប្លាស្ទិកដើម្បីបង្កើតវត្ថុសិល្បៈ សាងសង់កន្លែងសម្រាប់លំហែកាយ ឬសួនកម្សាន្ត ដោយប្រើប្រាស់សំណល់ដែលអាចកែច្នៃ។ រៀបចំទីផ្សារពិព័រណ៍ផលិតផលសម្រាប់សមាជិកសហគមន៍លក់ផលិតផលសិប្បកម្ម និងកសិកម្ម។ បង្កើតកន្លែងហាត់ប្រាណ បង្កើតមជ្ឈមណ្ឌលអប់រំសហគមន៍ សាងសង់លំនៅដ្ឋានសុវត្ថិភាពសម្រាប់ជនក្រីក្រ។ល។ គ្រូបំផុសគំនិតបែបនេះ ប្រសិនបើសិស្សគ្មានការគិតដោយខ្លួនឯង។)</li>
<li>ក្នុងចំណោមគំនិតទាំងអស់ដែលយើងបានបំផុស តើគំនិតមួយណាដែលអ្នកគិតថាសហគមន៍ត្រូវការច្រើនជាងគេ? ហេតុអ្វី?</li>
<li>ក្នុងចំណោមគំនិតទាំងអស់ដែលយើងបានបំផុស តើអ្នកគិតថាគំនិតមួយណាដែលអាចអនុវត្តបានច្រើនបំផុត? ហេតុអ្វី?</li>
</ul>
</td>
<td>នេះ។ សិស្សនឹងត្រូវចរចាជាមួយគ្នាដើម្បីសម្រេចបាននូវដំណោះស្រាយល្អបំផុត ឬជាដំណោះស្រាយរួម។</td>
</tr>
</table>

| | | | | |
|---|---|---|---|---|
| | | | សិស្សគប្បីទាញយករូបភាពដែលទាក់ទងនឹងមេរៀន នៅលើស្មាតហ្វូនរបស់ពួកគេឱ្យបានច្រើនសន្លឹក។ រូបភាពនេះជាផ្នែកមួយនៃការតាំងពិព័រណ៍របស់ពួកគេនៅចុងបញ្ចប់នៃឆមាស។<br><br>**សកម្មភាពទី៣៖ ការធ្វើផែនការនិរន្តរភាព**<br>សិស្សអាចត្រឡប់ទៅថ្នាក់រៀនវិញបាន។ គ្រូអាចប្រើសំណួរ៖<br>• តើភាគីពាក់ព័ន្ធណាខ្លះដែលយើងត្រូវពិភាក្សាដើម្បីអភិវឌ្ឍដីនេះ? តើយើងគួរនិយាយជាមួយពួកគេយ៉ាងដូចម្តេច? (តម្រុយ៖ និយាយជាមួយគណៈកម្មការសម្របសម្រួលអប់រំ និងក្រុមប្រឹក្សាឃុំ។ ពួកគេគួរតែដឹងថាអ្នកណាជាម្ចាស់ដី បន្ទាប់មកអ្នកត្រូវនិយាយជាមួយម្ចាស់ដី ហើយបញ្ចុះបញ្ចូលពួកគេឱ្យបង្កើតវាទៅតាមគំនិតកែច្នៃណាមួយ។ អ្នកក៏នឹងត្រូវនិយាយទៅកាន់អ្នកប្រើប្រាស់ដ៏មានសក្តានុពលផងដែរ វាអាស្រ័យលើគំនិតដែលយើងបានគិត។)<br>• តើផែនការរបស់អ្នកនឹងគាំទ្រដល់តម្រូវការរបស់សហគមន៍ក្នុងពេលបច្ចុប្បន្ន និងអនាគតយ៉ាងដូចម្តេច?<br>• តើវានឹងលើកកម្ពស់សេដ្ឋកិច្ច បរិស្ថាន និងសង្គមដូចម្តេច?<br><br>**កិច្ចការផ្ទះ៖** ៖ ប្រាប់សិស្សថា ម៉ោងសិក្សាបន្ទាប់នឹងផ្តោតលើនិរន្តរភាពជាវិជ្ជមាន ឬការងារស្តីពីអាកាសធាតុសម្រាប់សហគមន៍របស់យើង។ គិតអំពីអ្វីដែលអ្នកនឹងធ្វើដើម្បីឱ្យសហគមន៍យល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការរស់នៅប្រកបដោយនិរន្តរភាព ឬរៀបចំឱ្យពួកគេយល់ពីគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ? តើអ្នកនឹងប្រើបច្ចេកទេសអ្វីខ្លះ? តើអ្នកចង់ប្រាប់រឿងអ្វី? អ្នកអាចគិតអំពីដីទំនេរ ប៉ុន្តែអ្នកក៏ត្រូវគិតអំពីអ្វីគ្រប់យ៉ាងដែលអ្នកបានរៀនពេញមួយឆមាស និងអ្វីដែលអ្នកយល់ថាជារឿងសំខាន់បំផុតដែលត្រូវធ្វើ និងមូលហេតុ។ សិស្សត្រូវសរសេរយ៉ាងហោចណាស់ពីរទំព័រនៃការបំផុសគំនិត បន្ទាប់មកអ្នកនឹងប្រើវាដើម្បីពិភាក្សា និងរៀបចំផែនការសម្រាប់នៅម៉ោងសិក្សាបន្ទាប់។ | |
| ២ | ៧ | ២(១៤) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ គ្រូសិក្សាមេរៀនទី១០ ក្នុងឯកសារ CCRD។ ការបង្រៀនត្រូវផ្តោតជាពិសេសនូវអ្វីដែលយុវជនបានធ្វើនៅជុំវិញពិភពលោក។<br>**សម្ភារៈ** ៖ កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ ក្តារខៀន ដីស ឬហ្វឺត។ រូបភាពនៃសកម្មភាពយកចេញពី CCRD។ | **ការគោរពភាពចម្រុះ** ៖ តាមរយៈការសង្កេតមើល និងសិក្សាអំពីប្រជាជនកម្ពុជា និងកុមារដទៃទៀតលើចំណេះដឹងអំពីបម្រែបម្រួលអាកាស |

| | | | | |
|---|---|---|---|---|
| | | | **សកម្មភាពទី១ ៖ សកម្មភាពស្តីពីអាកាសធាតុនៅកម្ពុជា**<br>គ្រូចាប់ផ្តើមចូលទៅជំហានទី១ នៃមេរៀនទី១០ អំពីសកម្មភាពស្តីពីអាកាសធាតុកម្ពុជា ការកាត់បន្ថយ និងការបន្សាំ។ គ្រូត្រូវពណ៌នាអំពីការជួយគាំទ្រពីរដ្ឋាភិបាល ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិផ្សេងៗផងដែរ។<br>គ្រូសួរថា ៖<br>• តើអ្នកធ្លាប់បានឃើញនិមិត្តសញ្ញារបស់ស្ថាប័នណាមួយទេ? បើមែន តើអ្នកដឹងទេថាស្ថាប័ននោះកំពុងធ្វើអ្វី?<br>• តើអ្នក ឬមិត្តភ័ក្តិ ឬគ្រួសាររបស់អ្នកធ្លាប់ធ្វើការជាមួយ ឬនិយាយជាមួយស្ថាប័នទាំងនោះដែរឬទេ?<br>• តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះមនុស្សដែលកំពុងធ្វើការអំពីសកម្មភាពអាកាសធាតុនៅក្នុងប្រទេសកម្ពុជា? តើអ្នកសប្បាយចិត្តទេដែលពួកគេធ្វើបែបនេះ? ឬអ្នកគិតថាវាជាការខាតពេលវេលា?<br>• តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះជនបរទេស ឬអង្គការអន្តរជាតិនានាក្នុងប្រទេសកម្ពុជា? តើអ្នកសប្បាយចិត្តដែលពួកគេបានជួយ ឬអ្នកចង់ឱ្យពួកគេចាកចេញ? ហេតុអ្វី?<br>• តើអ្នកធ្លាប់បានឃើញគម្រោង ឬសកម្មភាពទាំងនេះនៅក្នុងសហគមន៍របស់យើងឬទេ?<br>• តើអ្នកធ្លាប់ចូលរួមសកម្មភាពបែបនេះឬទេ? ពេលណា? តើអ្នកបានធ្វើអ្វី? តើអ្នកចូលចិត្តដែរឬអត់? ហេតុអ្វី?<br>• តើអ្នកចង់ឱ្យមានសកម្មភាពបែបនេះនៅក្នុងសហគមន៍របស់យើងដែរឬទេ?<br><br>**សកម្មភាពទី២៖ វីដេអូគំនូរជីវចលស្តីពីអាកាសធាតុ**<br>គ្រូនិយាយអំពីការប្រែប្រួលអាកាសធាតុ និងគំនូរជីវចលស្តីអំពីអាកាសធាតុក្នុងមេរៀនទី១០ នៃ CCRD។ អានខ្លឹមសារ នៃសេចក្តីប្រកាសសកម្មភាពអាកាសធាតុយុវជនសកល ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៩ ពីឧបសម្ព័ន្ធ CCRD។ បង្ហាញរូបភាពសកម្មជនទាក់ទងនឹងអាកាសធាតុ។<br>គ្រូត្រូវបង្ហាញសកម្មភាពដោយប្រើស្លាយតាមតំណនេះ ៖<br>https://weshare.unicef.org/CS.aspx? VP3=SearchResult&ALID=2AMZIFHQQXXP (សកម្មភាពរបស់ UNICEF បកប្រែជាខ្មែរ)<br>បន្ទាប់មក សូមបង្ហាញវីដេអូខ្លីៗចំនួនពីរខាងក្រោម៖<br>https://www.unicef.org/eap/childutopia-story-5-youths- | ធាតុ សិស្សនឹងយល់អំពីសមត្ថភាព និងទស្សនៈផ្សេងៗគ្នា។<br><br>**ការច្នៃប្រឌិត** ៖ សិស្សនឹងមានភាពច្នៃប្រឌិតនៅពេលពួកគេបំផុសគំនិតពីសកម្មភាពនានា។<br><br>**ការចរចា** ៖ សិស្ស និងគ្រូនឹងធ្វើការចរចាគ្នា ដោយគ្រូជាអ្នកដឹកនាំសិស្សដើម្បីធ្វើសកម្មភាពចំនួន៥។ ប្រសិនបើសកម្មភាពទាំងនេះមានច្រើនពេក ពួកគេអាចបន្ថយចំនួនដើម្បីចរចា ។<br><br>**ការសម្រេចចិត្ត** ៖ សិស្សនឹងត្រូវធ្វើការសម្រេចចិត្តអំពីភាពខ្លាំង និងគោលដៅជីវិតរបស់ពួកគេ ហើយឯកភាពក្នុងការធ្វើសកម្មភាពណាមួយ។<br><br>**ការចូលរួម** ៖<br>សិស្សានុសិស្សគួរស្វែងយល់អំពីការចូលរួមសម្រាប់សកម្មភាពបម្រែបម្រួលអាកាសធាតុដែលអាចធ្វើខុសគ្នាៗ និងធ្វើឱ្យពួកគេក្លាយជាផ្នែកនៃសហគមន៍ពិភពលោកមួយ។ |

| | | | | |
|---|---|---|---|---|
| | | | and-1-dream-city ( សកម្មភាពរបស់ UNICEF បង្កើតវីដេអូឯកសារជាភាសាខ្មែរ ) https://weshare.unicef.org/archive/15759-Philippines-Fridays-for-Future-Mitzi-YT-2AMZIFB3M6LT.html ( សកម្មភាពរបស់ UNICEF បង្កើតវីដេអូឯកសារជាភាសាខ្មែរ )<br><br>**សកម្មភាពទី៣ ៖ តើអ្នកគួរធ្វើអ្វី ?**<br>គ្រូពន្យល់សិស្ស អំពីគម្រោងក្នុងឆមាសនេះគឺទាក់ទងនឹងខ្លឹមសារពីរគឺ ការរស់នៅប្រកបដោយនិរន្តរភាព និងសកម្មភាពដើម្បីអាកាសធាតុ។ ចុងក្រោយ គ្រូឱ្យសិស្សធ្វើរឿងប្រាំយ៉ាង៖<br>១-យុទ្ធនាការអប់រំអំពីការរស់នៅប្រកបដោយនិរន្តរភាពជាពិសេសអំពីការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការសន្សំសំចៃថាមពលនិងទឹក ការកាត់បន្ថយការទុកដីទំនេរចោល ការប្រើប្រាស់ដីដោយឈ្លាសវៃ ការធ្វើជីកំប៉ុសឬការប្រើប្រាស់ជីវម៉ាស់ឬការកែច្នៃកាកសំណល់អាហារ<br>២-ផលិតវីដេអូអំពីការប្រែប្រួលអាកាសធាតុ ឬការរស់នៅប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍របស់ពួកគេ<br>៣-ការសរសេររឿងផ្ទាល់ខ្លួនអំពីអាកាសធាតុ និងនិរន្តរភាព<br>៤-ការបង្កើតសិល្បៈចេញពីសំរាមជាមធ្យោបាយមួយដើម្បីកែលម្អ សោភណភាពសហគមន៍របស់ពួកគេ និង<br>៥-ធ្វើជាគ្រូបង្រៀនសម្រាប់សហគមន៍របស់ពួកគេ។ គោលបំណងរបស់គ្រូគឺ ចង់ឱ្យសិស្សបង្កើតគំនិតជាមុនសិន បន្ទាប់មកណែនាំពួកគេឱ្យធ្វើសកម្មភាពតាមគោលដៅ។ គ្រូត្រូវសរសេរគំនិតនៅលើក្តារខៀន។ គ្រូប្រាប់សិស្សឱ្យគិតដោយយោងលើកិច្ចការផ្ទះនៅម៉ោងសិក្សាពីសប្តាហ៍មុន ប៉ុន្តែក៏គិតអំពីអ្វីដែលពួកគេបានរៀនថ្ងៃនេះផងដែរ។<br>គ្រូសួរសំណួរ៖<br>• គិតឡើងវិញអំពីអ្វីៗដែលយើងបានរៀនអំពីការរស់នៅប្រកបដោយនិរន្តរភាព និងសកម្មភាពអាកាសធាតុ។ តើអ្វីដែលអ្នករកឃើញថាជាចំណុចចាប់អារម្មណ៍បំផុត ? ហេតុអ្វី ?<br>• តើអ្វីដែលអ្នករកឃើញថាចាប់អារម្មណ៍តិចតួច ? ហេតុអ្វី ?<br>• តើការរស់នៅប្រកបដោយនិរន្តរភាពប្រភេទណាខ្លះដែលអ្នកបានឃើញ ហើយកំពុងអនុវត្តនៅក្នុងសហគមន៍របស់យើង ?<br>• តើអ្នកឃើញអ្វីជាបញ្ហាចម្បងបំផុតដែលទាក់ទងនឹងការរស់នៅប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍របស់យើង ? | |

| | | | | |
|---|---|---|---|---|
| | | | • ក្នុងនាមជាសិស្ស តើអ្នកគិតថា អ្នកមានលទ្ធភាពធ្វើអ្វីបានខ្លះ? មិនអាចធ្វើអ្វីបានខ្លះ?<br>• តើមានសំណល់អាហារ និងជីវម៉ាសប្រភេទណាខ្លះ ដែលមាននៅក្នុងសហគមន៍? តើនៅកន្លែងណាច្រើនជាងគេ?<br>• តើយើងអាចធ្វើដូចម្តេចដើម្បីជូនដំណឹងដល់សហគមន៍អំពីបញ្ហាសំណល់អាហារ និងអត្ថប្រយោជន៍នៃការធ្វើជីកំប៉ុស្ត?<br>• តើយើងអាចធ្វើដូចម្តេចដើម្បីជូនដំណឹងដល់សហគមន៍អំពីអត្ថប្រយោជន៍ និងសារៈសំខាន់នៃការរស់នៅប្រកបដោយនិរន្តរភាព?<br>• តើការសន្យាមួយណាដែលអ្នកអាចធ្វើបានក្នុងជីវិតរបស់អ្នកទាក់ទងនឹងការរស់នៅប្រកបដោយនិរន្តរភាព? (ឧទាហរណ៍៖ យកកញ្ចប់កាកសំណល់ទៅជាមួយ ហើយមិនផឹកទឹកដែលច្រកក្នុងដបប្លាស្ទិកតូចៗ)។<br><br>**កិច្ចការផ្ទះ ៖** សិស្សត្រូវសរសេរមួយឬពីរទំព័រអំពីរបៀបដែលពួកគេនឹងធ្វើសកម្មភាពដែលបានជ្រើសរើស(អ្នកដែលពួកគេនឹងនិយាយជាមួយជំហានដែលពួកគេនឹងចាប់ផ្តើមដំណើរការ និងការបញ្ចប់)។ គំនិតទាំងនេះនឹងត្រូវបានកែលម្អនៅម៉ោងសិក្សាបន្ទាប់។ | |
| **ជំ.២. ការប្រមូលព័ត៌មាន** | | | **គោលបំណង ៖** ប្រមូលព័ត៌មានពីសហគមន៍ដើម្បីឱ្យសិស្សស្វែងយល់អំពីសហគមន៍ និងឥរិយាបថអំពីប្រធានបទដែលបានជ្រើសរើស។ | |
| ២ | ៨ | ២(១៦) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** គ្រូត្រូវមើលតាមអ៊ីនធឺណិត ដើម្បីស្វែងរកឧទាហរណ៍ និង វីដេអូគំនូរជីវចលអំពីអាកាសធាតុក្នុងប្រទេសកម្ពុជា។ រកមើលនៅលើ google.kh ឬពិនិត្យមើលវីដេអូខ្មែរលើ Youtube។ មានការណែនាំមួយចំនួនខាងក្រោម៖ គ្រូអាចស្វែងរកអ្នកជំនាញក្នុងតំបន់ ឬថ្នាក់ជាតិ ផ្នែកទីផ្សារ និងធ្វើការទំនាក់ទំនង។ អ្នកទាំងនេះអាចដឹងពីរបៀបផ្សាយពាណិជ្ជកម្ម ឬផ្លាស់ប្តូរឥរិយាបថ។ វាអាចជាអ្នកផ្សព្វផ្សាយព័ត៌មានក្នុងស្រុក ឬម្ចាស់ភោជនីយដ្ឋានក្នុងស្រុកដែលត្រូវផ្សាយពាណិជ្ជកម្មអាជីវកម្មរបស់ពួកគេ ឬគិលានុបដ្ឋាយិកាដែលធ្វើការក្នុងសហគមន៍អំពីការលាងដៃ ឬកូវីដ។ មានឧទាហរណ៍ជាច្រើនទៀត ប្រសិនបើអ្នកមិនអាចស្វែងរកនរណាម្នាក់នៅក្នុងមូលដ្ឋានបានទេ ស្នើនាយកសាលារបស់អ្នកទាក់ទងទៅអង្គការយូនីសេហ្វសម្រាប់ជំនួយគាំទ្រ។<br>**សម្ភារៈ ៖** កុំព្យូទ័រ ឧបករណ៍បញ្ចាំង ក្តារខៀន និងដីស ហ្វឺត។ | **ការប្រាស្រ័យទាក់ទង ៖** នេះគឺជាបំណិនចម្បងដែលសិស្សត្រូវរៀនពេញមួយឆមាស។ សិស្សនឹងរៀនពីរបៀបប្រាស្រ័យទាក់ទងផ្សេងៗគ្នា និងសារៈសំខាន់នៃរបៀបប្រាស្រ័យទាក់ទងនីមួយៗដើម្បីសម្រេចបានគោលដៅចុងក្រោយ។<br><br>**ការចូលរួម ៖** ការចូលរួមក្នុងសកម្មភាពទាំងនេះ និងការធ្វើឱ្យប្រសើរ |

**សកម្មភាពទី១ ៖ បង្កើតវីដេអូ និងសុំការគាំទ្រសម្រាប់យុទ្ធនាការ**

វីដេអូគឺជាមធ្យោបាយទំនាក់ទំនងដ៏សំខាន់ និងមានឥទ្ធិពលខ្លាំងក្នុងទំនាក់ទំនង។ វីដេអូមានដូចជា ការផ្សាយពាណិជ្ជកម្ម ភាពយន្តឯកសារ ការសម្ភាស រឿងតុក្កតា ភាពយន្តខ្លី។ ទូរស័ព្ទក៏អាចថត កាត់តឈុតខ្លីៗ ឬអាចបញ្ចូលគ្នាជាខ្សែភាពយន្តបាន។

វីដេអូដែលល្អតែងមានការរៀបចំមួយដែលល្អជាមុន។ សាច់រឿងត្រូវរៀបចំផែនការ និងសរសេរជាមុនសិន កត់ចំណាំថាកន្លែងណាត្រូវថត និងថតរឿងអ្វី ហើយពេលថតគ្រប់ផ្នែកនោះ វីដេអូត្រូវតែបានកែសម្រួលជាមួយគ្នា។

ពន្យល់សិស្សពីគម្រោងនៃឆមាសរបស់ពួកគេ ដើម្បីសុំការគាំទ្រធ្វើយុទ្ធនាការក្នុងសហគមន៍របស់ពួកគេ។ យុទ្ធនាការនេះត្រូវតែមានឧបករណ៍ផ្សេងៗគ្នាជាច្រើន។  ពួកគេត្រូវតែបង្កើតវីដេអូ ធ្វើស្លាកសញ្ញា និងផូស្ទ័រ ហើយត្រូវសរសេររឿង ប៉ុន្តែពួកគេក៏អាចធ្វើក្បួនដង្ហែរ កម្មវិធីវិទ្យុ ឬអ្វីៗផ្សេងទៀតដែលពួកគេគិតថាអាចធ្វើបាន និងជំនាញដែលពួកគេមាន។

វីដេអូរបស់ពួកគេនឹងត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់អង្គការយូនីសេហ្វ(UNICEF)។ វាក៏នឹងត្រូវបានដាក់នៅលើ YouTube សម្រាប់ពិភពលោកបានឃើញផងដែរ។ រឿងរ៉ាវរបស់ពួកគេនឹងត្រូវបានដាក់ចូលក្នុងសៀវភៅដោយអង្គការយូនីសេហ្វ ឬក្រសួងអប់រំ ហើយចែករំលែកទៅកាន់សាលាផ្សេងទៀត ដូច្នេះនៅឆ្នាំក្រោយសិស្សនៅក្នុងសហគមន៍ផ្សេងៗអាចរៀនពីពួកគេ។ ពួកគេមានឱកាសធ្វើជាគ្រូបង្រៀន និងធ្វើការផ្លាស់ប្តូរ។

បង្ហាញឧទាហរណ៍នៃវីដេអូគំនូរជីវចលស្តីពីអាកាសធាតុនេះ (ប៉ុន្តែគ្រូក៏អាចរកវីដេអូផ្សេងទៀតនៅលើអ៊ីនធឺណិត)

https://www.youtube.com/watch?v=uOa5zem4504

ឧទាហរណ៍ វីដេអូនិទានរឿងផ្សេងទៀត(ទោះបីជាមិនបង្កើតដោយកុមារក៏ដោយ)រួមមាន:

- https://www.youtube.com/watch?v=oBAt90X8VME
  ផែនដីជាកន្លែងដាក់មនុស្សចាស់
- https://www.youtube.com/watch?v=DfFK27CT2nM
  ការអប់រំឱ្យក្លាយជាកសិករវៃឆ្លាតស្តីពីអាកាសធាតុ
- https://www.youtube.com/watch?v=dwaO0r8WV9k
  បញ្ហាប្លាស្ទិកនៅកម្ពុជា

ឡើងនូវភាពជាម្ចាស់ការ ធ្វើឱ្យលទ្ធផលគម្រោងកាន់តែជោគជ័យ។

**កិច្ចសហប្រតិបត្តិការ ៖** បំណិននេះគួរតែសង្កត់ធ្ងន់អំពីរបៀបដែលសិស្សត្រូវសហការ ដើម្បីប្រាស្រ័យទាក់ទងជាមួយសហគមន៍ និងគោលដៅកែលម្អសហគមន៍។

**ស្វ័យគ្រប់គ្រង ៖** សិស្សត្រូវបានលើកទឹកចិត្តឱ្យគិតពីបំណិនដែលពួកគេមាន ហើយបន្ទាប់មកធ្វើការនៅក្នុងគម្រោងរបស់ពួកគេទៅតាមភាពខ្លាំងរបស់ពួកគេ។

**ការច្នៃប្រឌិត ៖** ការបំផុសគំនិតដើម្បីរៀបចំកម្រងសំណួរនឹងតម្រូវឱ្យមានភាពច្នៃប្រឌិត។

**សកម្មភាពទី២ ៖ ការធ្វើបទបង្ហាញរបស់អ្នកជំនាញទីផ្សារ ឬ ការផ្លាស់ប្តូរឥរិយាបថ**

ប្រសិនបើវាគ្មិនមិនសូវពូកែទេ សិស្សអាចសួរសំណួរដូចជា៖

- តើឥរិយាបថអ្វីដែលអ្នកព្យាយាមផ្លាស់ប្តូរ? ឬ តើសកម្មភាពអ្វីដែលអ្នកព្យាយាមបង្ហាញ?
- តើអ្វីជាសារដំបូងរបស់អ្នក? តើអ្នកបានគាំទ្រសារទាំងនោះឬទេ?
- តើអ្នកបាននិយាយទៅកាន់នរណា? តើនរណាជាគោលដៅសំខាន់បំផុត?
- តើនរណាបានជួយអ្នក? តើគេបានជួយអ្វីខ្លះ?
- តើអ្នកបានទំនាក់ទំនង ឬផ្សព្វផ្សាយនៅឯណា? តើអ្នកបានប្រើឧបករណ៍អ្វីខ្លះ?
- អ្វីដែលអ្នកធ្វើតើមានប្រសិទ្ធភាពឬទេ? តើអ្នកសង្កេតឃើញមានការផ្លាស់ប្តូរ ឬការលក់ផលិតផលរបស់អ្នកឬទេ?
- តើអ្នកវាស់កម្រិតប្រសិទ្ធភាពដោយរបៀបណា? តើអ្នកកំណត់ជាលេខឬ? តើអ្នកចាំអង្កេតវានៅពេលក្រោយឬ? តើអ្នកគ្រាន់តែមានអារម្មណ៍ថាជាការប្រសើរហើយឬ?

**សកម្មភាពទី៣ ៖ ការធ្វើផែនការសម្រាប់យុទ្ធនាការសុំការគាំទ្រ**

គ្រូពន្យល់ឱ្យសិស្សក្នុងថ្នាក់រៀបចំផែនការសម្រាប់ធ្វើសកម្មភាពសុំការគាំទ្រ។ សិស្សត្រូវធ្វើការងារជាក្រុមដែលមានសមាជិកប្រហែល៥នាក់ ដោយធ្វើសកម្មភាពតាមផ្នែកខុសៗគ្នា។ បែងចែកសិស្សធ្វើសកម្មភាពតាមផ្នែកដូចខាងក្រោម(ប៉ុន្តែត្រូវផ្តល់ឱកាសឱ្យសិស្សមានយោបល់ និងពិចារណាប្រសិនបើអាច)៖

- វីដេអូ(ត្រូវការអ្នកសរសេរសាច់រឿង, អ្នកអត្ថាធិប្បាយ, អ្នកថតកាត់ត, អ្នកសម្តែង, និងរៀនប្រើប្រាស់កម្មវិធី YouCut)។
- ផូស្ទ័រ និងខិតបណ្ណសម្រាប់សហគមន៍។
- សៀវភៅរឿងនិទាន រឿងផ្ទាល់ខ្លួន និងរឿងរ៉ាវក្នុងសហគមន៍។
- វគ្គបង្រៀន និងរៀនក្នុងឆមាស។
- ការតាំងពិព័រណ៍រូបភាព ពិព័រណ៍រូបថតអំពីការអនុវត្តដែលមាននិរន្តរភាព និងការមិនមាននិរន្តរភាព រូបភាពនៃការប្រើប្រាស់ដីទំនេរ បញ្ចាំងវីដេអូអំពីបម្រែបម្រួលអាកាសធាតុ អានអត្ថបទរឿងរបស់សិស្ស បញ្ចាំងវីដេអូរបស់សិស្ស រូបភាពផលិតពីសំរាមប្លាស្ទិក ក្រដាស។

សិស្សអាចបំពេញតារាងខាងក្រោម(គូរលើក្តារខៀន)៖ សិស្សត្រូវជ្រើសរើសនូវសកម្មភាពពីរដែលពួកគេចង់ធ្វើបំផុត។ ប្រសិន

បើមានសិស្សច្រើនចាប់អារម្មណ៍លើប្រធានបទដូចគ្នា ត្រូវធ្វើការពិភាក្សាគ្នាដើម្បីឱ្យមានចំនួនសមស្របតាមក្រុមនីមួយៗ។ ក្រុមសិស្សនីមួយៗត្រូវធ្វើការរៀបចំពិព័រណ៍ ក្រុមទទួលខុសត្រូវត្រួតពិនិត្យ ក្រុមរៀបចំធ្វើផូស្ទ័រ វីដេអូ និងក្រុមសរសេរសាច់រឿង។

| សកម្មភាពអ្វី? | នៅកន្លែងណា? | ដោយរបៀបណា/សម្ភារៈអ្វីខ្លះ? | នរណាដែលត្រូវចូលរួម? |
|---|---|---|---|
| | | | |
| | | | |
| | | | |

ដើម្បីចង់ដឹងពីអ្វីដែលជាតម្រូវការចាំបាច់សម្រាប់សហគមន៍ និងបានត្រៀមខ្លួនរួចរាល់ សិស្សទាំងអស់ត្រូវចុះទៅធ្វើការសម្ភាសក្នុងសហគមន៍។

**ការរៀបចំកម្រងសំណួរ**

ដោយប្រើប្រាស់ឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋាន គ្រូជួយសិស្សក្នុងការរៀបចំកម្រងសំណួរ។ ការរៀបចំសំណួរផ្អែកលើសិស្ស និងគ្រូ ប៉ុន្តែត្រូវមានគោលដៅ៤ ៖

- ត្រូវវាយតម្លៃពីកម្រិតយល់ដឹងរបស់សហគមន៍អំពីការកាត់បន្ថយផលប៉ះពាល់ និងការរស់នៅប្រកបដោយនិរន្តរភាព។
- ត្រូវដឹងថាតើអ្វីជាគំនិតនៃការរស់នៅប្រកបដោយនិរន្តរភាពរបស់ពួកគាត់។
- រកឱ្យឃើញពីគំនិតផ្សេងទៀត ដែលពួកគាត់អាចធ្វើឱ្យសហគមន៍របស់ពួកគាត់មាននិរន្តរភាព។
- មើលថាតើពួកគាត់គិតអំពីកន្លែងណា របៀបណា និងជាមួយអ្នកណាដែលទាក់ទងនឹងផែនការដើមរបស់អ្នក។

គ្រូជួយសិស្សរៀបចំកម្រងសំណួរសម្រាប់សម្ភាសមនុស្សពេញវ័យនៅក្នុងសហគមន៍។ នៅក្នុងក្រុមដូចគ្នា ដែលមានចំនួន៣នាក់ មាន១២សំណួរដែលក្រុមនីមួយៗនឹងត្រូវសួរ។ ក្រុមទាំងអស់នឹងសួរសំណួរដូចគ្នា ដោយគ្រាន់តែពួកគេត្រូវជួបសហគមន៍ផ្សេងៗគ្នា ដូច្នេះក្រុមពួកគេមានទំហំប៉ុនគ្នា។ នោះមានន័យថាប្រសិនបើអ្នកមានសិស្សចំនួន៤០នាក់ នៅក្នុងមួយថ្នាក់ ហើយអ្នកបែងចែកពួកគេមួយក្រុម ៣នាក់ នោះអ្នកនឹងមាន១៣ក្រុមដែលអាចសម្ភាសន៍មនុស្ស ៧នាក់ ក្នុងមួយពេលដែលបានបែងចែកនោះ អ្នកនឹងទទួលបាន៩១ចម្លើយ។ បើអ្នកចង់ទទួលបានចម្លើយ១០០ សូមបែងចែកក្រុមឱ្យតូចជាងមុន។ រំលឹកសិស្សឱ្យ

គ្រប់គ្រងពេលវេលាក្នុងការសម្ភាស។

១៣ x ៧ = ៩១ ការឆ្លើយតប

គ្រូនឹងត្រូវកែសម្រួលចំនួនគោលដៅសម្ភាសច្រើន ឬតិចអាស្រ័យលើទំហំនៃសហគមន៍នីមួយៗ។

អាស្រ័យលើសិស្សថាតើពួកគេបាន ឬមិនបានសិក្សាប្រធានបទបម្រែបម្រួលអាកាសធាតុពីថ្នាក់មុនរួចហើយ សំណួរអាចផ្លាស់ប្តូរ(ប្រសិនបើពួកគេបានរៀនអំពីបម្រែបម្រួលអាកាសធាតុនៅឆ្នាំមុន សហគមន៍ក៏ត្រូវបានសួរសំណួរមួយចំនួនរួចហើយ សំណួរអាចត្រូវ លុបចោល ឬកែសម្រួលដើម្បីសម្ភាសក្នុងសហគមន៍។ សំណួរមានដូចជា៖

- តើអ្នកដឹងទេថា អ្វីទៅជាការប្រែប្រួលអាកាសធាតុ ហើយវាបណ្តាលមកពីអ្វី?
- តើអ្នកបានកត់សម្គាល់ឃើញថាមានគ្រោះរាំងស្ងួត រលកកំដៅ ឬទឹកជំនន់ក្នុងរយៈពេលដប់ម្ភៃឆ្នាំកន្លងមកដែរឬទេ?
- តើអ្នកដឹងថាអ្វីជាការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ?
- តើធ្លាប់មានការដាំដើមឈើនៅតំបន់នេះឬទេ?
- តើអ្នកធ្លាប់ឮពីគោលការណ៍នៃការរស់នៅប្រកបដោយនិរន្តរភាពឬទេ? តើវាជាអ្វី?
- តើអ្នកធ្លាប់ឃើញកាកសំណល់ប្លាស្ទិកកកស្ទះច្រើនក្នុងប្រឡាយ លូបង្ហូរទឹកដែរឬទេ?
- តើអ្នកប្រើប្លាស្ទិកច្រើនដែរឬទេ? មានអ្វីខ្លះ?
- តើអ្នកបោះចោលប្លាស្ទិកច្រើនឬទេ? តើអ្នកដឹងថាមានអ្វីកើតឡើងនៅពេលអ្នកដុត ឬបោះវាចោល? តើអ្នកធ្លាប់គិតអំពីសំណល់ឬទេ? តើវានឹងមានអ្វីកើតឡើង?
- តើអ្នកធ្លាប់អត់មានទឹកប្រើឬទេ?
- តើវាពិបាកក្នុងការរក្សាផ្ទះ/ កន្លែងអាជីវកម្មរបស់អ្នកឱ្យមានអាកាសធាតុត្រជាក់ដែរឬទេ?
- តើវិក្កយបត្រភ្លើង ឬទឹករបស់អ្នកថ្លៃពេកឬទេ?
- តើអ្នកធ្វើអ្វីជាមួយកាកសំណល់អាហារ ប្រសិនបើមាន? តើអ្នកធ្វើអ្វីជាមួយកាកសំណល់កសិកម្ម ឬសំរាមក្នុងសួនច្បារ?
- យើងនឹងរៀបចំផែនការធ្វើយុទ្ធនាការនេះដើម្បីជួយសហគមន៍របស់យើងជាមួយនឹងការរស់នៅប្រកបដោយនិរន្តរភាព តើអ្នកគិតយ៉ាងណាដែរចំពោះគំនិតទាំងនេះ? តើគំនិតមួយណាគេចូលចិត្តជាង? ហេតុអ្វី?
- (ប្រសិនបើពួកគេចូលចិត្តគំនិតណាមួយ)៖ តើអ្នកគិតថាគំនិតមួយណាសំខាន់ជាងគេ? ហេតុអ្វី? តើយើងត្រូវនិយាយ

ជាមួយអ្នកណាដើម្បីសុំជំនួយ? តើអ្នកចង់ជួយឬទេ?

- (ប្រសិនបើពួកគេមិនចូលចិត្តគំនិតទាំងនោះ)៖ តើអ្នកមានគំនិតអ្វីផ្សេងទៀត? តើយើងគួរធ្វើវានៅឯណា? ហេតុអ្វីបានជាយើងគួរធ្វើដូច្នេះ? តើយើងអាចទទួលជំនួយជាសម្ភារៈ និងការងារពីនរណា?
- តើអ្នកចង់ស្វែងយល់បន្ថែមអំពីអ្វីខ្លះ?
- តើអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយមួយណា?(វិទ្យុ ទូរទស្សន៍ ហ្វេសប៊ុក TikTok អនឡាញ ឬកាសែតសារព័ត៌មាន។ល។)

ទាំងនេះគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ គ្រូត្រូវជួយសិស្សរៀបចំសំណួរដែលសមស្របសម្រាប់សហគមន៍របស់ពួកគេ។ គោលដៅគឺដើម្បីចង់ដឹងពីអ្វីដែលសហគមន៍របស់អ្នកដឹង ដូច្នេះសិស្សនឹងរៀនពីរបៀបវិភាគជំនឿរបស់សហគមន៍ និងរៀបចំកម្រងសំណួរប្រកបដោយប្រសិទ្ធភាព។

សិស្សគួររៀបចំជាតារាងដាក់ក្នុងសៀវភៅកត់ត្រារបស់ពួកគេ។ ពន្យល់សិស្សថា ការអង្កេតស្រាវជ្រាវនេះ អ្នកនឹងទទួលបានព័ត៌មានស្មុគស្មាញជាងអ្វីដែលអ្នកបានរៀនកាលពីឆ្នាំកន្លងទៅ។ នេះដោយសារតែឆ្នាំនេះ អ្នកនឹងព្យាយាមស្វែងយល់ពីអ្នកចូលរួមរបស់ពួកគេយ៉ាងពិតប្រាកដ ដូច្នេះអ្នកត្រូវតែទទួលបានព័ត៌មានប្រជាសាស្ត្រពីអ្នកចូលរួម ហើយសិស្សអាចរៀបចំកម្រងសំណួរតាមគោលដៅដែលនឹងជួយដល់ពួកគេបាន។

| គោលដៅ សម្ភាស | សំណួរ ទី១ | សំណួរ ទី២ | សំណួរ ទី៣ | សំណួរ ទី៤ | សំណួរ ទី៥ | សំណួរ ទី៦ |
|---|---|---|---|---|---|---|
| ភេទ ........<br>អាយុ ........<br>មុខរបរ .....<br>ចំនួនកូន ...<br>ការអប់រំ .... | ចម្លើយ សំណួរ ទី១ | ចម្លើយ សំណួរ ទី២ | ... | | | |
| ភេទ ........<br>អាយុ ........<br>មុខរបរ .....<br>ចំនួនកូន ...<br>ការអប់រំ .... | | | | | | |

**កិច្ចការផ្ទះ ៖** មើលពីកសិកម្មវៃឆ្លាតខាងអាកាសធាតុនៅកម្ពុជា ៖ https:// www.youtube.com/watch?v=Jsxet829B-U សារៈសំខាន់នៃការគ្រប់គ្រងការបំពុល ៖ https:// www.youtube.com/watch?v=A1kekS1xbAs ។ ធ្វើកំណត់ត្រាអំពីអ្វី

| | | | | |
|---|---|---|---|---|
| | | | ដែលអ្នកបានឃើញពីការនិទានរឿងនៅក្នុងវីដេអូទាំងនេះ អំពីអ្វីដែលអ្នកចូលចិត្ត និងអំពីអ្វីដែលអ្នកមិនចូលចិត្ត។ | |
| ៣ | ៩ | ២(១៨) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** រកអ្នកដែលអាចមើលការខុសត្រូវដើម្បីដឹកនាំសិស្សទៅធ្វើការសម្ភាសប្រមូលព័ត៌មានក្នុងសហគមន៍ប្រសិនបើចាំបាច់។ ប្រសិនបើសិស្សមានអាយុគ្រប់គ្រាន់អាចម្ចាស់ការខ្លួនឯងបានគ្រូមិនចាំបាច់រកមនុស្សនាំសិស្សទេ។ សូមធ្វើការទំនាក់ទំនងទៅនាយកសាលា គណៈកម្មាធិការសម្របសម្រួលការអប់រំ និងក្រុមប្រឹក្សាឃុំ ដើម្បីធានាថាសមាជិកសហគមន៍ត្រៀមខ្លួនទទួលសិស្ស។<br>**សម្ភារៈ ៖** កុំព្យូទ័រ និងឧករណ៍បញ្ចាំងស្លាយ ក្ដារខៀន ហ្វឺត ឬជីសផែនការស្រាវជ្រាវ។<br><br>**សកម្មភាពទី១ ៖ ការហាត់សមសម្ភាសន៍**<br>គ្រូណែនាំសិស្សឱ្យធ្វើការហាត់សមសម្ភាសន៍។ ឱ្យសិស្សមួយចំនួនសម្ដែងធ្វើជាអ្នកស្រួលនិយាយជាមួយ សិស្សខ្លះសម្ដែងជាអ្នកប្រកែកមិនឆ្លើយ សិស្សខ្លះទៀតសម្ដែងជាអ្នកយកចិត្តទុកដាក់ស្ដាប់ប៉ុន្តែស្ងៀមស្ងាត់ ហើយសិស្សខ្លះធ្វើជាអ្នកនិយាយច្រើន។ ពន្យល់សិស្សឱ្យយល់អំពីឥរិយាបថទាំងអស់ដែលពួកគេត្រូវសម្ដែង ហើយផ្ដល់គន្លឹះឱ្យសិស្សសម្រាប់ដោះស្រាយជាមួយនឹងឥរិយាទាំងនេះ (សួរសំណួរតាមរបៀបផ្សេងៗគ្នា ផ្ដល់យោបល់សម្រាប់ចម្លើយ ប្ដូរទៅសំណួរមួយទៀត សួរថា តើពួកគេមានសំណួរផ្សេងដែលពួកគេចង់ឆ្លើយ សួរសំណួរដដែលម្ដងទៀតប្រសិនបើពួកគេមិនបានទទួលចម្លើយ ព្យាយាមនិយាយកាត់ដោយគួរសម ហើយសួរសំណួរឡើងវិញ ប្រសិនបើមនុស្សនោះនិយាយច្រើនពេក)។ ប្រសិនបើសិស្សធ្លាប់ធ្វើកិច្ចការនេះពីមុនមក ពេលនេះសិស្សអាចគូសផែនទីកន្លែងដែលសិស្សនឹងទៅធ្វើការសម្ភាស។ បង្កើតផែនទីដូចខាងក្រោមហើយកំណត់ "ទីកន្លែង" សម្រាប់សម្ភាស។<br> | **ការចូលរួម ៖** ការចូលរួមក្នុងការធ្វើសកម្មភាព ការធ្វើផែនការ និងការហាត់សម នឹងជួយពង្រឹងពួកគេអំពីបំណិនការចូលរួម។<br><br>**ការប្រាស្រ័យទាក់ទង ៖** សិស្សត្រូវរៀននិយាយឱ្យបានច្បាស់លាស់ និងមានចំណេះដឹងល្អតាមរយៈការប្រាស្រ័យទាក់ទងពាក្យសំដី កាយវិការរបស់ពួកគេទៅកាន់មនុស្សពេញវ័យ។ ពួកគេក៏នឹងត្រូវរៀនទំនាក់ទំនងប្រកបដោយវិចារណញ្ញាណ និងមានភាពក្លាហានគ្រប់គ្រាន់ក្នុងការបង្វែរការសន្ទនាដែលកំពុងខុសប្រធានបទ។<br><br>**ការគោរពពហុភាព និងការយល់ចិត្ត ៖** សិស្សនឹងសម្ភាសមនុស្សច្រើនប្រភេទ ដើម្បីទទួលបានការយល់ដឹងអំពីទស្សនៈ និងតម្រូវការសហគមន៍ទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ និងនិរន្តរភាព។ សិស្សគួរតែដឹងថា អ្នកក្រ មនុស្សចាស់ ឬជនពិការមានតម្រូវការ |

| | | | | |
|---|---|---|---|---|
| | | | **សកម្មភាពទី២ ៖ ការសម្ភាសប្រមូលព័ត៌មាន**<br>ឱ្យសិស្សចុះប្រមូលព័ត៌មាននៅក្នុងសហគមន៍។ រំលឹកពួកគេឱ្យចេះគ្រប់គ្រងពេលវេលាឱ្យបានល្អ ប្រសិនបើអ្នកផ្តល់ចម្លើយនិយាយច្រើនពេក ត្រូវនិយាយកាត់ដោយការគួរសម ពន្យល់ពួកគាត់ថា យើងខ្ញុំត្រូវបន្តការសម្ភាសជាមួយអ្នកផ្សេងទៀត ។ នៅចុងបញ្ចប់នៃម៉ោងរៀន ត្រូវប្រាកដថាសិស្សគ្រប់គ្នារាយការណ៍មកដោយសង្ខេប ហើយគ្រូពន្យល់អំពីកិច្ចការផ្ទះដល់សិស្ស។<br><br>**កិច្ចការផ្ទះ ៖** សិស្សត្រូវសង្ខេបចម្លើយសម្ភាសន៍របស់ពួកគេ។ សិស្សត្រូវធ្វើការសរុបចម្លើយរបស់ពួកគេឱ្យបានស្អាតល្អនៅក្នុងតារាងមួយ។ កិច្ចការនេះ ពួកគេអាចធ្វើដោយខ្លួនឯងក៏បាន ឬជាក្រុមក៏បាន។ ក្នុងតារាង ពួកគេគួរតែមានសំណួរ ចម្លើយ និងប្រភេទមនុស្សដែលពួកគេសម្ភាស (ភេទ/អាយុ/ការងារ/កម្រិតនៃការអប់រំ/នៅជនបទ ឬនៅទីក្រុង /ឪពុកម្ដាយសិស្ស។ល។)។ កិច្ចការនីមួយៗគួរមានអនុសាសន៍សម្រាប់អ្វីដែលពួកគេគិតថាជាយុទ្ធនាការគួរតែផ្តោតលើ ព្រមទាំងមូលហេតុរបស់វា។ | ពិសេស និងបន្ទាន់ថែមទៀតយ៉ាងដូចម្ដេច? |
| **ជំ.៣. ការវិភាគព័ត៌មាន** | | | **គោលបំណង ៖** វិភាគព័ត៌មានដើម្បីកំណត់ការយល់ដឹង និងការយកចិត្តទុកដាក់អំពីបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វានៅក្នុងសហគមន៍។ ជួយសិស្សរកដំណោះស្រាយដោយប្រើវិធីសាស្ត្រដោះស្រាយបញ្ហា។ | |
| ៣ | ១០ | ២(២០) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** គ្រូត្រូវកំណត់អត្តសញ្ញាណឪពុកម្ដាយ ឬគ្រូផ្សេងទៀតដែលអាចមើលការខុសត្រូវសម្រាប់ដំណើរការអង្កេតស្រាវជ្រាវរបស់សិស្ស។ ក្នុងដំណើរសម្ភាស គ្រូត្រូវរៀបចំការសម្ភាសជាមួយសមាជិកក្រុមប្រឹក្សាឃុំឱ្យបានពីរឬបីនាក់។ គ្រូធ្វើទំនាក់ទំនងជាមួយគ្រូផ្សេងទៀត និងសុំជំនួយសម្រាប់ការផ្សព្វផ្សាយសារដែលសិស្សនឹងធ្វើការអង្កេតស្រាវជ្រាវ។<br>**សម្ភារៈ ៖** សៀវភៅកត់ត្រា ក្ដារខៀន ហ្វឺត ឬដីស ប៊ិក បន្ទាត់។<br><br>**សកម្មភាពទី១ ៖ ការឆ្លុះបញ្ចាំងលើការសម្ភាស**<br>ប្រើផូស្ទ័រស្វ័យរង្វាយតម្លៃដើម្បីណែនាំអំពីការឆ្លុះបញ្ចាំងលើបទសម្ភាសអំពីចំណេះដឹងតាមមូលដ្ឋាន។ ជ្រើសរើសសំណួរខាងក្រោម ឬសំណួរផ្សេងទៀតដែលអ្នកគិតថាមានសារៈសំខាន់?<br>• នៅពេលដែលអ្នកសួរសំណួរ តើវាពិបាកក្នុងការទទួលបានចម្លើយល្អដែរឬទេ?<br>• តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីទទួលចម្លើយបានកាន់តែល្អ?<br>• តើលទ្ធផលយ៉ាងម៉េចដែរ? | **ការប្រាស្រ័យទាក់ទង ៖** សិស្សត្រូវតែមានការប្រាស្រ័យទាក់ទងឱ្យបានច្បាស់ៗ និងក្លាហាន ជាមួយសមាជិកសហគមន៍ដើម្បីប្រមូលព័ត៌មាន។<br><br>**កិច្ចសហប្រតិបត្តិការ ៖** សិស្សនឹងរៀនសហការជាមួយសិស្សដទៃទៀត នៅពេលពួកគេបែងចែកភារកិច្ចសម្ភាសន៍។<br><br>**ការច្នៃប្រឌិត ៖** សិស្សត្រូវមានភាពច្នៃប្រឌិតក្នុងការទាញយកព័ត៌មានពីសមាជិកសហគមន៍ណា |

- តើវាពិបាកក្នុងការធ្វើការងារជាក្រុមឬទេ ?
- តើអ្នកធ្លាប់មានអារម្មណ៍ថាគេមិនចង់ឱ្យសម្ភាសដែរឬទេ ?
- តើវាធ្វើឱ្យអ្នកមានអារម្មណ៍បែបណា ?
- តើសំណួរមួយណាដែលអ្នកគិតថាពិបាកក្នុងការទទួលបានចម្លើយល្អ ?
- តើអ្នកបានធ្វើអ្វីដើម្បីជម្នះបញ្ហា ?
- ឥឡូវនេះ តើអ្នកគិតថាអ្នកបានរៀនអ្វីថ្មីពីការសម្ភាសឬទេ ?
- តើអ្នកបានជួយការងារក្រុមឬទេ ?
- តើសមាជិកក្រុមបានស្ដាប់អ្នកឬទេ ?
- តើអ្នករៀនបានអ្វីខ្លះពីការសម្ភាសកន្លងមក ដែលបានជួយអ្នកនៅពេលនេះ ?

**សកម្មភាពទី២ ៖ វិភាគទិន្នន័យដែលប្រមូលបាន**

*ការណែនាំ ៖* គ្រូបង្ហាញសំណួរទាំងអស់ដែលសិស្សបានសួរក្នុងតារាង ហើយបំពេញចម្លើយដែលក្រុមនីមួយៗទទួលបាន (តារាងខាងក្រោម)

| សំណួរ | ចម្លើយក្រុមទី១ | អ្នកផ្ដល់ចម្លើយ | ចម្លើយក្រុមទី២ | អ្នកផ្ដល់ចម្លើយ | ... |
|---|---|---|---|---|---|
| សំណួរទី ១ | | | | | |
| សំណួរទី ២ | | | | | |
| សំណួរទី ៣ | | | | | |
| ... | | | | | |

គ្រូពន្យល់ថា ឥឡូវនេះយើងនឹងប្រៀបធៀបចម្លើយដែលក្រុមនីមួយៗទទួលបាន។ យើងក៏ត្រូវប្រៀបធៀបព័ត៌មានរវាងអ្នកផ្ដល់បទសម្ភាសតាមសំណួរផងដែរ និងមើលថាតើយើងអាចឃើញលំនាំនៅក្នុងការឆ្លើយតបដែរឬទេ។ គ្រូគូរក្រាហ្វដូចខាងក្រោម៖




គ្រូសម្របសម្រួល ណែនាំសិស្សក្នុងការសួរសំណួរ និងផ្ដល់យោបល់៖

ដែលពិបាកក្នុងការសាកសួរ ឬទើសទាល់ក្នុងការផ្ដល់ព័ត៌មាន។

**ការចូលរួម ៖** សិស្សទាំងអស់ត្រូវចូលរួមក្នុងការសម្ភាស ដើម្បីរៀនពីរបៀបប្រាស្រ័យទាក់ទង។ សិស្សក៏អាចសង្កេតមើលការចូលរួមរបស់សហគមន៍ និងមើលការងាររបស់ពួកគេថាតើងាយស្រួលយ៉ាងដូចម្ដេចនៅពេលដែលមានការចូលរួមពីសហគមន៍។

**ការគោរពពហុភាព និងការយល់ចិត្ត ៖** សិស្សនឹងសម្ភាសជាមួយមនុស្សខុសៗគ្នាជាច្រើន ដើម្បីទទួលបានទស្សនៈនៃការយល់ដឹងរបស់សហគមន៍ និងតម្រូវការសំដៅលើបម្រែបម្រួលអាកាសធាតុ និងនិរន្តរភាព។ សិស្សគួរតែសង្កេតមើលជនក្រីក្រ ជនចាស់ជរា ឬជនពិការដែលមានតម្រូវការពិសេស និងបន្ទាន់ច្រើនប៉ុណ្ណា។

**ការរិះគិតពិចារណា ៖** ការវិភាគទិន្នន័យជំរុញឱ្យមានការរិះគិតពិចារ

| | | | | |
|---|---|---|---|---|
| | | | • តើសហគមន៍មានចំណេះដឹងអ្វីខ្លះអំពីបម្រែបម្រួលអាកាសធាតុ? តើសមាជិកសហគមន៍ណាដែលទទួលបានព័ត៌មានល្អបំផុត និងអាក្រក់បំផុតអំពីបម្រែបម្រួលអាកាសធាតុ?<br>• តើប្រជាជនមានចំណេះដឹងអំពីនិរន្តរភាពកម្រិតណា? តើនរណាមានច្រើន និងនរណាមានតិច?<br>• តើមនុស្សគិតពីអ្វីចំពោះការប្រើប្រាស់ប្លាស្ទិក? តើពួកគេយល់ទេថាហេតុអ្វីបានជាវាជាបញ្ហា? តើពួកគេមានដំណោះស្រាយចំពោះបញ្ហានេះដែរឬទេ?<br>• តើកាកសំណល់ចំណីអាហារជាបញ្ហាមួយដែលមាននៅគ្រប់កន្លែងឬ? តើត្រូវធ្វើដូចម្តេចចំពោះអាហារនោះ? តើយើងអាចណែនាំអំពីការផ្លាស់ប្តូរដោយរបៀបណា?<br>• ហេតុអ្វីបានជាអ្នកគិតថាមនុស្សមួយចំនួនគិតបែបនេះ?<br>• តើអ្នកគិតថាអ្វីដែលអាចជួយផ្លាស់ប្តូរគំនិតរបស់ពួកគេបាន?<br>• តើអ្នកគិតថាមនុស្សនឹងទទួលយកយុទ្ធនាការទំនាក់ទំនងរបស់អ្នកចំពោះបញ្ហានេះយ៉ាងដូចម្តេច? តើអ្នកគិតថាសារអ្វីដែលមានប្រសិទ្ធភាពបំផុត?<br>• តើមានបញ្ហាអ្វីខ្លះដែលយើងអាចជួបប្រទះអំឡុងពេលធ្វើសកម្មភាព?<br>• តើមនុស្សពិតជាមិនយល់ពីការប្រែប្រួលអាកាសធាតុមែនឬ? តើយើងគួរដោះស្រាយវាដោយរបៀបណា?<br>• តើមនុស្សមានការគិតខុសឬ? តើយើងអាចធ្វើដូចម្តេចដើម្បីជួយកែតម្រូវគំនិតរបស់ពួកគេ?<br>• តើក្រុមណាដែលយល់ច្រើនជាងគេ? ក្រុមណាដែលយល់តិចជាងគេ?<br>• តើយើងត្រូវការឧបករណ៍បែបណា ដើម្បីផ្សព្វផ្សាយទៅមនុស្សទាំងនេះ?(ផូស្ទ័រ រូបថត វីដេអូ ខិត្តបណ្ណ កម្មវិធីវិទ្យុ...)<br>• តើយើងគិតថាសារប្រភេទណាដែលមានសារៈសំខាន់បំផុតក្នុងការផ្តល់ចំណេះដឹងទៅកាន់ពួកគេ?<br>សំណួរខាងលើនេះនឹងត្រូវកែសម្រួល អាស្រ័យទៅលើសំណួរជាក់ស្តែងដែលសិស្សបានសួរ និងការឆ្លើយតបរបស់សហគមន៍។<br><br>**កិច្ចការផ្ទះ៖** ឱ្យសិស្សគិតពីបញ្ហាមួយដែលពួកគេបានជួបប្រទះអំឡុងពេលធ្វើការស្រាវជ្រាវ ហើយសរសេរអំពីដំណោះស្រាយចំពោះបញ្ហានោះមួយទំព័រ ថាតើពួកគេនិយាយជាមួយអ្នកណា តើពួកគេធ្វើអ្វីដែលខុសៗគ្នា តើការគាំទ្រប្រភេទណាដែលពួកគេត្រូវការ។ | ណា។ ការវិភាគទិន្នន័យមិនត្រឹមតែទទួលលទ្ធផលបែបណានោះទេ ប៉ុន្តែក៏ត្រូវមានការរិះគិតពិចារណាអំពីរបៀបវិភាគលទ្ធផល និងមូលហេតុដែលធ្វើឱ្យវាសមហេតុផលក្នុងការវិភាគផងដែរ។ |

| ជំ.៤. **ការរៀបចំផែនការសកម្មភាព** | | | **គោលបំណង ៖** កំណត់យុទ្ធនាការផ្សព្វផ្សាយអំពីបម្រែបម្រួលអាកាសធាតុសម្រាប់សហគមន៍ និងប្រទេសកម្ពុជា។ ផែនការនេះគួរតែរួមបញ្ចូលនូវវីដេអូ អត្ថបទដែលបានបោះពុម្ពនិងផ្សព្វផ្សាយជាលក្ខណៈជាតិ ផូស្ទ័រនិងការតាំងពិព័រណ៍រូបថតក្នុងមូលដ្ឋាន។ | |
|---|---|---|---|---|
| ៣ | ១១ | ២(២២) | **សកម្មភាពត្រៀមមុនរបស់គ្រូ ៖** ផ្អែកតាមការស្រាវជ្រាវក្នុងសហគមន៍ និងផែនការរបស់សិស្ស គ្រូត្រូវគិតអំពីទីកន្លែងដែលនឹងទទួលបានព័ត៌មានចាំបាច់ដើម្បីអនុវត្តសកម្មភាព ហើយគិតអំពីផែនការផ្សព្វផ្សាយដែលអ្នកនឹងត្រូវណែនាំដល់សិស្ស។ រៀបចំផូស្ទ័រព័ត៌មានអំពីអ្នកជំនាញទីផ្សារក្នុងស្រុក។ រៀបចំផូស្ទ័រគម្រោងផែនការផ្សព្វផ្សាយ(ឧបសម្ព័ន្ធ២)។<br>**សម្ភារៈ ៖** សៀវភៅកំណត់ត្រារបស់សិស្ស ក្តារខៀន ហ្វឺត ក្រដាសផ្ទាំងធំ ផូស្ទ័រព័ត៌មានអំពីអ្នកជំនាញក្នុងតំបន់។ កុំព្យូទ័រ និងឧបករណ៍បញ្ចាំងស្លាយត្រូវប្រើប្រសិនបើមាន។<br><br>**សកម្មភាពទី១ ៖ ផែនការផ្សព្វផ្សាយ**<br>សិស្សបានប្រមូល និងវិភាគទិន្នន័យដែលទទួលបានពីសហគមន៍រួចរាល់ហើយ ពេលនេះសិស្សត្រូវធ្វើផែនការផ្សព្វផ្សាយ។ ពន្យល់សិស្សថា គម្រោងក្នុងឆមាសរបស់អ្នកនឹងធ្វើយុទ្ធនាការរកការគាំទ្រពីសហគមន៍។ យុទ្ធនាការនេះត្រូវមានប្រព័ន្ធផ្សព្វផ្សាយផ្សេងៗមួយចំនួន សិស្សត្រូវផលិតវីដេអូ សិស្សត្រូវបង្រៀន បន្ទាប់មកសិស្សអាចធ្វើបទបង្ហាញ ឬសិល្បៈកែច្នៃវត្ថុចេញពីសំរាម។ សិស្សអាចជ្រើសរើសក្រុមណាមួយដែលគេចង់ចូលរួម ប៉ុន្តែបើសិនក្រុមណាមួយមានសិស្សច្រើនពេកត្រូវរំលែកក្រុមនីមួយៗឱ្យស្មើគ្នាតាមការស្ម័គ្រចិត្តរបស់សិស្ស។<br>គ្រូព្រីនឧបសម្ព័ន្ធទី២ចែកដល់សិស្ស។ គ្រូចែកសិស្សជាក្រុមដោយផ្អែកទៅលើសកម្មភាពផ្សព្វផ្សាយដែលបានជ្រើសរើស (យុទ្ធនាការក្នុងមូលដ្ឋាន បញ្ចាំងវីដេអូ អត្ថបទសំណេរ ការធ្វើបទបង្ហាញ ការកែច្នៃវត្ថុសិល្បៈពីសំរាម)។ ឱ្យសិស្សជ្រើសរើសប្រធានក្រុម ឬអ្នកបកស្រាយពីររូបសម្រាប់ក្រុមពួកគេ។ ពន្យល់សិស្សថានៅចុងបញ្ចប់នៃម៉ោងរៀន សិស្សត្រូវរៀបរាប់អំពីផែនការផ្សព្វផ្សាយឱ្យបានច្បាស់លាស់ ថាតើប្រភពនិងឧបករណ៍អ្វីខ្លះដែលពួកគេនឹងប្រើប្រាស់ ព័ត៌មានអ្វីដែលពួកគេនឹងត្រូវបង្ហាញ កន្លែងណាដែលពួកគេធ្វើសកម្មភាព។ គ្រូត្រូវផ្តល់ការគាំទ្រដល់ក្រុមតាមការណែនាំខាងក្រោម ហើយសូមពិចារណាផងដែរនូវព័ត៌មានពីអ្នកជំនាញទីផ្សារក្នុងស្រុក។ នៅពេលដែលសិស្សបាន | **ដំណោះស្រាយបញ្ហា ៖** សិស្សត្រូវមានការប្រកួតប្រជែងក្នុងការគិតអំពីដំណោះស្រាយ និងវិធីដែលអាចស្វែងរកជំនួយ ឬប្រភពណាមួយដើម្បីជួយដល់ដំណោះស្រាយបញ្ហា។<br><br>**ការរិះគិតពិចារណា ៖** តាមរយៈដំណាក់កាលនៃការកំណត់ ឬការរកដំណោះស្រាយបញ្ហា សិស្សត្រូវឆ្លងកាត់ដំណើរការវិភាគរកមូលហេតុ (មូលហេតុភ្លាមៗ និងបន្ទាប់បន្សំ) ដើម្បីឈានទៅដល់ដំណោះស្រាយដែលអាចអនុវត្តបាន។<br><br>**ការច្នៃប្រឌិត៖** សិស្សនឹងមានការច្នៃប្រឌិត ដោយសារពួកគេត្រូវការលើកឡើងនូវដំណោះស្រាយ និងមូលហេតុនៃបញ្ហា។ សិស្សអាចក្លាយជាមនុស្សពោរពេញទៅដោយគំនិតច្នៃប្រឌិត។<br><br>**ភាពធន់ ៖** នៅពេលដែលសិស្សគិតអំពីដំណោះស្រាយ ពួកគេត្រូវគិតដល់ភាពធន់នៅក្នុង |

| | | | | |
|---|---|---|---|---|
| | | | បញ្ចប់សកម្មភាពទាំងអស់ សិស្សត្រូវរៀបចំតាំងពិព័រណ៍ស្នាដៃរបស់ពួកគេ។<br><br>**១-ក្រុមវីដេអូ៖**<br>ប្រាប់សិស្សថា អ្នកនឹងផលិតជាវីដេអូឃ្លីបចំនួន ៣-៥ វីដេអូ (អាស្រ័យលើពេលវេលា) វីដេអូ TikTok នៅលើទូរសព្ទដៃរបស់អ្នក។ មានការណែនាំពីរបៀបផលិតវីដេអូ។ ឱ្យសិស្សមើលការណែនាំមួយចំនួនដូចខាងក្រោម៖<br>- https://www.youtube.com/watch?v=xsBQPxQ92fE (ភាសាខ្មែរ)<br>- https://www.youtube.com/watch?v=KlyzCvnkaDE (ភាសាខ្មែរ)<br>- https://www.youtube.com/watch?v=vAho-cr5UxY (ជាភាសាអង់គ្លេស ប៉ុន្តែមានភាពលម្អិត ងាយស្រួលក្នុងការអនុវត្តតាម(<br>ពន្យល់ពីជំហាននៃការផលិតវីដេអូ៖<br>***ជំហានទី១ ៖*** កំណត់ និងស្វែងយល់ពីទស្សនិកជន (ប៉ុន្តែតើសិស្សអាចធ្វើយ៉ាងណាដើម្បីឱ្យទស្សនិកជនយល់បានទូទាំងប្រទេស? តើពួកគេបានរកឃើញប្រធានបទទូទៅអ្វីខ្លះក្នុងចំណោមមនុស្សទាំងអស់ដែលពួកគេបានសម្ភាស? តើប្រធានបទទាំងនេះអាចអនុវត្តបានទូទាំងប្រទេសឬទេ? តើអ្វីដែលសំខាន់បំផុតដែលពួកគេអាចធ្វើបានដើម្បីបង្រៀនដល់សហគមន៍របស់ពួកគេ ក៏ដូចជាបង្រៀនដល់ប្រជាជនកម្ពុជាទាំងអស់?)<br>***ជំហានទី២ ៖*** សរសេរសាច់រឿង(storybaord) និងស្គ្រីបដែលនឹងត្រូវនិយាយ។ ដំណាក់កាលមុនផលិតគឺជាជំហានដ៏វែង និងសំខាន់បំផុតក្នុងការផលិតវីដេអូឱ្យមានគុណភាព។ ភាពយន្តល្អៗមិនត្រូវការកែច្នៃនោះទេ ហើយវីដេអូក៏ដូចគ្នាដែរ។ ស្នើឱ្យសិស្សធ្វើវីដេអូនីមួយៗក្នុងរយៈពេល៥នាទី។ វីដេអូនីមួយៗគួរតែមានសាច់រឿងផ្ទាល់របស់វា ប៉ុន្តែក៏គួរតែមានទំនាក់ទំនងនឹងគ្នា។ សិស្សត្រូវតែសរសេរសាច់រឿង (storyboard) និងស្គ្រីបដោយយោងទៅតាមពេលវេលានៃវីដេអូ។ សូមចងចាំផងដែរថា វីដេអូទាំងនេះ យ៉ាងហោចណាស់មួយផ្នែកនិយាយអំពីយុទ្ធនាការផ្សព្វផ្សាយក្នុងសហគមន៍។ វាមិនចាំបាច់ទេ ប៉ុន្តែនោះជាជម្រើសដែលត្រូវគិតដល់។ | សហគមន៍មុនគេ។សិស្សត្រូវគិតផងដែរពីកម្រិតចំណេះដឹងរបស់សហគមន៍។ ការគិតបែបនេះធ្វើឱ្យសហគមន៍មានភាពធន់ច្រើន។<br><br>**ការសម្រេចចិត្ត** ៖ សិស្សត្រូវធ្វើការសម្រេចចិត្តពីវិធីដែលពួកគេគួរធ្វើនៅក្នុងសកម្មភាពនោះ និងវិធីជួយអ្នកដទៃ។<br><br>**ការប្រាស្រ័យទាក់ទង** ៖ អ្វីគ្រប់យ៉ាងគឺត្រូវផ្តោតលើការប្រាស្រ័យទាក់ទងតាមរយៈការយល់ដឹងរបស់ទស្សនិកជន ការរៀបចំបានល្អ ការផ្តល់សារបានច្បាស់លាស់ ការប្រើប្រាស់គម្លាត និងសិល្បៈបង្ហាញពីគំនិត។<br><br>**សហប្រតិបត្តិការ និង ការចរចា** ៖ សិស្សត្រូវបែងចែកភារកិច្ចរបស់ពួកគេទៅតាមផ្នែកជា ក្រុមកែច្នៃវត្ថុពីសំរាម ក្រុមវីដេអូ និងក្រុមយុទ្ធនាការផ្សព្វផ្សាយក្នុងមូលដ្ឋាន។ គ្រូត្រូវជួយពួកគេឱ្យចរចាបានត្រឹមត្រូវ និងណែនាំឱ្យធ្វើកិច្ចសហប្រតិបត្តិការបានល្អ។ |

Storyboard គឺជាស៊េរីគំនូរនូវអ្វីដែលពួកគេចង់បង្ហាញនៅក្នុងវីដេអូ។ ស្គ្រីបគឺជាអ្វីដែលពួកគេនឹងនិយាយ។ វាអាចធ្វើបានស្របពេលគ្នា។ សិស្សត្រូវសរសេរសារទាំងអស់ និងបំផុសគំនិតអំពីរបៀបដែលពួកគេចង់បង្ហាញសារនោះ។ ឧទាហរណ៍ តើសិស្សចង់ផ្តោតទៅលើទំនាក់ទំនងរវាងប្លាស្ទិក អាកាសធាតុ និងសុខភាពមិនល្អឬ? តើសាររួមរបស់ពួកគេនឹងនិយាយអំពីការប្រើប្រាស់ប្លាស្ទិកតិចឬ? សិស្សត្រូវតែស្វែងយល់ពីសារទាំងមូល បន្ទាប់មករៀបចំផែនការថាតើពួកគេចង់បង្ហាញវាយ៉ាងដូចម្តេច... តើត្រូវបញ្ចាំងវីដេអូទាំងអស់ឬ? តើនឹងមានអ្នកណាម្នាក់និយាយឡើងវិញឬទេ? តើនឹងមានអ្វីដែលអាចបន្ថែមទៀតទេ? តើនឹងមានគំនូរបន្ថែមទេ? ធ្វើជា storyboard ខណៈពេលកំពុងធ្វើការលើស្គ្រីប ហើយបន្ទាប់មកត្រូវប្រាកដថាវាអាចទៅដោយរលូន។ នេះជាកិច្ចការលំបាកមួយ ហើយនឹងត្រូវការចំណាយពេលច្រើន។

ជំហានបន្ទាប់គឺ៖

***<u>ជំហានទី៣</u>*** ៖ ថតសម្លេងការរៀបរាប់របស់អ្នក

***<u>ជំហានទី៤</u>*** ៖ ថតរូបភាពរបស់អ្នក ឬថតវីដេអូ

***<u>ជំហានទី៥</u>*** ៖ កែសម្រួលវីដេអូ

***<u>ជំហានទី៦</u>*** ៖ បញ្ចូលសេចក្តីផ្តើមវីដេអូ (គំនូរ ឬគំនូរមានចលនា)។

ជំហានទាំងនេះនឹងត្រូវធ្វើឱ្យរួចរាល់នៅម៉ោងសិក្សាបន្ទាប់។ ប៉ុន្តែសិស្សត្រូវតែរៀបចំផែនការផ្សព្វផ្សាយក្នុងម៉ោងសិក្សានេះដែរ។

***<u>ជំហានទី៧</u>*** ៖ ចែករំលែកវីដេអូរបស់អ្នក។ សាលាគួរតែបង្កើតគណនី TikTok ប្រសិនបើមិនទាន់មាន ហើយសិស្សគួរតែធ្វើការចែករំលែកវីដេអូរបស់ពួកគេនៅលើឆានែលនេះ។ វីដេអូទាំងនេះគួរតែត្រូវបានចែករំលែកតាមរយៈតំណភ្ជាប់របស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូនីសេហ្វ (UNICEF) សម្រាប់ការផ្សព្វផ្សាយ និងជាឯកសារយោងបន្ថែម។ រំលឹកសិស្សថា សិស្សផ្សេងទៀតដែលនៅក្នុងប្រទេសកម្ពុជានឹងរៀនសូត្រពីអ្នក! នេះជាឱកាសមួយក្នុងការផ្តល់នូវការអប់រំដល់អ្នកដទៃ ហើយវីដេអូទាំងនេះអាចត្រូវបានមនុស្សមួយចំនួននៅប្រទេសកម្ពុជាបានស្គាល់ស្នាដៃរបស់អ្នក!

បង្ហាញឧទាហរណ៍វីដេអូបម្រែបម្រួលអាកាសធាតុរបស់សិស្ស (គ្រូអាចស្វែងរកវីដេអូផ្សេងៗទៀតតាមអ៊ីនធឺណែត)
https://www.youtube.com/watch?v=uOa5zem4504

ឧទាហរណ៍ផ្សេងទៀតនៃវីដេអូការនិទានរឿង ទោះជាវីដេអូនោះមិនផលិតដោយសិស្សក៏ដោយ រួមមាន៖

- https://www.youtube.com/watch?v=oBAt90X8VME
  Earth Tanks for Older People
- https://www.youtube.com/watch?v=DfFK27CT2nM
  Climate Smart Farmer Field Schools
- https://www.youtube.com/watch?v=dwaO0r8WV9k
  Cambodia's obsession with plastic

**២-ក្រុមយុទ្ធនាការផ្សព្វផ្សាយក្នុងមូលដ្ឋាន ៖**

ក្រុមនេះត្រូវសួរសំណួរដូចគ្នានឹងក្រុមវីដេអូដែរ៖

- តើអ្នកដឹងអ្វីខ្លះអំពីទស្សនិកជនរបស់អ្នក?
- តើខ្លឹមសាររួមអ្វីខ្លះដែលសិស្សបានរកឃើញក្នុងចំណោមមនុស្សទាំងអស់ដែលសិស្សបានសម្ភាសន៍?
- តើយុទ្ធនាការទាំងនេះអាចអនុវត្តទូទាំងប្រទេសបានឬទេ?
- តើអ្វីដែលសំខាន់បំផុតដែលសិស្សអាចបង្រៀនសហគមន៍របស់ពួកគេ និងអ្នកផ្សេងទៀត?
- តើសារអ្វីដែលអ្នកគិតថាសំខាន់បំផុតដែលអ្នកគួរបង្ហាញ? តើការបង្ហាញនោះធ្វើដោយរបៀបណា?) ទំហំផ្ទាំងរូបភាព បណ្ណផ្ទត់ រូបថតដែលមានចំណងជើង សារណែនាំ)
- តើទីតាំងណាសមស្របសម្រាប់ដាក់មធ្យោបាយផ្សព្វផ្សាយ?
- តើ "និមិត្តសញ្ញា" ប្រភេទណាដែលសិស្សអាចគូរបាន? (ស្នើសិស្សម្នាក់ ឬពីរនាក់ដែលចេះគូរគំនូរបានស្អាត ឱ្យគូរនិមិត្តសញ្ញា ឬតួអក្សរដែលជាផ្ទៃរឿងទូទៅដោយភ្ជាប់ទៅលើសារទាំងអស់។ គំនិតមួយចំនួន - eco-warrior gecko; trash-loving crocodile; sustainability-loving elephant
- សិស្សគួរតែមានតារាងផែនការសម្រាប់បំពេញគឺ ៖

សិស្សគួរតែសរសេរផែនការទាំងនេះទៅក្នុងតារាងផែនការរបស់ពួកគេ ហើយបន្ទាប់មកចាប់ផ្តើមគូររូបភាពតាមគំនិតខ្លះៗរបស់ពួកគេ។ គូសផែនទីកន្លែងដែលពួកគេនឹងធ្វើយុទ្ធនា សម្ភារៈដែលត្រូវប្រើមាន ក្រដាស ស្កុត ហ្វឺត។ល។ ប្រសិនបើពួកគេធ្វើផែនការ និងរចនាតួអក្សររួច មុនពេលក្រុមវីដេអូបានបញ្ចប់ ក្រុមនេះគួរតែចូលរួមជាមួយក្រុមវីដេអូដើម្បីជួយពួកគេបញ្ចូលនូវនិមិត្តសញ្ញា (logo) ទៅក្នុងផែនការរបស់ពួកគេ។ ពួកគេក៏គួរតែទាក់ទងជាមួយក្រុមអ្នកសរសេរ ដើម្បីជួយក្រុមសរសេរសៀវភៅក្នុងការរចនាគម្របសម្រាប់សៀវភៅរបស់ពួកគេ។

| | | | | |
|---|---|---|---|---|
| | | | ៣-ក្រុមសរសេរសៀវភៅ ៖<br>ក្រុមនេះអាចសម្រេចការងារបានមុនគេ។ សមាជិកក្រុមទាំងអស់ត្រូវបានផ្តល់ភារកិច្ចសរសេរអំពីអាកាសធាតុ និងនិន្នភាព ដែលពួកគេចង់និយាយពីបទពិសោធផ្ទាល់ខ្លួន ពីសហគមន៍ ឬ អំពីអ្វីមួយដែលបានកើតឡើងចំពោះនរណាម្នាក់ដែលពួកគេស្គាល់ ឬនៅពេលសម្ភាស។<br>នៅពេលពិភាក្សាក្រុម សិស្សម្នាក់ៗត្រូវសរសេរផែនការរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេ ហើយបន្ទាប់មកផ្តល់ផែនការនេះទៅឱ្យក្រុមពិចារណា។ សិស្សគួរតែរឿងរបស់ខ្លួន៖<br>• ត្រូវតែមាន ៥ទំព័រ ឬអាចធ្វើហួតដល់ ១០ទំព័រប្រសិនបើគេចង់សរសេរ។ អាចបញ្ចូលរូបថត ឬរូបគំនូរតាមទំព័រនីមួយៗ តិចឬច្រើនតាមសាច់រឿង។<br>• ត្រូវគិតដល់គោលការណ៍នៃការសរសេររឿងខ្លីដែលល្អ ៖<br>❖ យល់ថារឿងខ្លីមិនដូចរឿងប្រលោមលោកទេ<br>❖ កុំធ្វើវែងពេក<br>❖ កុំចំណាយពេលច្រើនក្នុងការសរសេរ<br>❖ ចំនួនតួអក្សរតិច<br>❖ នរណាអានក៏យល់ដែរ<br>❖ បង្កើតចំណាប់អារម្មណ៍!<br>❖ រំលឹកសាវតានៃរឿង ប៉ុន្តែកុំនិយាយលម្អិត។<br>• បន្ទាប់មកដំណើរការសរសេរគួរអនុវត្តតាមគោលការណ៍នេះ៖<br>❖ ផ្តោតអារម្មណ៍លើរឿងខ្លីរបស់អ្នក<br>❖ សរសេរចាប់ផ្តើមរឿងត្រូវឱ្យមានការទាក់ទាញ<br>❖ បញ្ចប់សាច់រឿងប្រកបដោយអត្ថន័យ<br>❖ អានឱ្យច្បាស់ និងបន្លឺសំឡេងឱ្យខ្លាំង<br>❖ ត្រួតពិនិត្យ និងកែសម្រួល<br>❖ សុំមតិកែលម្អ។<br>នៅចុងបញ្ចប់នៃម៉ោងសិក្សាសិស្ស គួរតែរៀបចំផែនការនៅក្នុងសៀវភៅកំណត់ត្រា ប្រធានបទឬសារសំខាន់ៗ តួអង្គ សាវតារឿង ការកើតហេតុ ចំណាប់អារម្មណ៍ និងរបៀបចាប់ផ្តើម និងបញ្ចប់សាច់រឿង ។ សិស្សគួរតែធ្វើកិច្ចការនេះជាបុគ្គល បន្ទាប់មកធ្វើជាក្រុមដោយប្តូរកិច្ចការគ្នាមើល និងផ្តល់មតិកែលម្អ។ សិស្សយល់ថា ពួកគេត្រូវតែស្តាប់ និងពិចារណាលើការផ្តល់យោបល់ផ្សេងៗ។ ប៉ុន្តែនៅទីបញ្ចប់ សិស្សត្រូវតែសម្រេចចិត្តដោយខ្លួនឯងថា តើផែនការណាដែលល្អបំផុត។ ទោះបីជាយ៉ាងណា សិស្សត្រូវតែអាចពន្យល់ហេតុផលនៃផែនការនេះបានត្រឹមត្រូវ។ | |

| | | | | |
|---|---|---|---|---|
| | | | **៤-ក្រុមធ្វើបទបង្ហាញ ៖**<br>ក្រុមនេះនឹងទទួលបន្ទុកធ្វើបទបង្ហាញអំពីអ្វីដែលពួកគេបានរៀននៅក្នុងឆមាសនេះ(រយៈពេល២០នាទី)។ សិស្សត្រូវបកស្រាយអំពីឥទ្ធិពលឧស្ម័នផ្ទះកញ្ចក់ និងមូលហេតុនៃបម្រែបម្រួលអាកាសធាតុ ផលប៉ះពាល់ វិធានការកាត់បន្ថយ និងការរស់នៅប្រកបដោយនិរន្តរភាព ត្រូវប្រាកដថាធ្វើឱ្យមានទំនាក់ទំនងរវាងការរស់នៅប្រកបដោយចីរភាព និងវិធីដែលអាចកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ហើយធ្វើឱ្យបរិស្ថានស្អាត និងមនុស្សមានសុខភាពល្អ។ សិស្សអាចនិយាយអំពីការបន្សុំាដោយសង្ខេបបើគេចង់និយាយ ក្នុងករណីសិស្សបានរៀនពីថ្នាក់ក្រោមរួចហើយ ប៉ុន្តែត្រូវតែផ្តោតទៅលើការកាត់បន្ថយ និងការរស់នៅប្រកបដោយចីរភាព។ ស្នើឱ្យសិស្សផ្តោតទៅលើការរស់នៅប្រកបដោយចីរភាពដែលពាក់ព័ន្ធបំផុតចំពោះសហគមន៍របស់ពួកគេ (ការប្រើប្រាស់ប្លាស្ទិក គ្មានការដុតប្លាស្ទិក ការប្រើប្រាស់ផលិតផលសម្អាតបរិស្ថានផលិតពីធម្មជាតិ គ្មានការបន្ទោរបង់នៅទីសាធារណៈ ឬការចោលកាកសំណល់ពាសវាលពាសកាល មិនដុតសំរាមសម្អាតដី។ល។)។<br>សិស្សត្រូវចងចាំគោលការណ៍ធ្វើបទបង្ហាញ ដែលពួកគេបានរៀនពីមុន និងអនុវត្តតាមគោលការណ៍នោះដើម្បីរៀបចំស្លាយ។ សូមប្រាកដថា សិស្សអាចប្រើប្រាស់កុំព្យូទ័របាន(កុំព្យូទ័រសាលា កុំព្យូទ័ររបស់គ្រូ។ល។)<br><br>**៥-ក្រុមសិល្បៈកែច្នៃវត្ថុសំណល់ និងការតាំងពិព័រណ៍៖**<br>សិល្បៈកែច្នៃគឺជាទម្រង់នៃមធ្យោបាយផ្សព្វផ្សាយមួយ ដែលអាចមានប្រសិទ្ធភាពខ្ពស់ក្នុងការទទួលបាននូវព័ត៌មាន។ សិល្បៈអំពីសំរាមបានក្លាយជាទីពេញនិយមយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វាជាវិធីបង្កើតឱ្យមានសោភណភាពនៅទីសាធារណៈដោយប្រើវត្ថុធាតុដើមពីសំរាមប្លាស្ទិក។ បង្ហាញសិស្សរបស់អ្នកនូវរូបភាពនៃរូបចម្លាក់ដែលធ្វើពីសំរាមដូចខាងក្រោម និងរូបភាពផ្សេងៗទៀតនៅក្នុងឧបសម្ព័ន្ធ៨។ | |

| | | | | |
|---|---|---|---|---|
| | | | <br>ក្រុមខ្លះអាចធ្វើរួចមុនក្រុមដទៃ។ ក្រុមដែលធ្វើរួចមុនគេត្រូវចាប់ផ្តើមរៀបចំផែនការផ្សព្វផ្សាយ ប្រសិនបើពួកគេមានពេល។ ក្រុមតុបតែងទទួលបន្ទុករៀបចំព្រឹត្តិការណ៍នេះ ប៉ុន្តែសិស្សទាំងអស់អាចផ្តល់ជាជំនួយដល់ពួកគេបាន។<br><br>**កិច្ចការផ្ទះ** ៖ ឱ្យសិស្សទាំងអស់(ដោយមិនគិតថាពួកគេស្ថិតនៅក្នុងក្រុមវីដេអូនោះទេ)អនុវត្តកម្មវិធី YouCut ។ ឱ្យសិស្សទាំងអស់គ្នាចូលមើលវីដេអូពី ២០ទៅ ៣០វិនាទី ដែលសិស្សបានធ្វើរួចពីសប្តាហ៍កន្លងមក - វីដេអូមិនចាំបាច់មានស្ព្រីបទេ។ គ្រូគួរតែដឹងថាសិស្សយល់ពីរបៀបប្រើប្រាស់កម្មវិធីដើម្បីកាត់តវីដេអូ បញ្ចូលតន្ត្រី និងចលនា ឬអ្វីផ្សេងទៀត។ ទោះបីជា សិស្សទាំងអស់មិននៅក្នុងក្រុមធ្វើវីដេអូក៏ដោយ ក៏ពួកគេអាចមានលទ្ធភាពប្រើប្រាស់កម្មវិធីវីដេអូនៅលើទូរស័ព្ទដៃឆ្លាតវៃរបស់ពួកគេបាន។ | |
| **ជំ.៥.<br>ការអនុវត្តផែនការ** | | | **គោលបំណង** ៖ ដើម្បីលើកកម្ពស់ការយល់ដឹងតាមរយៈសហគមន៍ និងប្រទេសកម្ពុជា អំពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងការចូលរួមពសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីរួមគ្នាកាត់បន្ថយការប្រែប្រួលអាកាសធាតុ រស់នៅប្រកបដោយនិរន្តរភាព និងចាត់វិធានការដើម្បីការពារបរិស្ថាន និងសុខភាព។ | |
| ៣ | ១២ | ៣(២៥) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ គ្រូត្រូវដឹង និងយល់អំពីផែនការទាំងអស់របស់សិស្ស និងជួយពួកគេនៅពេលចាំបាច់។ គ្រូត្រូវកំណត់និងបញ្ជាក់ពីទីកន្លែងសម្រាប់ការតាំងពិព័រណ៍។<br>**សម្ភារៈ** ៖ ផូស្ទ័រ ហ្វឺត ខ្មៅដៃពណ៌ កន្ត្រៃ ក្រដាសពណ៌ ស្កុតសម្រាប់ក្រុមផ្សព្វផ្សាយ។<br><br>**សកម្មភាពទី១ ៖ ការពន្យល់មិត្តរួមថ្នាក់**<br>ដោយប្រើប្រាស់ផែនការផ្សព្វផ្សាយដែលសិស្សបានធ្វើពី | **ការដោះស្រាយបញ្ហា និងការរិះគិតពិចារណា** ៖ សិស្សត្រូវមានការប្រកួតប្រជែងក្នុងការគិតអំពីគម្រោងរបស់អ្នកដទៃ និងដំណោះស្រាយ និងរបៀបដែលពួកគេអាចស្វែងរកជំនួយដើម្បីធ្វើ |

សប្តាហ៍មុន គ្រូគូសតារាងផែនការផ្សព្វផ្សាយនៅលើក្តារខៀន(ឬនៅលើកុំព្យូទ័រប្រសិនបើមាន)។

ឱ្យសិស្សជ្រើសរើសអ្នកនិយាយម្នាក់ ឬពីរនាក់សម្រាប់ក្រុមនីមួយៗ ហើយក្រុមនីមួយៗត្រូវពន្យល់អ្នកផ្សេងទៀតឱ្យបានដឹងច្បាស់អំពីផែនការរបស់ពួកគេ។ សិស្សក្រុមផ្សេងទៀតត្រូវលើកទឹកចិត្តឱ្យសួរសំណួរ។ គ្រូអាចជួយណែនាំសិស្សនូវសំណួរដូចខាងក្រោម៖

- ហេតុអ្វីបានជាតំបន់មួយនេះប្រសើរជាងតំបន់មួយទៀត? តើពួកយើងផ្សព្វផ្សាយបានគ្រប់កន្លែងឬទេ? តើយើងអាចធ្វើបន្ថែមទៀតបានទេ? តើយើងគួរធ្វើតិចជាងនេះឬ?
- ហេតុអ្វីបានត្រូវប្រើសារនេះ មិនប្រើសារផ្សេង? តើការផ្លាស់ប្តូរឥរិយាបថ ឬការយល់ដឹងប្រភេទណាដែលអ្នកសង្ឃឹមថានឹងទទួលបានពីខ្លឹមសារនៃសារនេះ?
- តើលទ្ធផលនឹងទៅជាយ៉ាងណា? តើវានឹងជួយដល់អាកាសធាតុបានយ៉ាងដូចម្តេច? ជួយប្រជាជនដល់កម្ពុជាបានយ៉ាងដូចម្តេច?
- តើអាចមានការច្នៃប្រឌិតអ្វីបន្ថែមទៀតលើទម្រង់នេះឬទេ?
- តើសារនេះមានច្រើនពេក ឬគួរសម្រួលវាខ្លះ?
- តើមានវិធីណាដែលយើងអាចវាស់កម្រិតផលប៉ះពាល់នោះដែរឬទេ?(ប្រហែលជាមិនអាចទេ ប៉ុន្តែមើលថាតើពួកគេមានគំនិតអ្វីខ្លះ)
- តើយើងនឹងអាចធ្វើអ្វីបានខ្លះនាពេលអនាគតបន្ទាប់ពីរៀនចប់ (ធ្វើផែនការសម្រាប់រៀបចំផ្ទុស្ទ័រឡើងវិញ ឬធ្វើផូស្ទ័រឱ្យកាន់តែប្រើប្រាស់បានយូរតាមរយៈការបោះពុម្ពលើក្រដាសរឹង ធ្វើការផ្សព្វផ្សាយការងាររបស់យើងកាន់តែទូលំទូលាយ ដើម្បីអាចមើលឃើញកាន់តែច្រើន)។

**សកម្មភាពទី១ ៖ ការធ្វើផែនការឡើងវិញ និងការកែសម្រួល** (សកម្មភាពជម្រើស)

សកម្មភាពនេះសង្ឃឹមថាសិស្សបានធ្វើរួចហើយតាមរយៈការងារក្រុមកាលពីសប្តាហ៍មុន សិស្សនឹងមានមតិកែលម្អគ្រប់គ្រាន់រួចហើយលើផែនការនេះ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការពិនិត្យឡើងវិញក្នុងថ្នាក់ទាំងមូលនៃសកម្មភាពរកឃើញថាត្រូវធ្វើការផ្លាស់ប្តូរ ឬមានកំហុស សូមទុកពេលឱ្យសិស្សប្រើម៉ោងសិក្សារយៈពេល ៦០ទៅ៩០នាទីទៀត ដើម្បីឱ្យសិស្សពិនិត្យឡើងវិញនូវផែនការរបស់ពួកគេ។ ឧទាហរណ៍ សិស្សអាចមានភាព

ឱ្យបំណិនទាំងពីរនេះកាន់តែប្រសើរឡើង។

**ការបង្កើតថ្មី ឬការច្នៃប្រឌិត** អ្នកសិក្សានឹងមានភាពច្នៃប្រឌិត ដោយសារពួកគេត្រូវការបង្កើតដំណោះស្រាយ និងមូលហេតុនៃបញ្ហាដែលបានកំណត់។ ពួកគេអាចក្លាយជាមនុស្សសម្បូរទៅដោយភាពច្នៃប្រឌិត។

**សហប្រតិបត្តិការ** ៖ ក្រុមសិស្សនឹងធ្វើការរួមគ្នាដើម្បីសម្រេចថា តើនរណាធ្វើអ្វី ដោយផ្អែកលើចំណាប់អារម្មណ៍ និងបំណិនរបស់ពួកគេ។

**ការសម្រេចចិត្ត** ៖ សិស្សត្រូវធ្វើការសម្រេចចិត្តពីរបៀបដាក់ខ្លួននៅក្នុងសកម្មភាពផ្សេងៗ និងរបៀបជួយអ្នកដទៃ។

**ការចរចា** ៖ សិស្សខ្លះប្រហែលជាចង់ធ្វើកិច្ចការដូចគ្នា ឬសិស្សខ្លះមិនចង់ធ្វើកិច្ចការនោះទេ។ សិស្សទាំងអស់ត្រូវរៀនចរចា ដើម្បីស្វែងរកដំណោះស្រាយដោយយុត្តិធម៌ រួមទាំងការបែងចែកភារកិច្ច និងការងារ

| | | | | |
|---|---|---|---|---|
| | | | វលូនក្នុងក្រុម ប្រសិនបើក្រុមមួយត្រូវការជំនួយច្រើនជាងក្រុមផ្សេងទៀត។ បើសិស្សអនុវត្តសកម្មភាពនេះសិស្សត្រូវធ្វើឱ្យចប់តាមម៉ោងកំណត់។ បើសិស្សមិនធ្វើសកម្មភាពនេះទេ សិស្សត្រូវចាប់ផ្តើមអនុវត្តសកម្មភាពថ្មីដូចខាងក្រោម។<br><br>**សកម្មភាពទី២ ៖ សកម្មភាពស្របពេលគ្នា អនុវត្តមុនផ្សព្វផ្សាយ**<br>សិស្សត្រូវអនុវត្តសកម្មភាពដូចគម្រោងផែនការដែលបានធ្វើ។ ផែនការនេះរួមមានការបញ្ចាំងវីដេអូ ការអធិប្បាយ ការកែសម្រួលក្នុងកម្មវិធី ការបន្ថែមចលនា ឬការរចនា និងគិតទាំងពេលវេលាសម្រាប់សិស្សក្នុងការសរសេររឿងផងដែរ។ ទីបញ្ចប់សកម្មភាពនេះរួមបញ្ចូលទាំងការរចនាផូស្ទ័រ ប័ណ្ណផ្ទត់ រូបភាព ឬអ្វីក៏ដោយដែលចាំបាច់ ដើម្បីធ្វើយុទ្ធនាការផ្សព្វផ្សាយនៅសហគមន៍ តាមលទ្ធភាពធនធានដែលអាចធ្វើបាន។<br><br>**កិច្ចការផ្ទះ** ៖ សិស្សដែលជាអ្នកផលិតវីដេអូ និងសិស្សដែលធ្វើយុទ្ធនាការក្នុងសហគមន៍ ត្រូវបញ្ចប់គម្រោងផែនការទាំងអស់។ ក្រុមសិស្សនិពន្ធរឿង ត្រូវតែចែករំលែករឿងរបស់ពួកគេទៅអ្នកនិពន្ធពីរនាក់ផ្សេងទៀតក្នុងក្រុមដើម្បីកែសម្រួល។ កិច្ចការផ្ទះនេះត្រូវកែសម្រួលដោយប្រុងប្រយ័ត្ន គិតទាំងវេយ្យាករណ៍ រចនាបទ និង លំហូរនៃសាច់រឿង។ | ដល់ភាគីចរចា ដោយសមធម៌។ |
| | ១៣ | ៣(២៨) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ មុនម៉ោងសិក្សា គ្រូត្រូវរៀបចំឧបករណ៍ និងសម្ភារៈទាំងអស់ដូចខាងក្រោមសម្រាប់សកម្មភាពផ្សព្វផ្សាយ។<br>**សម្ភារៈ** ៖ ផូស្ទ័រ រូបភាពព្រីនចេញពីកុំព្យូទ័រ ខ្មៅដៃពណ៌ ហ្វឺត និងឧបករណ៍ទាំងអស់ដែលត្រូវការដើម្បីធ្វើសកម្មភាព(កុំព្យូទ័រ ឧបករណ៍បញ្ចាំង..)។ ក្នុងករណីដែលពួកគេត្រូវការសម្ភារៈបន្ថែមដូចជា ថ្នាំលាប កូនឈើ គ្រាប់ពូជ ប៉ែល ដី ឈើ និងអ្វីៗដែលត្រូវការគេអាចទិញបន្ថែមបាន។<br>***ការណែនាំ*** ៖ គ្រូពន្យល់ថានៅក្នុងម៉ោងនេះ និងម៉ោងបន្ទាប់ សិស្សត្រូវ អនុវត្តសកម្មភាពដែលបានរៀបចំផែនការពេញមួយធមាសនេះឱ្យបានចប់។ គ្រូឱ្យសិស្សតាមក្រុមអនុវត្តផែនការតាំងពិព័រណ៍ដែលបានរៀបចំនៅម៉ោងសិក្សាមុន។<br><br>**សកម្មភាពទី ១៖ ការអនុវត្តផែនការតាំងពិព័រណ៍**<br>គ្រូបង្ហាញកន្លែងតាំងពិព័រណ៍ដល់សិស្ស។ ការតាំងពិព័រណ៍នេះប្រើប្រាស់ម៉ោងសិក្សានៅកន្លែងតាំងផ្ទាល់ អាចជាបន្ទប់ថ្នាក់ | **សហប្រតិបត្តិការ** ៖ ក្រុមសិស្សត្រូវធ្វើការរួមគ្នា និងអនុវត្តតាមតួនាទី ឬរៀនសហប្រតិបត្តិការ និងកែសម្រួលនៅពេលដែលតួនាទីពឹងផ្អែកគ្នាទៅវិញទៅមក។<br><br>**ភាពធន់** ៖ ភាពធន់ក្នុងសហគមន៍ និងភាពធន់ផ្ទាល់ខ្លួនក្នុងការប្រឈមនឹងអាកាសធាតុ គឺជាស្នូលនៃសកម្មភាពនេះ។ សិស្សនឹងរៀនសូត្រទាំងសកម្មភាពជាក់ស្តែង និងការប្រាស្រ័យទាក់ |

រៀនធំមួយនៅសាលា និងអាចជាកន្លែងពិព័រណ៍អំពីព្រឹត្តិការណ៍សហគមន៍ ប្រសិនបើមាន។

ក្នុងការអនុវត្តផែនការតាំងពិព័រណ៍ សិស្សត្រូវគិតទៅលើចំណុចដូចខាងក្រោម៖

- ការណែនាំរបស់គ្រូ។
- ការរៀបចំរចនារួមឱ្យសមស្រប និងមានសោភ័ណ។
- សារដែលសំខាន់ៗ។
- រូបភាព និងគំនិតដែលតាំងបង្ហាញត្រូវមានភាពច្នៃប្រឌិត ភាពទាក់ទាញ មានលក្ខណៈសិល្បៈ ផ្សារភ្ជាប់នឹងបម្រែបម្រួលអាកាសធាតុ ការខូចខាតបរិស្ថាន និងដំណោះស្រាយ ដូចជា៖
  - រូបភាពនៃផលប៉ះពាល់ជុំវិញពិភពលោក និងការពន្យល់អំពីរបៀបដែលបញ្ហានេះអាចកើតឡើងនៅក្នុងប្រទេសកម្ពុជា (កុមារដែលអត់ឃ្លានដោយសារគ្រោះរាំងស្ងួត មនុស្សរងគ្រោះដោយសារទឹកជំនន់)។
  - រូបភាពនៃផលប៉ះពាល់ និងផលវិបាកនៅប្រទេសកម្ពុជា
  - រូបភាពនៃដំណោះស្រាយ(កាត់បន្ថយការខ្ជះខ្ជាយ)
  - សម្រង់គំនិត(រកមើលនៅលើបណ្ដាញអ៊ីនធឺណិត ដើម្បីស្វែងរកគំនិតណាដែលនិយាយអំពីការប្រែប្រួលអាកាសធាតុ អាចសុំជំនួយពីអ្នកចេះភាសាអង់គ្លេសប្រសិនបើចាំបាច់។ សរសេរវានៅលើបដាធំមួយរួចតាំងលើជញ្ជាំង។
  - រូបភាពទាំងនេះត្រូវរចនាឱ្យស្អាតដោយដាក់ស៊ុម ប្រើប្រាស់ពណ៌ មានចំណងជើង។
  - រូបភាពមនុស្សរស់នៅក្នុងសហគមន៍ ដែលសិស្សបានទាក់ទងគាត់ (ឧទាហរណ៍ រូបភាពនៃអ្នកជំនាញក្នុងស្រុកដែលនិយាយអំពីបម្រែបម្រួលអាកាសធាតុ និងនិរន្តរភាព ឬរូបភាពរបស់មនុស្សដែលត្រូវបានសម្ភាសន៍ ជាមួយនឹងសម្រង់សម្ដីដែលពួកគាត់បាននិយាយ ប្រើតែសម្រង់សម្ដីណាដែលវិជ្ជមាន និងបង្ហាញពីចំណេះដឹង ឬសំណួរ) ។

សូមមើលឧបសម្ព័ន្ធ៣ សម្រាប់គំនិតក្នុងការរៀបចំផែនការតាំងពិព័រណ៍។ នៅចុងបញ្ចប់នៃមួយម៉ោង ពួកគេត្រូវធ្វើការរៀបចំតាំងពិព័រណ៍ឱ្យបានរួចរាល់។ គ្រូរៀបចំការតាំងពិព័រណ៍នេះដោយមានជំនួយពីសិស្ស។

គំនិតឬយោបល់ផ្សេងៗត្រូវបិទក្នុងបន្ទប់តាំងពិព័រណ៍។ ការរៀបចំនេះរួមមាន ការបញ្ចាំងវីដេអូ ទីកន្លែងសម្រាប់សិស្សអានរូបភាពផ្សេងៗដូចជា ៖ ការរស់នៅប្រកបដោយចិរភាព ការប្រើ

ទងប្រកបដោយប្រសិទ្ធភាព ដែលធ្វើឱ្យប្រសើរឡើងនូវភាពធន់របស់ពួកគេ។

**ការសម្រេចចិត្ត** ៖ នៅពេលដែលសិស្សកំពុងរៀបចំ និងអនុវត្ត ពួកគេត្រូវធ្វើការសម្រេចចិត្ត និងការកែតម្រូវនៅពេលនោះ។

**ដំណោះស្រាយបញ្ហា** ៖ សិស្សនឹងជួបប្រទះបញ្ហាប្រឈមដែលឥតគ្រោងទុកក្នុងការអនុវត្តផែនការរបស់ពួកគេ។ ពួកគេត្រូវតែអាចស្វែងរកវិធីដោះស្រាយបញ្ហា ឬបន្តទៅមុខ និងកែសម្រួលទៅតាមស្ថានការណ៍។

**ការប្រាស្រ័យទាក់ទង៖** សិស្សនឹងរៀនអំពីការធ្វើផែនការ និងដំណើរការនៃទិដ្ឋភាពជាច្រើនក្នុងការប្រាស្រ័យទាក់ទងចាប់ពីសារដែលសំខាន់ៗរហូតដល់របៀបដាក់បញ្ចូលគ្នា និងការតាំងពិព័រណ៍ប្រកបដោយប្រសិទ្ធភាព រហូតដល់ទីផ្សារ និងការផ្សាយពាណិជ្ជកម្ម។

ប្រាស់ដីដែលនៅទំនេរ ការបង្កើតឱ្យមានកម្មវិធីសិល្បៈ និងសកម្មភាពផ្សេងៗទៀតនៅក្នុងសហគមន៍ និងអ្វីៗក៏ដោយឱ្យតែអ្នកសិក្សាចង់បង្ហាញ ឬបង្កើតឡើង(រាល់គំនិតពាក់ព័ន្ធដែលពួកគេបានរៀននៅក្នុងឆមាសនេះ)។



គំនិតមួយនៃការរៀបចំតាំងពិព័រណ៍ប្រកបដោយភាពច្នៃប្រឌិត(មានបង្ហាញច្រើនទៀតក្នុងឧបសម្ព័ន្ធ៣)។

សារសំខាន់ៗដែលសិស្សគួរពិចារណា៖

- ការប្រែប្រួលអាកាសធាតុសំដៅលើការផ្លាស់ប្តូរនៅកម្រិតជាមធ្យមនៃសីតុណ្ហភាព និងស្ថានភាពធាតុអាកាសនៅក្នុងរយៈពេលវែង។ បច្ចុប្បន្ននេះការប្រែប្រួលអាកាសធាតុគឺបានកើតឡើងយ៉ាងឆាប់រហ័សបើប្រៀបធៀបទៅនឹងអតីតកាល ហើយការប្រែប្រួលអាកាសធាតុនេះគឺបណ្តាលមកពីសកម្មភាពរបស់មនុស្ស។
- សកម្មភាពជាច្រើនរបស់មនុស្សបណ្តាលឱ្យមានឧស្ម័នផ្ទះកញ្ចក់ ដែលនាំឱ្យកើនឡើងកម្តៅផែនដី នៅរយៈកម្ពស់ទាបនៃស្រទាប់បរិយាកាស ដែលធ្វើឱ្យមានការកើនឡើងកម្តៅនៅស្ទើរគ្រប់ទីកន្លែង និងធ្វើឱ្យមានផលប៉ះពាល់ដល់របបខ្យល់និងរបបទឹកភ្លៀងផងដែរ។
- សកម្មភាពរបស់មនុស្សបានធ្វើឱ្យកើតមានឧស្ម័នផ្ទះកញ្ចក់រួមមាន៖ ការប្រើប្រាស់យានយន្តប្រើថាមពលប្រេងឥន្ធនៈច្រើនពេកជំនួសឱ្យការជិះកង់ ឬថ្មើរជើង ការដុតធ្យូងថ្ម ឬប្រេងដែលប្រើប្រាស់ជាថាមពលជំនួសដោយថាមពលស្អាតដូចជា ថាមពលពន្លឺព្រះអាទិត្យ(សូឡា) ឬខ្យល់(កង្ហារខ្យល់បង្កើតថាមពល)ការដាក់ជីនៅតាមវាលស្រែ ការបង្កើតឱ្យមានគំនរសំរាមដែលស្អុយរលួយ(កន្លែងចាក់សំរាម សំណល់ពីមនុស្សបោះចោលក្នុងទឹក សំណល់ពីសត្វ។ល។) ការប្រើប្រាស់ថាមពល

**ការរិះគិតពិចារណា ៖**

សម្រាប់សិស្សទាំងអស់ជាពិសេសអ្នកដែលធ្វើការប្រាស្រ័យទាក់ទងពួកគេត្រូវគិតអំពីវិធីសាស្ត្រណាដែលមានប្រសិទ្ធភាព និងរបៀបអនុវត្តវិធីសាស្ត្រនោះឱ្យល្អបំផុត។

ច្រើនពេក ការប្រើប្រាស់ផលិតផលដែលធ្វើអំពីផូស៊ីលឥន្ធនៈច្រើនពេក( ប្លាស្ទិក សារជាតុប៉ូលីអេស្ទែរ ឬសារជាតុសំយោគ)

- ប្រទេសកម្ពុជាមិនមែនជាមូលហេតុធ្វើឱ្យមានការប្រែប្រួលអាកាសធាតុនោះទេ ប៉ុន្តែយើងនឹងរួមចំណែកធ្វើឱ្យមានការប្រែប្រួលអាកាសធាតុដែរ ប្រសិនបើយើងបន្តកាប់បំផ្លាញព្រៃឈើ ប្រើប្រាស់ថាមពលហួសកម្រិត ដុតប្លាស្ទិក ប្រើប្រាស់ជី បង្ហូរកាកសំណល់ទៅក្នុងទឹកដោយមិនបានចម្រោះ ឬបន្សាបសារជាតុគ្រោះថ្នាក់នោះទេ។
- បន្ថែមលើការប្រែប្រួលអាកាសធាតុ មានបញ្ហាបរិស្ថានជាច្រើននៅប្រទេសកម្ពុជាដែលបំផ្លាញសុខភាព និងប៉ះពាល់ជីវភាពរស់នៅរបស់យើង។ បញ្ហាទាំងនេះមានដូចជា ការបំពុលទឹក ការបំពុលខ្យល់ សំណល់ប្លាស្ទិក ការអភិវឌ្ឍដោយគ្មាននិរន្តរភាពដូចជា ការសាងសង់អាគារលើដី និងព្រៃឈើធម្មជាតិ និងការសាងសង់ទីក្រុងនានា ធំៗនិងលឿនពេក។
- ប៉ុន្តែប្រទេសកម្ពុជាធ្លាប់មានបញ្ហាទាំងនេះរួចហើយ និងបន្តរងទុក្ខយ៉ាងធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ។
- យើងធ្លាប់ជួបគ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួតហើយ។ គ្រោះទាំងនេះបណ្ដាលឱ្យមានការខូតខាត និងប៉ះពាល់ដល់ការផលិតស្បៀង។ បញ្ហាទាំងនេះជាការខាតបង់ដ៏ធ្ងន់ធ្ងរ។
- នៅពេលដែលកម្រិតទឹកសមុទ្រកើនឡើងជាបន្តបន្ទាប់ ប្រទេសកម្ពុជាអាចរងការជន់លិចនៅក្នុងរយៈពេល ៧០ឆ្នាំទៅមុខទៀត តំបន់ភាគច្រើននៃប្រទេសកម្ពុជានឹងស្ថិតនៅក្រោមទឹក។
- យើងមិនអាចក្លាយជាប្រទេសអ្នកមានបានទេ ប្រសិនបើយើងរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយបង្កដោយអាកាសធាតុ។ ដូច្នេះហើយ យើងត្រូវរៀនសម្របខ្លួន និងរៀនរស់នៅប្រកបដោយនិរន្តរភាពដើម្បីកុំឱ្យមានបញ្ហា។
- មានវិធីជាច្រើនដើម្បីរស់នៅប្រកបដោយនិរន្តរភាព(វិធីទាំងនេះបានរៀនរួចហើយនៅក្នុងឆមាស)

**សកម្មភាពទី២ ៖ ការរៀបចំតាំងពិព័រណ៍ និងការហាត់សមពណ៌នា**

ក្នុងការតាំងពិព័រណ៍ គ្រូនិងសិស្សចាប់ផ្ដើមតាំងបង្ហាញដោយរៀបចំកន្លែងតាំងទៅតាមការចង់បាន ហើយគិតអំពីការប្រើប្រាស់ស្តុតពណ៌ ដើម្បីរចនាស៊ុម ឬរូបភាពផ្សេងៗ និងប្រើប្រាស់វត្ថុជាតុ

| | | | | |
|---|---|---|---|---|
| | | | ដើមពីសំរាមដើម្បីកែច្នៃជារូបភាព ឬវត្ថុបែបសិល្បៈដាក់លើជញ្ជាំង ឬកម្រាល។<br>លើកទឹកចិត្តសិស្សឱ្យមានការច្នៃប្រឌិតខ្ពស់ និងប្រើប្រាស់ធនធានតិចតួចតាមលទ្ធភាពដែលអាចធ្វើបាន ក្នុងការតាំងបង្ហាញរបស់ពួកគេ។ ត្រូវដឹងថា រូបភាពនៃខ្លឹមសារមួយចំនួនដែលពាក់ព័ន្ធត្រូវព្រីនចេញ ប៉ុន្តែព្រីនតិចបំផុត។ អាចប្រើជីសសរសេរផ្ទាល់លើជញ្ជាំង។ គ្រូយកចិត្តទុកដាក់លើការព្រីនរូបភាព ឬឯកសារទៅតាមតម្រូវការ ឬប្រគល់ភារកិច្ចទៅសិស្សណាម្នាក់ដែលអាចទុកចិត្តបាន។<br>គ្រូធ្វើការជាមួយសិស្សដើម្បីសរសេរលិខិតអញ្ជើញ ដោយបំពេញព័ត៌មានសំខាន់ៗមាន ពេលវេលា និងទីកន្លែងដែលត្រូវតាំងពិព័រណ៍។ ជាការប្រសើរ លិខិតអញ្ជើញគួរភ្ជាប់ជាមួយស្លាយដែលរៀបចំតាមកម្មវិធី Power Point ដោយមានការបញ្ចូលរូបភាពនិមិត្តសញ្ញាអ្វីមួយដែលសិស្សបានរចនា។ ស្លាយនេះគួរត្រូវរក្សាទុក និងចែករំលែកទៅសិស្សទាំងអស់តាមរយៈ WhatsApp Telegram ឬព្រីនចេញ និងថតចម្លងសម្រាប់ភ្ជាប់ជាមួយលិខិតអញ្ជើញ។<br>គ្រូណែនាំសិស្សឱ្យយកលិខិតអញ្ជើញ និងស្លាយនេះទៅក្រុមគ្រួសារ និងមិត្តភក្តិតាមដែលអាចបញ្ជូនបាន ដើម្បីទទួលបានចំនួនអ្នកចូលរួមមើលការតាំងពិព័រណ៍បានច្រើនកុះករនៅសប្តាហ៍បន្តបន្ទាប់ ។<br>ក្រោយពីការរៀបចំតាំងពិព័រណ៍ និងលិខិតអញ្ជើញត្រូវបានរៀបចំ( ការងារនេះត្រូវធ្វើដំណាលគ្នាតាមរយៈក្រុមគោលដៅសិស្សដែលយល់ពីការធ្វើស្លាយក្នុង PowerPoint បានល្អ ) គ្រូគួរដឹកនាំសិស្សឱ្យរៀបចំតាំងពិព័រណ៍ និងហាត់សមពណ៌នា។<br>ឧទាហរណ៍- ថ្ងៃតាំងពិព័រណ៍នេះនឹងដំណើរការដូចខាងក្រោម៖<br>• ការណែនាំរបស់គ្រូ<br>• វគ្គបង្រៀនរបស់សិស្ស និងសំណួរ-ចម្លើយ<br>• សិស្សណែនាំ និងបង្ហាញវីដេអូ<br>• សិស្សដឹកនាំពន្យល់ពីគម្រោងលើដីទំនេរ និងអ្វីដែលមានក្នុងការតាំងពិព័រណ៍<br>• សិស្សដឹកនាំពន្យល់ពីយុទ្ធនាការក្នុងសហគមន៍របស់ពួកគេ រួមទាំងសំណួរ-ចម្លើយ<br>• សិស្សអានរឿងអំពីអាកាសធាតុរបស់ពួកគេ។<br>ពេលវេលាសម្រាប់ភ្ញៀវដើរមើលជុំវិញការតាំងពិព័រណ៍ និងការសួរសំណួរ។ | |

| | | | | |
|---|---|---|---|---|
| | | | **កិច្ចការផ្ទះ** ៖ ឱ្យសិស្សយកលិខិតអញ្ជើញអ្នកដែលសិស្សស្គាល់ ដើម្បីអញ្ជើញពួកគាត់ឱ្យបានច្រើនតាមលទ្ធភាពធ្វើបាន។ នេះជាការបង្ហាញដ៏អស្ចារ្យមួយនៃការងាររបស់សិស្ស និងមានការច្នៃប្រឌិត ហើយវាក៏ជាឱកាសល្អសម្រាប់សហគមន៍មកចូលរួមជាមួយគ្នា និងសិក្សាពីរបៀបធ្វើឱ្យសហគមន៍កាន់តែរឹងមាំ។ | |
| ៤ | ១៤ | ៣(៣១) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ ទំនាក់ទំនងទៅក្រុមប្រឹក្សាឃុំសង្កាត់ ហើយប្រាកដថា យ៉ាងហោចណាស់មានតំណាងមួយរូបនឹងមកចូលរួម នៅថ្ងៃតាំងពិ ព័រណ៍។ សម្របសម្រួលជាមួយនាយក ឬគណៈគ្រប់គ្រងសាលាដើម្បីអញ្ជើញសហគមន៍ចូលរួមទស្សនាពិព័រណ៍។ ធ្វើការផ្សព្វផ្សាយនៅក្នុងសហគមន៍ដើម្បីឱ្យមាតាបិតាសិស្ស និងសមាជិកសហគមន៍មកចូលរួម។ សម្របសម្រួលជាមួយគ្រូផ្សេងទៀតដើម្បីឱ្យសិស្សថ្នាក់ផ្សេងបានមកចូលរួម និងចំណាយពេលយ៉ាងតិចមួយម៉ោងនៅក្នុងការតាំងពិព័រណ៍(ការតាំងពិព័រណ៍នេះនឹងក្លាយជាព្រឹត្តិការណ៍មួយរបស់សាលារៀន ហើយពួកគាត់អាចចូលរួមរហូតដល់ចប់កម្មវិធី)។<br>**សម្ភារៈ** ៖ កុំព្យូទ័រ ឧបករណ៍បញ្ចាំងស្លាយ រូបគំនូរ រូបថត រូបសិល្បៈ កែច្នៃ...។<br><br>**សកម្មភាពទី១៖ ការធ្វើបទបង្ហាញរបស់គ្រូ**<br>គ្រូស្វាគមន៍ដល់អ្នកចូលរួមទស្សនាទាំងអស់ ហើយពន្យល់ថាពួកគាត់មកទីនេះដើម្បីស្វែងយល់អំពីការប្រែប្រួលអាកាសធាតុ និងអំពីអ្វីដែលសិស្សធ្វើដើម្បីជួយការពារសហគមន៍ពីការប្រែប្រួលអាកាសធាតុ។ គ្រូចាប់ផ្តើមធ្វើបទបង្ហាញដោយពន្យល់ពីការប្រែប្រួលអាកាសធាតុដូចជា ការពន្យល់ពីស្រទាប់បរិយាកាស ទីតាំងនៃឧស្ម័នផ្ទះកញ្ចក់ និងសកម្មភាពមនុស្សដែលបង្កឱ្យមានបម្រែបម្រួលអាកាសធាតុ។ គ្រូមិនចាំបាច់បង្កើតនូវសម្ភារៈថ្មីទៀតទេ ដោយគ្រាន់តែធ្វើបទឧទ្ទេស និងប្រើសម្ភារៈដែលមានស្រាប់ពីការបង្រៀនសិស្សកន្លងមកក្នុងឆមាសនេះ។<br><br>**សកម្មភាពទី២៖ ការបង្រៀនរបស់សិស្ស និងសំណួរ-ចម្លើយ**<br>សិស្សដែលដើរតួជាគ្រូបង្រៀនត្រូវបានឱ្យធ្វើបទបង្ហាញរយៈពេលមិនលើសពី ២០នាទី ហើយទុកពេលឱ្យអ្នកចូលរួមដើម្បីអាចមានសំណួរបន្ទាប់ពីបទបង្ហាញ។ ប្រសិនបើអ្នកចូលរួមមិនមានសំណួរទេ គ្រូ(សិស្សដើរតួ)ត្រូវសួរសំណួរសំខាន់ៗមួយចំនួនទៅកាន់អ្នកចូលរួម ដោយផ្អែកលើការរៀននិងបង្រៀនកន្លងមកក្នុងឆមាស។ | **ការប្រាស្រ័យទាក់ទង** ៖ សិស្សត្រូវប្រាស្រ័យទាក់ទងគ្នាឱ្យបានច្បាស់លាស់ និងដោយភាពរីករាយ។ ពួកគេនឹងត្រូវចូលរួមក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក និងការកែលម្អ ឬការផ្តល់យោបល់ក្នុងម៉ោងសំណួរ-ចម្លើយ។<br><br>**ភាពធន់** ៖ ភាពធន់ក្នុងសហគមន៍ និងភាពធន់ផ្ទាល់ខ្លួនក្នុងការប្រឈមនឹងអាកាសធាតុ គឺជាស្នូលនៃសកម្មភាពនេះ។ សិស្សនឹងរៀនសូត្រ ទាំងសកម្មភាពជាក់ស្តែងនិងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវភាពធន់របស់ពួកគេ។<br><br>**ការច្នៃប្រឌិត** ៖ សិស្សនឹងប្រើភាពច្នៃប្រឌិតក្នុងការរៀបចំបទបង្ហាញ និងការតាំងពិព័រណ៍របស់ពួកគេ ប៉ុន្តែពួកគេត្រូវគិតដោយខ្លួនឯង និងមានភាពច្នៃប្រឌិតដើម្បីឆ្លើយនូវសំ |

**សកម្មភាពទី៣៖ ការណែនាំបង្ហាញរបស់សិស្សពីការផលិតវីដេអូ និងការបញ្ចាំងវីដេអូ**

សិស្សគួរចំណាយពេល១០នាទី ដើម្បីណែនាំបង្ហាញដំណើរការផលិតវីដេអូ តើហេតុអ្វីបានជាពួកគេផលិតវីដេអូ តើពួកគេផលិតវីដេអូយ៉ាងដូចម្ដេច ហេតុអ្វីបានជាពួកគេជ្រើសរើសប្រធានបទនេះ តើវាមានទំនាក់ទំនងយ៉ាងដូចម្ដេចទៅនឹងយុវជនជាសកម្មជនអាកាសធាតុផ្សេងទៀតជុំវិញពិភពលោក តើពួកគេបានរៀនសូត្រអ្វីខ្លះពីសកម្មភាពទាំងនោះ។ល។ បន្ទាប់មកបញ្ចាំងវីដេអូ។ វីដេអូបញ្ចាំងអាចត្រូវផ្អាក ដើម្បីទុកពេលនិយាយបន្តទៀត ប៉ុន្តែគួរធ្វើការបញ្ចាំងឡើងវិញនៅថ្ងៃចាប់ផ្ដើមតាំងពិព័រណ៍។

**សកម្មភាពទី៤ ៖ សិស្សធ្វើការពន្យល់អំពីគម្រោងលើដីទំនេរ និងអ្វីដែលមាននៅក្នុងការតាំងពិព័រណ៍**

គ្រូ និងសិស្សធ្វើការរួមគ្នាដឹកនាំអ្នកចូលរួមដើម្បីបង្ហាញសកម្មភាពសម្របខ្លួនរបស់ពួកគេ។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចនេះ សហគមន៍គួរត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរផ្សេងៗ ហើយឱ្យសិស្សព្យាយាមឆ្លើយសំណួរទាំងនោះជាមុន រួចហើយត្រូវកែតម្រូវចម្លើយ ប្រសិនបើចាំបាច់។ នៅពេលទៅដល់កន្លែងតាំងពិព័រណ៍ គ្រូត្រូវជ្រើសរើសសិស្សម្នាក់(ជម្រើសជាអាទិភាព) ដើម្បីធ្វើការពន្យល់សង្ខេបរយៈពេល ៥ទៅ១០នាទីអំពីអ្វីដែលពួកគេបានធ្វើ និងមូលហេតុផ្សេងៗដែលជាបទពិសោធរបស់ពួកគេ។ល។

**សកម្មភាពទី៥ ៖ សិស្សធ្វើការពន្យល់ផ្សព្វផ្សាយអំពីសារដែលបានដាក់តាំង និងសំណួរ-ចម្លើយ**

សិស្សធ្វើការពន្យល់ពីមូលហេតុនៃការជ្រើសរើសសារដែលពួកគេបានធ្វើ មូលហេតុនៃការជ្រើសរើសនិមិត្តសញ្ញា ឬរូបតំណាង និងមូលហេតុដែលគិតថា សកម្មភាពទាំងនេះមានសារៈសំខាន់សម្រាប់សហគមន៍។ សិស្សគប្បីស្នើអ្នកចូលរួមឱ្យសួរសំណួរ ហើយសិស្សអាចព្យាយាមឆ្លើយរាល់សំណួរទាំងនោះ ដោយមានការគាំទ្រពីគ្រូ និងនាយកសាលាប្រសិនបើចាំបាច់។

**សកម្មភាពទី៦ ៖ ការអានរឿងរបស់សិស្សស្ដីពីអាកាសធាតុ**

ការអានត្រូវទុកពេលសម្រាប់ការសួរសំណួរនៅចុងបញ្ចប់។ ប្រសិនបើពុំមានពេលគ្រប់គ្រាន់សម្រាប់សិស្សទាំងអស់អានម្ដងម្នាក់ៗទេ ស្នើឱ្យមានសិស្សស្ម័គ្រចិត្ត។ ប្រសិនបើមានសិស្សស្ម័គ្រចិត្តច្រើនពេក សរសេរឈ្មោះដាក់ក្នុងប្រអប់ រួចចាប់យកឈ្មោះ

ណួរដែលមិននឹកស្មានដល់ទៅកាន់ពួកគេ។

**ការរិះគិតពិចារណា៖** នៅពេលឆ្លើយសំណួរដែលមិននឹកស្មានដល់ ឬមានបញ្ហាប្រឈម ពួកគេត្រូវវាយតម្លៃយ៉ាងល្អិតល្អន់លើចម្លើយដែលសមស្រប មុនផ្ដល់ចម្លើយនោះ។ ពួកគេត្រូវបានផ្ដល់នូវឧបករណ៍ដើម្បីវាយតម្លៃថា តើហេតុអ្វីបានជាគេយកជម្រើសមួយនេះពីក្នុងចំណោមជម្រើសផ្សេងៗទៀត។

| | | | | |
|---|---|---|---|---|
| | | | មួយពីក្នុងប្រអប់ដោយចៃដន្យ ដើម្បីកុំឱ្យមានភាពលម្អៀង។ រំលឹកដល់សិស្សទាំងអស់ថា រឿងរបស់ពួកគេនឹងត្រូវបោះពុម្ព និងចែកផ្សាយដោយអង្គការយូនីសេស ទោះបីជាពួកគេពុំបានអានក្នុងថ្ងៃនេះក៏ដោយ។<br><br>**សកម្មភាពទី៧ ៖ ពេលវេលាសម្រាប់អ្នកចូលរួមទស្សនាពិព័រណ៍ និងសួរសំណួរផ្សេងៗ**<br>អ្នកចូលរួមប្រហែលអាចនៅទស្សនា ឬមិននៅទស្សនាការតាំងពិព័រណ៍គ្រប់ផ្នែកឱ្យបានអស់នោះទេ។ សិស្សគួរត្រៀមខ្លួនដើម្បីឆ្លើយសំណួរ ហើយអាចនៅជិតនឹងផ្នែកនៃវត្ថុពិព័រណ៍ណាមួយដែលពួកគេយល់ច្បាស់ដើម្បីពន្យល់ដល់ភ្ញៀវ។ ឧ.ប្រសិនបើពួកគេរៀបចំគម្រោងលើដីទំនេរ ពួកគេគប្បីនិយាយអំពីគម្រោងនោះ ឬបើពួកគេធ្វើការងារអំពីវីដេអូ ពួកគេគប្បីនិយាយអំពីវីដេអូ។ នៅអំឡុងពេលនៃការតាំងពិព័រណ៍ វីដេអូគួរតែបញ្ចាំងចោលដើម្បីឱ្យភ្ញៀវបានទស្សនាម្តងទៀត។<br><br>**កិច្ចការផ្ទះ៖** ឱ្យសិស្សបំពេញទម្រង់ក្នុងឧបសម្ព័ន្ធ១ ឱ្យបានរួចរាល់មុនពេលចូលរៀននៅម៉ោងបន្ទាប់។ | |
| **ជ.៦. ការឆ្លុះបញ្ចាំង និង ការវាយតម្លៃ** | | | **គោលបំណង** ៖ ដើម្បីលើកទឹកចិត្តសិស្សឱ្យធ្វើការឆ្លុះបញ្ចាំងគ្រប់ជំណាក់កាលនៃការរៀនសូត្រពេញមួយឆមាស រួមទាំងរបៀបអាចធ្វើឱ្យប្រសើរឡើងនូវបទពិសោធរបស់ពួកគេក្នុងការអនុវត្តការផ្សព្វផ្សាយ និងសកម្មភាពផ្សេងៗនៅក្នុងសហគមន៍។ | |
| ៤ | ១៥ | ២(៣៣) | **សកម្មភាពត្រៀមមុនរបស់គ្រូ** ៖ គ្រូត្រូវរៀបចំទម្រង់សម្រាប់សិស្សបំពេញនូវបញ្ហាប្រឈម និងអនុសាសន៍ផ្សេងៗនៅក្នុងរបាយការណ៍សកម្មភាព ព្រមទាំងផែនការសម្រាប់ឆ្នាំក្រោយបន្ទាប់ផងដែរ(ឧបសម្ព័ន្ធ៦)។ គ្រូត្រូវត្រៀមគំនិតសម្រាប់ណែនាំសិស្សដើម្បីវិភាគអំពី ស្ថានភាព សកម្មភាព និងផែនការសម្រាប់ឆ្នាំក្រោយបន្ទាប់(ឧបសម្ព័ន្ធ៧)។<br>**សម្ភារៈ** ៖ ផូស្ទ័រស្វ័យវង្វាយតម្លៃ តារាងបញ្ហាប្រឈម និងអនុសាសន៍(ឧបសម្ព័ន្ធ៦)។ តារាងអំពីចំណុចខ្លាំង និងចំណុចខ្សោយ(ឧបសម្ព័ន្ធ៧) សម្រាប់ផែនការឆ្នាំបន្ទាប់។<br>***<u>សេចក្តីផ្តើម</u>***៖ គ្រូអបអរសាទរសិស្សនូវរាល់កិច្ចការដែលពួកគេបានធ្វើ និងសកម្មភាពផ្សព្វផ្សាយ។ គ្រូពន្យល់ថា ថ្ងៃនេះយើងនឹងឆ្លុះបញ្ចាំងរាល់កិច្ចការទាំងអស់ ដើម្បីរៀនសូត្រសម្រាប់ថ្ងៃអនាគត អ្វីដែលងាយស្រួលធ្វើ អ្វីដែលពិបាកធ្វើ អ្វីដែលថ្មី និងអ្វីដែលបានដឹងរួចហើយ ។ | **ការរិះគិតពិចារណា** ៖ សម្រាប់សិស្សទាំងអស់ ប៉ុន្តែជាពិសេសអ្នកដែលធ្វើការផ្សព្វផ្សាយ ពួកគេត្រូវគិតអំពីវិធីសាស្ត្រអ្វីដែលមានប្រសិទ្ធភាពបំផុត និងរបៀបអនុវត្តបានល្អបំផុត។<br><br>**ទំនាក់ទំនង** ៖ សិស្សត្រូវការបង្ហាញទស្សនៈរបស់ពួកគេយ៉ាងច្បាស់លាស់ និង ស្តាប់អ្នកដទៃដោយយកចិត្តទុកដាក់ ដើម្បី |

| | | | | |
|---|---|---|---|---|
| | | | **សកម្មភាពទី១ ៖ ការឆ្លុះបញ្ចាំងលើដំណើរការរៀនសូត្រ ដំណើរការស្រាវជ្រាវ ការអនុវត្ត និងការផ្សព្វផ្សាយ**<br>ឱ្យសិស្សយកកិច្ចការផ្ទះដែលបានបំពេញរួចកាលពីសប្តាហ៍មុន ឬ សប្តាហ៍ទី១៤( ឧបសម្ព័ន្ធ១ )។<br>ឱ្យសិស្សលើកឧទាហរណ៍មួយចំនួនអំពី **ស្ថានភាព ឥរិយាបថ**(អ្វីដែលបានធ្វើ) និង **ផលប៉ះពាល់**( លទ្ធផលនៃសកម្មភាពពួកគេ )។ ធ្វើផ្ទស្វ័រង្វាយតម្លៃចំនួន៣ ឬគូរលើក្តារខៀន ហើយឱ្យសិស្សឆ្លុះបញ្ចាំងទៅលើដំណើរការរៀន បទពិសោធស្រាវជ្រាវ និងដំណើរការអនុវត្ត ឬដំណើរការផ្សព្វផ្សាយ។<br>**ស្ថានភាព**៖ តើអ្នកអាចនិយាយអំពីស្ថានភាពបានទេ ? ឬ "ពេលដែលយើង...."<br>**ឥរិយាបថ**៖ តើអ្វីដែលអ្នកបានធ្វើ ? តើអ្នកមានភាពប្រសើរឡើងយ៉ាងណា ក្នុងអំឡុងពេលឆមាស ?<br>**ផលប៉ះពាល់**៖ តើអ្វីជាលទ្ធផលចុងក្រោយ ?<br>បែងចែកសិស្សជាដៃគូ ហើយឆ្លើយសំណួរខាងក្រោម៖<br>- តើសកម្មភាពមួយណាដែលអ្នកយល់ថាវាលំបាកជាងគេបំផុត ?<br>- តើសកម្មភាពមួយណាដែលអ្នកចូលចិត្តជាងគេ ?<br>- តើអ្នកគួរធ្វើសកម្មភាពអ្វីខុសពីនេះ នៅឆ្នាំក្រោយ ?<br>ឱ្យសិស្សបង្ហាញឧទាហរណ៍ជាក់ស្តែងពីមេរៀន។ បន្ទាប់មកគ្រូសួរដៃគូសិស្ស ( គ្រូជ្រើសរើសដោយចៃដន្យយកពី ៤ទៅ៦គូយ៉ាងច្រើនបំផុត ) ដើម្បីផ្តល់ចម្លើយ ហើយពិភាក្សាជាមួយសិស្សផ្សេងទៀតក្នុងថ្នាក់។<br><br>**សកម្មភាពទី២ ៖ ការសរសេរបញ្ចប់របាយការណ៍សកម្មភាពស្រាវជ្រាវ**<br>គ្រូពន្យល់សិស្សថា អ្នកទាំងអស់គ្នាត្រូវរៀបចំរបាយការណ៍សង្ខេបដើម្បីជួយសិស្សដទៃទៀតឱ្យធ្វើសកម្មភាពដូចគ្នានៅពេលក្រោយ។ គ្រូប្រាប់សិស្សឱ្យសង្ខេបអ្វីដែលបានសរសេរក្នុងផ្ទស្វ័រ ស្វ័យវង្វាយតម្លៃ ព្រមទាំងបន្ថែមគំនិតផ្ទាល់ខ្លួនរបស់ពួកគេអំពីអ្វីដែលរីករាយបំផុត អ្វីដែលលំបាកបំផុត អ្វីដែលពេញចិត្តបំផុត និងអ្វីដែលពួកគេធ្វើខុសពីនេះ។ បន្ទាប់មកពួកគេត្រូវសរសេរអ្វីដែលជាបញ្ហាប្រឈម និងអនុសាសន៍ផ្ទាល់ខ្លួន( ឧបសម្ព័ន្ធ៦ )ទុកសម្រាប់សិស្សផ្សេងទៀត។ គ្រូរំលឹកនូវអ្វីដែលសិស្សបានពិភាក្សានៅក្នុងសកម្មភាពមុនៗ ហើយសួរថា តើអ្វីដែលពួកគេចង់ប្រាប់ | យល់ និងពេញចិត្តលើទស្សនៈ ផ្សេងៗ។<br><br>**ភាពធន់** ៖ សិស្សគ្រប់គ្នាបានរៀនសូត្រអំពីភាពធន់ទាំងផ្នែករាងកាយ និង ឥរិយាបថពេញមួយឆមាស ប៉ុន្តែពេលនេះភាពធន់ផ្នែកអារម្មណ៍គួរផ្តោតជាសំខាន់។<br><br>**ការចូលរួម** ៖ គឺការរួមបញ្ចូលនូវគំនិត យោបល់របស់សិស្ស និងផ្តល់ឱ្យពួកគេធ្វើការគ្រប់គ្រងលើការរៀនសូត្ររបស់ពួកគេ។ ការចូលរួមបង្រៀនអ្នកសិក្សាឱ្យចូលរួមយ៉ាងសកម្ម។ នៅម៉ោងសិក្សាបញ្ចប់នេះ ក៏ដូចជាគ្រប់ម៉ោងសិក្សាទាំងអស់ពេញមួយឆមាស សិស្សគួរយល់ដឹងអំពីរបៀបនៃការចូលរួមរបស់គេមានតម្លៃយ៉ាងដូចម្តេច និងចំណុចដែលជំរុញការចូលរួមកាន់តែខ្លាំង។ |

| | | | | |
|---|---|---|---|---|
| | | | ដល់សិស្សផ្សេងទៀត ដែលវានឹងមានប្រយោជន៍ក្នុងការធ្វើការងារគម្រោងដូចគ្នានេះនៅពេលខាងមុខ។<br>គ្រូឱ្យសិស្សធ្វើការជាក្រុមតូចដែលមានគ្នាពី ៣ទៅ៤នាក់ ហើយឱ្យពួកគេយល់ស្របគ្នាលើបញ្ហាប្រឈម និងអនុសាសន៍ចំនួន១-២។ គ្រូឱ្យក្រុមនីមួយៗចាត់តាំងម្នាក់ក្នុងចំណោមពួកគេដើម្បីសរសេររបាយការណ៍សកម្មភាពក្នុងឆមាស ហើយឱ្យសិស្សក្នុងក្រុមជួយផ្តល់គំនិត និងសំយោគរបាយការណ៍រួមមួយទុកជាឯកសារដាក់ក្នុងបណ្ណាល័យ។<br><br>**សកម្មភាពទី៣ ៖ ការជ្រើសរើសប្រធានបទសម្រាប់ឆ្នាំបន្ទាប់**<br>គ្រូឱ្យសិស្សគិតអំពីប្រធានបទដែលពួកគេចាប់អារម្មណ៍សម្រាប់ឆ្នាំបន្ទាប់ ដើម្បីលើកសំណើនៅក្នុងដំណើរការធ្វើកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន និងផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាសិស្សអំពីប្រធានបទដែលបានជ្រើសរើស។ គ្រូឱ្យសិស្សកំណត់បញ្ហាមួយចំនួននៅក្នុងសហគមន៍ដែលប៉ះពាល់ខ្លាំងដល់ពួកគេ និងឱកាសដែលពួកគេមាន( សូមមើលឧបសម្ព័ន្ធ៧ )។<br><br>**កិច្ចការផ្ទះ** ៖ សូមប្អូនឈប់សំរាកពីការសិក្សាដោយរីករាយ ហើយសូមព្យាយាមអនុវត្តទម្លាប់កាត់បន្ថយការប្រើប្រាស់( ផលិតផលវេចខ្ចប់ដោយប្លាស្ទិក ថាមពលអគ្គិសនី ទឹក... )នៅតាមផ្ទះជាមួយគ្រួសារ និងជាមួយអ្នកជិតខាង។ បង្កើតឬកែច្នៃរូបផ្សេងៗ ដើម្បីតុបតែងលម្អលំនៅដ្ឋានដោយភាពច្នៃប្រឌិត ប្រសិនបើមានការគាំទ្រពីឪពុកម្តាយរបស់ប្អូន។ | |

## ឧបសម្ព័ន្ធ ១ ៖ ទម្រង់ស្វ័យវាយតម្លៃ និងវាយតម្លៃជាក្រុម

| ឈ្មោះ ៖ ................................................ | ថ្នាក់ទី ៖ ................................................ |
|---|---|

**សំណួរទី១ ៖** តើអ្នកពេញចិត្តនឹងវគ្គសិក្សានេះដែរឬទេ? ចូរគូសរង្វង់លើចម្លើយណាមួយ និងសរសេរពីមូលហេតុនោះ

បាទ/ចា៎ ធម្មតា ទេ ...................................................................................

**សំណួរទី២ ៖** តើអ្នកគិតថាបំណិនទន់ទាំងនេះមានភាពប្រសើរឡើងតាមរយៈសកម្មភាពផ្សេងៗដែរឬទេ?

| **បំណិនទន់** | **ភាពប្រសើរឡើង** | | | ហេតុអ្វី? តើឥរិយាបថ ឬគំនិតរបស់អ្នកមានផលប៉ះពាល់ដូចម្តេចដល់ក្រុម? វិជ្ជមាន ឬ អវិជ្ជមាន? |
|---|---|---|---|---|
| ការដោះស្រាយបញ្ហា | បាទ/ចា៎ | ធម្មតា | ទេ | |
| ការរិះគិតពិចារណា | បាទ/ចា៎ | ធម្មតា | ទេ | |
| ភាពធន់ | បាទ/ចា៎ | ធម្មតា | ទេ | |
| សហប្រតិបត្តិការ | បាទ/ចា៎ | ធម្មតា | ទេ | |
| ការប្រាស្រ័យទាក់ទង | បាទ/ចា៎ | ធម្មតា | ទេ | |
| ការចូលរួម | បាទ/ចា៎ | ធម្មតា | ទេ | |
| ការចរចា | បាទ/ចា៎ | ធម្មតា | ទេ | |
| ការច្នៃប្រឌិត | បាទ/ចា៎ | ធម្មតា | ទេ | |
| ការសម្រេចចិត្ត | បាទ/ចា៎ | ធម្មតា | ទេ | |
| ការយល់ចិត្ត | បាទ/ចា៎ | ធម្មតា | ទេ | |
| ការគោរពភាពចម្រុះ | បាទ/ចា៎ | ធម្មតា | ទេ | |

| | | | | |
|---|---|---|---|---|
| ស្វ័យគ្រប់គ្រង | បាទ/ចាំ | ធម្មតា | ទេ | |
| **សំណួរទី៣ ៖** ប្រសិនបើអ្នកត្រូវបានផ្តល់ឱកាសដើម្បីធ្វើសកម្មភាពដូចមុន តើអ្នកនឹងមានឥរិយាបថខុសគ្នាយ៉ាងដូចម្តេច? តើអ្នកគិតថា ឥរិយាបថ ឬ គំនិតរបស់អ្នកមានផលប៉ះពាល់លើក្រុមយ៉ាងដូចម្តេច? | | | | |
| **សំណួរទី៤ ៖** តើអ្នកចង់ទទួលបានការគាំទ្របែបណាពីគ្រូរបស់អ្នក ពីសិស្សផ្សេងទៀត ឬពីក្រុមគ្រួសាររបស់អ្នកទាក់ទងនឹងការប្រែប្រួលអាកាសធាតុ? | | | | |

## *ឧបសម្ព័ន្ធ ២ ៖ គម្រោងផែនការផ្សព្វផ្សាយ*

| | |
|---|---|
| ឈ្មោះក្រុម | |
| សមាជិកក្រុម | |
| ឈ្មោះគម្រោង | |
| បញ្ហាដែលបានកំណត់ | |
| គោលដៅគម្រោង | |
| សម្ភារៈ ឬឧបករណ៍ចាំបាច់ដើម្បីអនុវត្តគម្រោង | |
| មូលហេតុដែលគម្រោងនេះត្រូវបានជ្រើសរើសដើម្បីដោះស្រាយបញ្ហា | |
| ការពិពណ៌នាអំពីបញ្ហាក្នុងគម្រោង ៖ | |

| |
|---|
| |
| ការពិពណ៌នាដំណោះស្រាយក្នុងការផ្សព្វផ្សាយ ឬសារគន្លឹះ ៖ |
| តើអ្នកវាយតម្លៃលទ្ធផលគម្រោងយ៉ាងដូចម្តេច? |

## ឧបសម្ព័ន្ធ ៣ ៖ គំនិតខ្លះៗសម្រាប់កន្លែងតាំងពិព័រណ៍

ការកំណត់ស៊ុម ការកំណត់ទីតាំងទៅតាមប្រភេទផ្សេងៗគ្នា និងការគូរគំនូរលើផ្ទៃជញ្ជាំង





ការប្រើវត្ថុច្នៃប្រឌិតផ្សេងៗដាក់តាមជញ្ជាំង (រូបកែច្នៃពីសំរាមប្លាស្ទិក...)។ ដាក់លើកម្រាល និងលើជញ្ជាំង ប្រកបដោយភាពច្នៃប្រឌិត





ប្រើប្រព័ន្ធផ្សព្វផ្សាយចម្រុះ ទម្រង់ផ្សេងៗគ្នា ច្នៃប្រឌិតប្រកបដោយលក្ខណៈសិល្បៈ






## ឧបសម្ព័ន្ធ ៤ ៖ គំនិតខ្លះៗលើដីទំនេរ

ស្តង់លក់ទំនិញ ឬសេវាកម្ម



រថយន្ត ឬស្តង់លក់អាហារ



ផ្សារណាត់ពិព័រណ៍ផលិតផល



សួនសហគមន៍



ចម្ការដំណាំហូបផ្លែសហគមន៍



ទីលានហាត់ប្រាណ



សួនកុមារ (ធ្វើពីវត្ថុធាតុដើមកែច្នៃ)



ទីលានសម្រាប់កម្សាន្ត និងរៀបចំព្រឹត្តិការណ៍ផ្សេងៗ



កន្លែងបោះជំរុំ



ស្ទូឌីយោថតរូបនៅទីធ្លាខាងក្រៅ



ទីលានអប់រំសហគមន៍



លំនៅដ្ឋានសម្រាប់ជនក្រីក្រ



ទីលានសិល្បៈសហគមន៍



## *ឧបសម្ព័ន្ធ៩ ៖ ផូស្ទ័រស្វ័យវង្វាយតម្លៃ*

**លំណែនាំ៖** ផ្អែកលើតម្រូវការរបស់សិស្ស គ្រូបង្រៀនត្រូវសម្រេចចិត្តកំណត់យកបំណិនទន់គោលដៅ និងលទ្ធផលសិក្សាសង្ឃឹមទុកទៅតាមកម្រិតនៃបំណិនទន់។ ប្រើឧទាហរណ៍នៅក្នុងឯកសារណែនាំអនុវត្តបំណិនជីវិតតាមមូលដ្ឋានដើម្បីទទួលបានគំនិត។ សាលារៀនប្រើប្រាស់បំណិនទន់ទាំង១២ ជាគោល ហើយគ្រូអាចជ្រើសរើសប្រភេទបំណិនទន់ណាក៏បាន ចំនួនបំណិនទន់ប៉ុន្មានក៏បាន ដើម្បីកំណត់លទ្ធផលសិក្សាដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស (ទីបំផុត បំណិនទន់ដែលបានជ្រើសរើសទាំងអស់នឹងមានបំណិនទន់ទាំង១២ នៅក្នុងស្តង់ដាកម្មវិធីសិក្សា។ ឧទាហរណ៍ បំណិនទន់មួយក្នុងចំណោមបំណិនទន់ទាំង១២ គឺការប្រាស្រ័យទាក់ទងដែលជាគុផ្សំរួមមានបំណិនស្តាប់ និងបំណិនសង្ខេប)។ ដូចនេះលទ្ធផលដែលបានកំណត់ នឹងឆ្លើយតបទៅនឹងស្តង់ដាសិក្សានៃបំណិនទន់ទាំង១២ ដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

ធានាថាផូស្ទ័រស្វ័យវង្វាយតម្លៃត្រូវរៀបចំឱ្យបានរួចរាល់មុនពេលអ្នកចាប់ផ្តើមបង្រៀនមេរៀនដំបូង។ អានល្បះទាំងអស់ឱ្យសិស្សក្នុងថ្នាក់ស្តាប់ ហើយត្រូវប្រាកដថាពួកគេយល់ច្បាស់។ ជារៀងរាល់សប្តាហ៍ ប្រើផូស្ទ័រនេះសម្រាប់ធ្វើការឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃមេរៀន។

| ស្វ័យវង្វាយតម្លៃប្រចាំសប្តាហ៍ | |
|---|---|
| ខ្ញុំចូលរួមក្នុងការពិភាក្សា | បាទ/ចា៎ អាច ទេ |
| ខ្ញុំតែងតែស្តាប់មិត្តភក្តិ | បាទ/ចា៎ អាច ទេ |
| ខ្ញុំចូលរួមក្នុងការងារក្រុម | បាទ/ចា៎ អាច ទេ |
| ខ្ញុំធ្វើការងាររបស់ខ្ញុំចប់ទាន់ពេលវេលា | បាទ/ចា៎ អាច ទេ |
| ពេលខ្ញុំដឹងមិត្តរួមថ្នាក់ពិបាកចិត្តខ្ញុំព្យាយាមជួយ | បាទ/ចា៎ អាច ទេ |
| ខ្ញុំមានទំនុកចិត្តក្នុងការផ្តល់គំនិតរបស់ខ្ញុំ | បាទ/ចា៎ អាច ទេ |

## *ឧបសម្ព័ន្ធ ៦ ៖ របាយការណ៍សកម្មភាព*

ពណ៌នាអំពីបញ្ហាប្រឈមដែលអ្នកបានជួបប្រទះក្នុងអំឡុងពេលធ្វើសកម្មភាព និងវិធីដែលអ្នកដោះស្រាយបញ្ហាប្រឈមនោះ។ ផ្តល់ឧទាហរណ៍មួយចំនួនអំពីបញ្ហាប្រឈម៖ ត្រូវការពេលបន្ថែមដើម្បីធ្វើសកម្មភាពមួយចំនួន មានការលំបាកក្នុងការទាក់ទងជាមួយអ្នកពាក់ព័ន្ធមួយចំនួន មានការលំបាកក្នុងការយល់ដឹងអំពីសម្ភារៈ មានការលំបាកក្នុងការអនុវត្ត។ល។

| បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|
| | |
| | |
| | |
| | |

**អនុសាសន៍**

នៅក្នុងកថាខណ្ឌនេះ សូមពណ៌នាអំពីសំណើណាមួយដែលអ្នកគិតថាអាចជួយសិស្សផ្សេងទៀតឱ្យធ្វើការស្រាវជ្រាវដូចអ្នកបានធ្វើរួចហើយ។ ព័ត៌មានខ្លះអាចជួយសម្រួលដល់ការងាររបស់ពួកគេ ឧទាហរណ៍ (ប្រភពព័ត៌មានណាមួយដែលជួយអ្នកបានច្រើនបំផុត ឬសម្ភារៈដែលមានប្រយោជន៍បំផុតដែលអ្នកបានរកឃើញនៅក្នុងបណ្ណាល័យ) ឬសារៈសំខាន់នៃការហាត់សមធ្វើការសម្ភាស ឬពិនិត្យមើលថាតើគ្រប់គ្នាដឹងច្បាស់អំពីតួនាទីរបស់ពួកគេមុនពេលចាប់ផ្តើមធ្វើសកម្មភាពមួយ ...។

## *ឧបសម្ព័ន្ធ ៧ ៖ ការវិភាគស្ថានភាព*

គ្រូណែនាំសិស្សឱ្យគិតអំពី **បញ្ហា** និង **ឱកាស** ថ្មីដែលពួកគេអាចនឹងស្នើឡើងនៅក្នុងពេលធ្វើកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀនក្នុងឆ្នាំសិក្សាខាងមុខ។

ចំណុចចាប់ផ្តើមគឺត្រូវសួរសិស្សក្នុងជីវិតប្រចាំថ្ងៃ តើពួកគេចាប់អារម្មណ៍រៀនអ្វីបន្ថែមទៀត។ គ្រូអាចប្រើភាពជាដៃគូនៃសាលារៀន ដើម្បីទទួលបានគំនិតមួយចំនួនក្នុងការកំណត់អំពីបញ្ហា ឬឱកាសដែលអាចមានដោយសាលារៀនផ្សេងទៀតនៅក្នុងស្រុក ឬខេត្តតែមួយដើម្បីជំរុញលើកទឹកចិត្តសិស្ស។

**បញ្ហា**

សំណួរដែលអាចមាន៖ តើមានបញ្ហាអ្វីខ្លះនៅក្នុងសហគមន៍របស់អ្នកដែលកំពុងប៉ះពាល់ដល់អ្នក ឬមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកឬទេ? បញ្ហាបរិស្ថាននៅក្នុងសហគមន៍ដែលប៉ះពាល់ដល់អ្នកដោយផ្ទាល់ ឬដោយប្រយោល និងកន្លែងដែលអ្នកតែងតែទៅ។ តើមានអ្វីខ្លះដែលអ្នកបានសិក្សានៅសាលារៀនដែលអ្នកចង់អង្កេតស្រាវជ្រាវ និងរៀនសូត្របន្ថែមនៅក្នុងសហគមន៍របស់អ្នកដែរឬទេ?

**ឱកាស**

សំណួរដែលអាចមាន៖ តើមានអ្វីគួរឱ្យចាប់អារម្មណ៍ដែលកំពុងកើតឡើងនៅក្នុងសហគមន៍របស់អ្នក ដែលអ្នកចង់រៀនសូត្របន្ថែមទៀតឬទេ? សកម្មភាពគួរឱ្យចាប់អារម្មណ៍ណាមួយ? អាជីវកម្មណាមួយ?

តើមានមេរៀនណាខ្លះដែលអ្នកអាចរៀនពីមនុស្សនៅជុំវិញអ្នក (ជោគជ័យ និងបរាជ័យ) លើបញ្ហា និងសកម្មភាពអាជីពងាយដែលបានកំណត់នោះ?

**បច្ចេកទេសប្រើប្រាស់ដើម្បីកំណត់ចម្លើយ និងសរសេររបាយការណ៍៖**

- ការបំផុសគំនិត
- ការពិភាក្សា
- ការប្រើឧទាហរណ៍ពីសាលារៀនផ្សេងទៀត
- ការរៀបចំព័ត៌មានដោយប្រើទស្សនៈរបស់សិស្ស។

| **ចំណុចខ្លាំង**<br>(ឱកាសដែលអាចមានដើម្បីស្រាវជ្រាវបន្ថែម) | **ចំណុចខ្សោយ**<br>(បញ្ហាដែលអាចមានដើម្បីស្រាវជ្រាវបន្ថែម) |
|---|---|
| - តើអ្វីជាជោគជ័យនៅក្នុងភូមិ?(ឧ. អាជីវកម្ម សេវាកម្ម ការងារសិល្បៈ គម្រោងអង្គការក្រៅរដ្ឋាភិបាល គំនិតផ្តួចផ្តើមរបស់យុវជន...)<br>- តើអ្វីដែលធ្វើឱ្យភូមិរបស់យើងប្រសើរជាងភូមិដទៃទៀត?<br>- តើអ្វីដែលធ្វើឱ្យមនុស្សស្គាល់ភូមិរបស់យើង? | - តើអ្វីដែលដំណើរការមិនល្អនៅក្នុងភូមិ?<br>- តើមានបញ្ហាអ្វីខ្លះដែលកំពុងប៉ះពាល់ដល់ជីវិតរបស់អ្នកនៅក្នុងភូមិ?(ឧ. កង្វះទឹក ទឹកជំនន់ មានគ្រោះថ្នាក់ច្រើន ការប្រើប្រាស់គ្រឿងញៀន...)<br>- តើអ្វីដែលអាចកែលម្អបាននៅក្នុងភូមិ? |

## ឧបសម្ព័ន្ធ ៨ ៖ គំនិតខ្លះៗពីសិល្បៈសំរាម

ដើម្បីទទួលគំនិតបន្ថែម សូមចូលទៅកាន់ Google ឬ google.kh ហើយស្វែងរក " trash sculptures" (រូបផ្ដុំពីសំរាម) ឬ "trash art" (សិល្បៈសំរាម)។






AGIL
FRAGIL
FR






Main Gallery


WASHED ASHORE
Exhibit Open
11 am to 4 pm
www.sfzoo.org



## *ឧបសម្ព័ន្ធ ៩ ៖ សវនកម្មសំណល់ថាមពល*

| A | B | C | D | E | F | G | H | I | J |
|---|---|---|---|---|---|---|---|---|---|
| ផលិតផល | តើវាបើកទេឥឡូវនេះ? | ជាធម្មតាតើវាបើកប៉ុន្មានម៉ោង/ថ្ងៃ? | តើវាអាចបើកប៉ុន្មានម៉ោងទៀត? | តើវាមានការសម្រាកខ្លះទេ? (5% នៃថាមពលក្នុងការបើក) | (ប្រសិនបើមានសម្រាក) តើវាសម្រាកប៉ុន្មានម៉ោង/ថ្ងៃ? | មធ្យមវ៉ាត់/ម៉ោងក្នុងមួយផលិតផល (ពីអ៊ីនធឺណិត) | ចំនួនម៉ោងបើកសរុប C + F x 0.05 | ប្រាក់ចំណាយលើឧបករណ៍ដំណើរការក្នុងមួយឆ្នាំ (H x G) ÷ 1000 x 610 រៀល/kWh x 365ថ្ងៃ | ប្រាក់សន្សំប្រសិនបើបិទច្រើន៖ [(F x 0.05) + D] x (G) ÷ 1000 x 610 រៀល/kWh x 365ថ្ងៃ |
| ទូរទឹកកក | បាទ/ចាំ | 24 | 0 | គ្មាន | 0 | 200 | 24 | 1068720 រៀល | 0 |
| ទូរទស្សន៍ | ទេ | 4 | 2 | មាន | 20 | 200 | 5 | 222650 រៀល | 133590 រៀល |
| កង្ហារបញ្ឈរ | បាទ/ចាំ | 12 | 12 | គ្មាន | 0 | 0.04 | 12 | 214 រៀល | |
| កង្ហារពិដាន | | | | | | 0.03 | | | |
| អំពូលភ្លើង | | | | | | 5 | | | |
| ... | ... | | .... | .... | ... | ... | ... | | |
| ... | ... | | ... | ... | ... | ... | ... | | |
| | | | | | | | | ប្រាក់ចំណាយសរុប (បូកជួរឈរទាំងអស់) | ប្រាក់សន្សំសរុបដែលអាចទទួលបាន (បូកជួរឈរទាំងអស់) |

*ឧបសម្ព័ន្ធ ១០ ៖ តារាងគំរូនៃការប្រើប្រាស់ប្លាស្ទិកនៅផ្ទះ*

| ប្រភេទផ្សេងៗនៃផលិតផលដែលបានប្រើប្រាស់ | | | | | | |
|---|---|---|---|---|---|---|
| កាលបរិច្ឆេទនៃការទិញ | អាហារ និង ភេសជ្ជៈ | របស់លេង | សៀវភៅ | ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ | សម្លៀកបំពាក់ | ផលិតផលថែរក្សាសម្រស់ |
| | ឧ- ប្លាស្ទិក ដប ភេសជ្ជៈ | ឧ - តុក្កតាជ័រ | | ឧ- ប្រើប្រាស់ក្នុង បន្ទប់ទឹក | ឧ- អាវធ្វើពីសារធាតុប្លាស្ទិក | ឧ - ដបសាប៊ូ |
| | | | | | | |

| ផលិតផល? | តើយើងអាចរស់នៅដោយគ្មានវាបានឬទេ? | សម្ភារៈវេចខ្ចប់? | តើរបស់វេចខ្ចប់នឹងត្រូវបោះចោលដោយរបៀបណា? | តើផលិតផលនឹងត្រូវប្រើប្រាស់ ឬបោះចោល? | បើបោះចោល តើគួរចោលដោយរបៀបណា? | តើមានជម្រើសល្អជាងនេះទេ? តើវាជាអ្វី? | តើជម្រើសនោះសមស្របសម្រាប់គ្រួសាររបស់ខ្ញុំឬទេ? ហេតុអ្វីសមស្រប ឬហេតុអ្វីមិនសមស្រប? |
|---|---|---|---|---|---|---|---|
| ដបទឹក | បាទ | ប្លាស្ទិក | ចោលក្នុងធុងសំរាម | ប្រើប្រាស់ឡើងវិញ | | បាទ ម៉ាស៊ីនទឹក | ទេ យើងមិនអាចមានលទ្ធភាពទិញវាបានទេ។ |
| ឯកសណ្ឋានសាលា | ទេ | ប្លាស្ទិក | បោះចោលក្នុងធុងសំរាម | បោះចោល | ធុងសំរាមនៅពេលចាស់ពេកឬចង្អៀត | បាទឬចាស | ប្រែក្លាយអាវចាស់នោះទៅជាសិប្បកម្មឬវត្ថុដែលអាចប្រើប្រាស់បាន។ |
| ... | ... | ... | ... | ... | ... | ... | ... |